ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត


ប្រភព ៖ សារមន្ទីរសិល្បៈមេត្រូប៉ូលីតែន

- កម្មសិទ្ធិប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជា
- សំណុំរឿងប្រាសាទព្រះវិហារ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៦១ ខែឧសភា ឆ្នាំ២០១៣

# ស្វែងរកការពិត

លេខ១៦១ ខែឧសភា ឆ្នាំ២០១៣

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆កម្មសិទ្ធិប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជា........................................១

**ផ្នែកឯកសារ**

◆ហៃ សំអុល រៀបរាប់ពីសកម្មភាពក្បត់បដិវត្តន៍................................៣

◆បញ្ជីឈ្មោះ និងរូបថតអ្នកទោសមន្ទីរស-២១....................................៥

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ការអប់រំរបស់ខ្មែរក្រហម : ការអប់រំកុមារឲ្យមានកំហឹង......................៩

◆ខ្ញុំបាត់បង់ឪពុក.....................................................................១៧

◆បបរលាយជាមួយទឹកដោះម្ដាយ.................................................២១

◆បានត្រឹមតែដឹង.....................................................................២៤

◆ម្ដាយបូជាជីវិតដើម្បីកូន..........................................................២៧

◆ណាយនឹងសង្គ្រាម.................................................................៣០

◆ម៉ាឡៃតំបន់ជម្រោះដូរបត់........................................................៣៤

**ផ្នែកច្បាប់**

◆វិទ្យុសហគមន៍ : តើការអត់ឃ្លានវិវត្តទៅយ៉ាងដូចម្ដេច......................៤០

◆អង្គជំនុំជម្រះសាលាដំបូងរកឃើញថា នួន ជា..................................៤៤

**វេទិកាពិភាក្សាសាធារណៈ**

◆សំណុំរឿងប្រាសាទព្រះវិហារ : កម្ពុជា និង ថៃ..............................៤៦

◆មហិច្ឆតាប្រព្រឹត្តអំពើហិង្សាក្នុងប្រទេសបង់ក្លាដេស...........................៥០

◆តើទ្រព្យសម្បត្តិរបស់អតីតមេដឹកនាំខ្មែរក្រហម................................៥២

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆បងប្រុសខ្ញុំ ហៃ សំអុល..........................................................៥៥

◆ ទណ្ឌិតផ្ទៃល្ពៅ......................................................................៥៧




អ្នករាំរបាំ ជុំវ៉ាន់ សុដាជីវី សម្ភាសន៍ជាមួយអតីតនាដកា នៅភូមិកោះកែរ ឃុំស្រយ៉ង់ ស្រុកគូលេន ខេត្តព្រះវិហារ


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម.៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ :** ឆាយ ដាវីន, ម៉ម សុវណ្ណ, គ្រេកហ្គោរី ប្រូកណូវ, អាន ហាញឧល, រ៉េនឧល ឌីហ្វាល់កូ, ដូរៀន វិកឆឹត, សូហ្វាណា លីនតុន, ជីរ៉ល គ្រេ, បន ឆរងីអារី, ឆាយ សុឆាត **អ្នកនិពន្ធនិងស្រាវជ្រាវ :** ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា **អ្នកបកប្រែ :** នង ច័ន្ទមល្លិកា, ភួង ច័ន្ទប្រណិត **និពន្ធនាយកទូទៅ :** ឆាំង យុ និង ញាណ សុជាតិ **ជំនួយការនិពន្ធនាយក :** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ :** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ :** ឆេង វើង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# កម្មសិទ្ធិប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជា

ការសម្រេចចិត្តរបស់សារមន្ទីរសិល្បៈមេត្រូប៉ូលីតែន ដែលជាសារមន្ទីរធំបំផុតមួយនៅសហរដ្ឋអាមេរិក ក្នុងការប្រគល់រូបចម្លាក់ថ្មពីរនៃសតវត្សរ៍ទី១០មកឲ្យព្រះរាជាណាចក្រកម្ពុជាគឺជាពេលវេលាដ៏សំខាន់ខណៈដែលប្រទេសកម្ពុជាបន្តការពុះពាររបស់ខ្លួនក្នុងការទាមទារបេតិកភណ្ឌវប្បធម៌ត្រឡប់មកវិញ ។

រូបចម្លាក់ដែលត្រូវបានហៅថាជា "បនទេវៈលុតជង្គង់" ឬ "អ្នកបំរើលុតជង្គង់" គឺជារូបចម្លាក់ថ្ម ដែលមានទំហំស្មើរូបមនុស្សពិត ដែលបានយាមនៅទ្វារសារមន្ទីរផ្នែកសិល្បៈអាស៊ីអាគ្នេយ៍នៃសារមន្ទីរមេត្រូប៉ូលីតែនចាប់តាំងពីឆ្នាំ១៩៩៤មកម៉្លេះ ។ រូបចម្លាក់ទាំងនេះត្រូវបានយកចេញដោយខុសច្បាប់ពីតំបន់កោះកែរអំឡុងទសវត្សរ៍៧០ ហើយសារមន្ទីរនេះបានសម្រេចប្រគល់រូបចម្លាក់នេះត្រឡប់មកប្រទេសកម្ពុជាវិញបន្ទាប់ពីការស៊ើបអង្កេត និងការពិភាក្សាជាមួយនឹងខុទ្ទកាល័យរបស់ទីស្តីការគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ ដូចទៅនឹងការលើកឡើងរបស់នាយកគ្រប់គ្រងសារមន្ទីរមេត្រូប៉ូលីតែនដែលមានប្រសាសន៍ថា "សារមន្ទីរបានប្តេជ្ញាក្នុងការអនុវត្តបទដ្ឋានពីខាងដើមយ៉ាងហ្មត់ចត់មិនត្រឹមតែចំពោះរូបចម្លាក់ដែលទទួលបានថ្មីនេះទេ ថែមទាំងចំពោះការសិក្សាអំពីសមុច្ច័យផ្សេងៗរបស់ខ្លួនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីសិក្សាឲ្យបានឆាប់រហ័សលើភាពជាកម្មសិទ្ធិនៃវត្ថុបុរាណប្រវត្តិសាស្ត្រ ។

សេចក្តីសម្រេចរបស់សារមន្ទីរមេត្រូប៉ូលីតែនមានសារៈសំខាន់ដោយសារសេចក្តីសម្រេចនេះបង្កើតបានជាគំរូវិជ្ជមានសម្រាប់សហគមន៍ទូទាំងពិភពលោក ដែលខ្លួនទទួលបានសម្បត្តិវប្បធម៌មកថែរក្សារួចមកហើយនោះ ។ ក្រោមបទដ្ឋានអន្តរជាតិនាពេលបច្ចុប្បន្ន សារមន្ទីជាច្រើននឹងធ្វើការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីចងក្រងប្រវត្តិនៃសម្បត្តិវប្បធម៌ទាំងនោះ មុនពេលខ្លួនទទួលយកមកថែរក្សា ។ ទោះបីជាយ៉ាងណាក៏ដោយ ទាក់ទងទៅនឹងវត្ថុបុរាណដែលទទួលយកមកថែរក្សារួចមកហើយនោះហាក់បីដូចជាមិនសូវមានការខ្នះខ្នែងក្នុងការទទួលខុសត្រូវលើការងារថែរក្សា ដែលនេះធ្វើឲ្យការសម្រេចចិត្តរបស់សារមន្ទីរមេត្រូប៉ូលីតែន ក្លាយជាជំហានដ៏សំខាន់ក្នុងការប្រគល់ត្រឡប់មកវិញនូវទ្រព្យសម្បត្តិវប្បធម៌ដែលទទួលបានដោយខុសច្បាប់ ។


ទីតាំងដែលរូបបនទេវៈលត់ជង្គង់ត្រូវបានកាត់ចេញពីជើងទម្រ នៅប្រាសាទចិន តំបន់កោះកែរកាលពីទសវត្សរ៍៧០


រូបបនទេវៈលត់ជង្គង់ដែលបានមកដល់មាតុភូមិកំណើតវិញនៅល្ងាចថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣

ប៉ុន្តែក្រៅពីការសម្រេចចិត្តនេះ ដែលជះឥទ្ធិពលដល់គោលនយោបាយរបស់សារមន្ទីរផ្សេងៗជាច្រើន ការប្រគល់រូបចម្លាក់ទាំងនេះត្រឡប់មកវិញ មានសារៈសំខាន់ក្នុងការទាញចំណាប់អារម្មណ៍ដល់ការពុះពាររបស់ប្រជាជនកម្ពុជាក្នុងការផ្សះផ្សាជាមួយនឹងអតីតកាលដ៏រីករវររបស់ខ្លួន ។

ប្រទេសកម្ពុជាបានជួបប្រទះសង្គ្រាមខក្រិដ្ឋកម្មរំលោភសិទ្ធិ

មនុស្សធ្ងន់ធ្ងរ អំពើប្រល័យពូជសាសន៍ និងការបះបោរក្នុងសង្គមជាច្រើនសតវត្សរ៍ ដែលបានជះឥទ្ធិពលបំផ្លាញដល់អត្តសញ្ញាណ និងបេតិកភណ្ឌជាតិរបស់កម្ពុជា ។ វត្ថុបុរាណដែលមិនអាចកាត់ថ្លៃបានជាច្រើនត្រូវបានយកចេញពីប្រទេស ហើយត្រូវបានលក់ទៅឲ្យឈ្មួញបរទេស ហើយទន្ទឹមពេលដែលសង្គ្រាម ឧក្រិដ្ឋកម្មរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ អំពើប្រល័យពូជសាសន៍ និងការបះបោរនៅក្នុងសង្គមបានរលាយសាបសូន្យឥទ្ធិពលនៃអតីតកាលដ៏រឹកវរមកលើបេតិកភណ្ឌរបស់ប្រទេសនៅតែមានរហូតដល់ពេលសព្វថ្ងៃ ។

ប្រទេសកម្ពុជាគឺជាទឹកដីនៃសោភ័ណភាពដ៏មិនគួរឲ្យជឿ និងជាទឹកដីប្រវត្តិសាស្ត្រ ។ ប្រាសាទ វិហារឥស្លាម រូបចម្លាក់ និងស្នាដៃសិល្បៈនៃសោភ័ណភាពដ៏ល្បីល្បាញបានគ្របដណ្តប់ពេញផ្ទៃប្រទេសកម្ពុជា ។ ភាពនៅឆ្ងាយដាច់ស្រយាលនៃវត្ថុសិល្បៈទាំងនោះ បានបំពេញបន្ថែមដល់សោភ័ណភាពរបស់វា ប៉ុន្តែភាពនៅឆ្ងាយដាច់ស្រយាលនេះក៏បានផ្តល់នូវឱកាសដល់ការលួចប្លន់ ។ ភាពក្រីក្រ និងកង្វះខាតការយល់ដឹងក្នុងចំណោមប្រជាជនសាមញ្ញបានបង្កើនហានិភ័យនៃការលួចប្លន់ ឬការយកដោយខុសច្បាប់នូវរតនសម្បត្តិដែលមិនអាចកាត់ថ្លៃបាន ។ ទន្ទឹមពេលដែលការកើនឡើងការពង្រឹងច្បាប់ និងការកាន់តែយល់ដឹងរបស់អង្គការ និងរដ្ឋាភិបាលបរទេសបានជួយទប់ស្កាត់ដល់លំហូរនៃបេតិកភណ្ឌជាតិនៅមានតម្រូវការក្នុងការស្តារឡើងវិញនូវសម្បត្តិវប្បធម៌ដែលគេទទួលបានដោយខុសច្បាប់ពីអតីតកាល ។

ក្នុងសំណុំរឿងដែលមិនទាន់យកមកជំនុំជម្រះនៅចំពោះមុខតុលាការសហព័ន្ធក្នុងទីក្រុងញូយ៉កៈ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានខិតខំស្វែងរកឲ្យមានការប្រគល់ត្រឡប់មកវិញនូវរូបចម្លាក់ថ្មអ្នកចម្បាំង ក្នុងរឿងទេវកថាបែបហិណ្ឌូដែលស្គាល់ថាជាឌូរីយោធន ។ រូបចម្លាក់នេះមានប្រភពមកពីតំបន់កោះកែរ ក្នុងប្រទេសកម្ពុជា ហើយរូបចម្លាក់នេះគឺជាកាបង្ហាញអំពីអ្នកប្រឆាំងក្នុងរឿងព្រេងមហាភារតៈ ដែលជាសង្គ្រាមមួយដែលត្រូវបានពិពណ៌នានៅក្នុងគម្ពីរសាសនា ។ ព្រះរាជអាជ្ញានៅក្នុងសំណុំរឿងនេះ ចោទប្រកាន់ថាកន្លែងដេញថ្លៃ សូធ័របី បានផ្តល់ព័ត៌មានមិនពិតប្រាកដអំពីដើមកំណើតនៃរូបចម្លាក់នេះ ក្នុងហេតុផលដើម្បីលក់ចេញនូវវត្ថុដ៏អស្ចារ្យនេះ ។

ទន្ទឹមពេលដែលសំណុំរឿងនេះមានសារសំខាន់ដល់ការកសាងរឿងពិតអំពីប្រវត្តិនៃរូបចម្លាក់ឌូរីយោធននេះ សំណុំរឿងនេះគឺជាឧទាហរណ៍មួយផ្សេងទៀតនៃការតស៊ូដ៏លំបាកដែលប្រទេសកម្ពុជាត្រូវតែធ្វើដើម្បីទាមទារយកមកវិញនូវបេតិកភណ្ឌរបស់ខ្លួន និងទាញហេតុផលកាន់តែច្រើនជាងមុន ដើម្បីជំរុញឲ្យអង្គភាពរដ្ឋាភិបាល និងឈ្មួញទិញវត្ថុបុរាណឲ្យមានការទទួលខុសត្រូវនិងយកចិត្តទុកដាក់កាន់តែខ្លាំងជាងមុន ទាក់ទងទៅនឹងការថែរក្សានិងការស្តារបេតិកភណ្ឌវប្បធម៌របស់ប្រទេសកម្ពុជា ។

ឆាំង យុ


ប្រាសាទចិន ដែលរូបបនទេវៈលុតជង្គង់ត្រូវបានយកចេញកាលពីជំនាន់សង្គ្រាមស៊ីវិលក្នុងទសវត្សរ៍៧០

# ហៃ សំអុល រៀបរាប់ពីសកម្មភាពក្បត់បដិវត្តន៍ ជាមួយព្រះអង្គម្ចាស់ នរោត្តម នរតិប៉ោ

**(ឯកសារចម្លើយសារភាព J00៣២៤)**

ហៃ សំអុល ត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកមន្ទីរសន្តិសុខស្រុកកងមាសក្នុងខែធ្នូ ឆ្នាំ១៩៧៦ ពីបទធ្វើសកម្មភាពក្បត់បដិវត្តន៍ខ្មែរក្រហមជាមួយព្រះអង្គម្ចាស់ នរោត្តម នរតិប៉ោ ដោយបានរៀបចំគម្រោងដើម្បីវាយដណ្តើមទីក្រុងភ្នំពេញពីខ្មែរក្រហម ។ នៅក្នុងកំណត់ហេតុនិងចម្លើយរបស់ ហៃ សំអុល ដែលរៀបរៀងដោយគណៈសន្តិសុខស្រុកកងមាស តំបន់៤១ ភូមិភាគឧត្តរ បានសរសេរថា ហៃ សំអុល អាយុ៣១ឆ្នាំ មានស្រុកកំណើតនៅភូមិកណ្តឹង ស្រុកបាទី ខេត្តតាកែវ ។ ឪពុកឈ្មោះ ហៃ ម្តាយឈ្មោះ ឃីម ធ្លាប់ប្រកបរបររកស៊ីចិញ្ចឹមគោឲ្យជនជាតិអារ៉ាប់ ។ សំអុល មានប្រពន្ធឈ្មោះ សែ គីម និងមានបងប្អូនប្រាំពីរនាក់ (ស្រីបីនាក់ និងប្រុសបួននាក់) ។ បងប្រុសទីមួយឈ្មោះ ផល ប្រពន្ធឈ្មោះ រិន របររកស៊ីឡើងត្នោតនៅកំពង់កន្ទួត ។ បងទីពីរឈ្មោះ ឈួន ភេទប្រុស ប្រពន្ធឈ្មោះ មិ ធ្វើចម្ការនៅក្រឡាញ់ ខេត្តសៀមរាប ។ បងទីបីឈ្មោះ លី ភេទស្រី ប្តីឈ្មោះ សឿន របររកស៊ីប៉ាវកាប់ព្រៃគប់នៅបាត់ដំបង ។ បងទីបួនឈ្មោះ លួត ភេទស្រី ប្តីឈ្មោះ ជុំ របរធ្វើម៉ាស៊ីនឡាន និងប្អូនប្រុសស្រីពីរនាក់ទៀតឈ្មោះ អ៊ែល និង សាន រស់នៅក្នុងបន្ទុកឪពុកម្តាយ ។

សំអុល ជាអ្នកបើកឡានថ្វាយព្រះអង្គម្ចាស់ នរតិប៉ោ តាំងពីរបបសង្គមរាស្ត្រនិយមរហូតដល់ឆ្នាំ១៩៧២ ។ សំអុល បានរៀបរាប់ពីសកម្មភាពនិងទំនាក់ទំនងជាមួយព្រះអង្គម្ចាស់ នរតិប៉ោ ថា នៅឆ្នាំ ១៩៧២ រដ្ឋការ លន់ នល់ បានចាប់គាត់និងព្រះអង្គម្ចាស់ នរតិប៉ោ ដាក់គុក ។ នៅឆ្នាំ១៩៧៤ ទើបអ្នកទាំងពីបានរួចខ្លួនពីគុក និងរស់នៅទីក្រុងភ្នំពេញរហូតដល់ខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជានៅខែមេសា ឆ្នាំ១៩៧៥ ។ សំអុល បានបន្តថា មុនបែកទីក្រុងភ្នំពេញ ព្រះអង្គម្ចាស់ នរតិប៉ោ បាននិយាយប្រាប់រឿងរ៉ាវប្រទេសជាតិនិងផែនការមួយចំនួនក្នុងការវាយរំដោះនៅទូទាំងប្រទេស ។

ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ព្រះអង្គម្ចាស់ នរតិប៉ោ និងព្រះបិតាព្រះអង្គ (សម្តេចនរោត្តម សីហនុ) បានរៀបចំកម្លាំងជាបីក្រុម ។ ទីមួយគឺ បក្សស មានឈ្មោះថា "កងទ័ពសេរីការពារជាតិ ក្នុងកិច្ចប្រតិបត្តិការសាមគ្គីជាតិ" ដែលគ្រប់គ្រងដោយព្រះអង្គម្ចាស់ ភូរិស្សរ៉ា និងមានបក្ស អាស៊ាន ដែលមានសមាជិកប្រាំពីរប្រទេសចេញមុខជួយដោយមានការស៊ីញ៉េលួចលាក់នៅទីក្រុងបាងកក ។ ព្រះអង្គម្ចាស់ នរតិប៉ោ បានលបលួចចេញទៅចុះហត្ថលេខានៅទីក្រុងបាងកក ដោយជិះយន្តហោះចេញពីក្នុងបរិវេណផ្ទះរបស់សម្តេច សឺន សាន ។ កម្លាំងទីពីរមានព្រះអង្គម្ចាស់ នរោត្តម ច័ន្ទរង្សី ជាប្រធាន, ថាច់ រ៉េន និង ថាច់ លីវង់ ជាសមាជិក ។ ព្រះអង្គម្ចាស់ ច័ន្ទរង្សី ជាអ្នកដឹកនាំ ដោយធានាថានឹងវាយដណ្តើមកាន់កាប់ទីក្រុងភ្នំពេញពីខ្មែរក្រហមវិញ ។ កម្លាំងទីបី គឺជាកម្លាំងចោរព្រៃ ដែលមាន អ៊ិន តាំ ជាមេដឹកនាំនៅខេត្តកំពង់ចាម ។ ផ្នែកចលនាបំផុសបំផុលមានអ្នកចូលរួមឈ្មោះ វី សុវណ្ណ, សឿន, និង សរិត ថៃ ។ ក្រុមនេះធ្លាប់ប៉ុនប៉ងបាញ់សម្លាប់នាយករដ្ឋមន្ត្រី ប៉ុល ពត តែត្រូវបញ្ឈប់ទៅវិញដោយសារនៅក្នុងឡាននោះពុំឃើញមានវត្តមាន ប៉ុល ពត ។

ក្រោយពីត្រូវខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញមកដល់ភូមិអង្គរបាន ស្រុកកងមាស ខេត្តកំពង់ចាម ព្រះអង្គម្ចាស់ នរតិប៉ោ បានមានបន្ទូលប្រាប់ សំអុល ទៀតថា ព្រះបិតារបស់ព្រះអង្គ (សម្តេចនរោត្តម សីហនុ) សុំលាឈប់ពីតំណែង ពីព្រោះថាបើកាលណាផែនការបានជោគជ័យគឺព្រះអង្គនឹងលែងមានជាប់ពាក់ព័ន្ធជាមួយពួកខ្មែរក្រហមទៀត ។ បន្ទាប់មក សំអុល ត្រូវ

ត្រឡប់មករស់នៅក្នុង ភូមិសូរគង (ភូមិសូរគងស្ថិតនៅក្នុងស្រុកកងមាសដែរ) ។ នៅទីនោះមានបុរសម្នាក់ឈ្មោះ សឿន ដែលទទួលខុសត្រូវខាងចោរព្រៃ ហើយជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឈ្មោះ រី សុវណ្ណ បានបបួល សំអុល ឲ្យចូលរួមចលនាតស៊ូរំដោះប្រទេសជាតិឲ្យផុតពីពួកខ្មែរក្រហម និងចក្រពត្តិកុម្មុយនីស្តដោយនិយាយថា ព្រះអង្គម្ចាស់ នរតិបោ៉ា បានចូលរួមជាមួយពួកគេហើយ ។ ការងារនេះត្រូវបានបែងចែកជាបួនតំបន់គឺព្រៃឈរ កំពង់សៀម កងមាស និងព្រៃទទឹង ។

ព្រះអង្គម្ចាស់ នរតិបោ៉ា មានផែនការពីរលើកក្នុងការវាយរំលំពួកខ្មែរក្រហម ។ លើកទីមួយគឺនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៧ និងលើកទីពីរនៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៧៨ ។ គម្រោងការលើកទីមួយមានប្រាំមួយមុខព្រួញ ។ មុខព្រួញទីមួយមាន នរោត្តម ភូរិស្សរ៉ា វាយចេញពីឡាវ, មុខព្រួញទីពីមាន សឹង ង៉ុក ថាញ់ វាយចេញពីខាងភ្នំដិន ខេត្តតាកែវ, មុខព្រួញទីបីមាន សុស្តែន, ថាច់ ចាន់លីវង់, ថាច់ រីន "មេទ័ពកន្សែងស" វាយចេញពីសៀម មកកំពង់ស្ពឺ, មុខព្រួញទីបួនមាន ជ័យ ជយុមប៊ិន អតីតចៅហ្វាយខេត្តក្រចេះ វាយចេញពីលាវ, មុខព្រួញទីប្រាំមាន នរោត្តម ច័ន្ទរង្សី វាយចេញពីសៀម ហើយចូលកាន់កាប់ទីក្រុងភ្នំពេញមុនគេ, មុខព្រួញទីប្រាំមួយ អ៊ិន តាំ វាយចេញពីលាវ ។ មុខព្រួញទាំងប្រាំមួយនេះវាយមកចាប់ដៃគ្នានៅភ្នំពេញ ។ ចលនានេះបានចាត់តាំង នរោត្តម នរតិបោ៉ា ជាប្រធាននយោបាយក្នុងប្រទេស, នរោត្តម កន្តុល ជាអនុប្រធាននយោបាយក្នុងប្រទេស ។ នរោត្តម ជីវ័ន្តមុនីរក្ស ដែលជាបងថ្លៃ ចាន់ លីវង់ ជាសមាជិក ។ វណ្ណ មូលីវណ្ណ ទទួលខុសត្រូវខាងនយោបាយក្រៅប្រទេស ។ ផែនការវាយលើកទីពីនៅថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៧៨ មានប្រាំបីមុខព្រួញសញ្ញា ។ មុខព្រួញទីមួយមាន នរោត្តម ភូរិស្សរ៉ា វាយចេញពីឡាវ, មុខព្រួញទីពីរមាន សឹង ង៉ុកថាញ់ វាយចេញពីយួន, មុខព្រួញទីបីមាន សុស្តែន វាយចេញពីសៀម, មុខព្រួញទីបួនមាន ជ័យ ជយុមប៊ិន វាយចេញពីលាវ, មុខព្រួញទីប្រាំមាន នរោត្តម ច័ន្ទរង្សី វាយចេញពីសៀម, មុខព្រួញទីប្រាំមួយ អ៊ិន តាំ វាយចេញពីលាវ, មុខព្រួញទីប្រាំពីរ នរោត្តម រណឫទ្ធិ វាយចេញពីយួន, មុខព្រួញទីប្រាំបីមាន នរោត្តម វិរិយ៉ា វាយចេញពីយួន ។ នៅក្នុងផែនការលើកទីពីនេះ ដោតទង់ជ័យសាសនាពីរដើម តែប្តូរបង្គង់ខាងលើដាក់ពណ៌សជាសញ្ញាសន្តិភាព ដោយចាត់តាំងនរោត្តម នរតិបោ៉ា ជាប្រធាននយោបាយផ្ទៃក្នុងប្រទេស, សម្តេចក្រុមព្រះ បូនមហាក្សត្រីយានីជាអនុប្រធាន, នរោត្តម កន្តុល និង យិន មិ ជន្ទង លន់ នល់ ពាក់ស័ក្តិ៤ ដែលបង្កប់ខ្លួននៅអំពិលហ៊ីហា និងមានកូន លន់ នល់ រស់នៅជាមួយ ។ សម្តេច សឺន សាន ទទួលខុសត្រូវខាងនយោបាយក្រៅប្រទេស និងសមាជិកផ្សេងៗទៀតដែលចូលរួមជាគណៈប្រតិភូចូលកាន់កាប់ប្រទេស ។

ជាចុងក្រោយ សំអុល បានបញ្ជាក់ថា ចំពោះផែនការទាំងពីរលើកនេះ គឺមានខ្សែចាត់តាំងបង្កប់ខ្លួននៅខាងក្នុងខ្លះដែរ ។ សំអុល បានដឹងរឿងនេះតាមរយៈព្រះអង្គម្ចាស់ នរតិបោ៉ា ក្នុងចំណោមវរជន៣៧៨នាក់ មាននារី៥៨រូប ។ ព្រះអង្គម្ចាស់ នរតិបោ៉ា មានបន្ទូលប្រាប់ សំអុល ថា ចំពោះសកម្មភាព នារីមានឈ្មោះ លីហ្សា ជាក្មួយ សិរិ មតៈ មានប្តីឈ្មោះ ស្រេង ទទួលបន្ទុកនៅកំពង់សៀម ព្រៃឈរ ។ ឈ្មោះ សារាយ សួង ទទួលខុសត្រូវខាងកំពង់ធំ តែត្រូវឲ្យសោកស្តាយខ្មែរក្រហមបានចាប់គាត់ ដូចនេះហើយត្រូវប្តូរឲ្យទៅឈ្មោះ ក្រឹង ហាន ដែលជាអតីតចាងហ្វាងគុកកំពង់ធំ ។ ឈ្មោះ សារឿន ទទួលខុសត្រូវខេត្តពោធិ៍សាត់ ។ ឈ្មោះ គាម នៅក្រសួងនេសាទព្រៃឈរ ឈ្មោះនេះបានទាក់ទងជាមួយណាត្រី ហើយធ្លាប់យកឥវ៉ាន់ឲ្យព្រះអង្គម្ចាស់ នរតិបោ៉ា នៅអង្គរបានស្រុកកងមាស ។ ឈ្មោះ យិន មិ មានកូនឈ្មោះ យិន ប្រសុង ទទួលខុសត្រូវនៅព្រៃឈរដែលជាខ្សែសំខាន់នៅភូមិអំពិលហ៊ីហា ហើយ យិន មិ នេះជាប់ជាជន្ទង លន់ នល់ និងជាសមាជិកផ្ទៃក្នុងជាមួយព្រះអង្គម្ចាស់ នរតិបោ៉ា ។

**ឆាយ ជាទីន**

◆ **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**

◆ **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# បញ្ជីឈ្មោះនិងរូបថតអ្នកទោសមន្ទីរស-២១ដែល ទទួលបាននៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២

**អ្នកកត់ត្រា ៖ ឆាំង យុ, ញាណ សុជាតិ និង ស៊ីរ៉ិ សាវីណា**

**(តពីលេខមុន)**

| ល.រ | ឈ្មោះ | ភេទ | លេខរូបថត | រឿងរ៉ាវទាក់ទងនឹងប្រវត្តិរូបសង្ខេប |
|---|---|---|---|---|
| ៦៥៧ | សួស រ៉ា | ប្រុស | ២៦១ | ១២.៦.៧៨ |
| ៦៥៨ | អ៊ុម គិន | ប្រុស | ២៦ | ១.៤.៧៨ |
| ៦៥៩ | សំ យាង | ប្រុស | ៧០៧ | ២៩.៦.៧៨ |
| ៦៦០ | ស ឆន | ប្រុស | ៧៩៩ | --.៧៨ |
| ៦៦១ | ស្តើង ស៊ាត | ប្រុស | ៣៩៦ | ២១.៦.៧៨ |
| ៦៦២ | សាច សម | ប្រុស | ៥៩៣ | ៣០.៣.៧៨ |
| ៦៦៣ | ម៉ម ព្រឹម | ប្រុស | ៣៦០ | ២០.៦.៧៨ |
| ៦៦៤ | ស៊ី ស៊ា | ប្រុស | ៣៥៨ | ២០.៦.៧៨ |
| ៦៦៥ | ខៀវ សុក | ប្រុស | ៣៥៩ | ២១.៦.៧៨ |
| ៦៦៦ | អៀម ហ៊ី | ប្រុស | ៤៨១ | ១១.៤.៧៨ |
| ៦៦៧ | ម៉ុម ម៉ាច- សារ៉ាត | ប្រុស | ៥៩០ | ៣០.៣.៧៨ |
| ៦៦៨ | រ៉ា សុភាព | ប្រុស | ៥៩០ | ៣០.៣.៧៨ |
| ៦៦៩ | ឡុង មុច | ប្រុស | ២៥០ | ១១.៦.៧៨ |
| ៦៧០ | សៅ សយ | ប្រុស | ២៥១ | ១១.៦.៧៨ |
| ៦៧១ | មន ឡេ | ប្រុស | ២៥២ | ១១.៦.៧៨ |
| ៦៧២ | ប្រាក់ ផេន-ជា | ប្រុស | ៥៩៥ | ៣០.៣.៧៨ |
| ៦៧៣ | សុក អាត | ប្រុស | ៥៧០ | ២៣.៨.៧៨ |
| ៦៧៤ | គោ ស៊ីវន-ម៉ាច | ប្រុស | ៤០១ | ២២.៣.៧៨ |
| ៦៧៥ | សូ ផន | ប្រុស | ៥៥០ | ២៣.៦.៧៨ |
| ៦៧៦ | ឃ្លោក ផល្លី | ប្រុស | ៧៤ | ៨.៧.៧៨ |
| ៦៧៧ | អួន ឡុន | ប្រុស | ១២២ | ៧.៦.៧៨ |
| ៦៧៨ | ឈិត អឿន-រឿន | ប្រុស | ៣៦៤ | ១.៣.៧៨ |
| ៦៧៩ | ឃឹម ហាងកាង | ប្រុស | ២៥៨ | ១២.៦.៧៨ |
| ៦៨០ | ឃិន ថេង | ប្រុស | ២៥៣ | ១១.៦.៧៨ |

| | | | | |
|---|---|---|---|---|
| ៦៨១ | សេច ខ្វែក | ប្រុស | ១២២ | ១២.៣.៧៨ |
| ៦៨២ | ធាង ធុរផសា | ប្រុស | ៤២៣ | ២៣.៣.៧៨ |
| ៦៨៣ | សូ ណាន | ស្រី | ៨១៣ | ២២.៤.៧៨ |
| ៦៨៤ | លូ សាផ | ស្រី | ៦១៤ | ១៤.៤.៧៨ |
| ៦៨៥ | មាក សន | ប្រុស | ៨១២ | ២២.៤.៧៨ |
| ៦៨៦ | សូ យេ | ប្រុស | ៨១១ | ២២.៤.៧៨ |
| ៦៨៧ | កូវ វណ្ណា | ប្រុស | ៨១០ | ២២.៤.៧៨ |
| ៦៨៨ | មន ឡេ | ប្រុស | ២៥២ | ១១.៦.៧៨ |
| ៦៨៩ | គង ចិនលិន-អុន | ប្រុស | ៤១៤ | ២៣.៣.៧៨ |
| ៦៩០ | ឈឹម ឆន | ប្រុស | ៤១៩ | ២៣.៣.៧៨ |
| ៦៩១ | យោ លឹម | ប្រុស | ៤២០ | ២៣.៣.៧៨ |
| ៦៩២ | នួន សារិទ្ធ-សារ | ប្រុស | ៤១៧ | ២៣.៣.៧៨ |
| ៦៩៣ | សុក នឿន-សារឿន | ប្រុស | ៤១៨ | ២៣.៣.៧៨ |
| ៦៩៤ | លឹម បូ | ប្រុស | ៤១៥ | ២៣.៣.៧៨ |
| ៦៩៥ | ពា ហេង | ប្រុស | ៤១៦ | ២៣.៣.៧៨ |
| ៦៩៦ | ឌី អន | ប្រុស | ៥៧២ | ៣០.៣.៧៨ |
| ៦៩៧ | ស៊ូ សុកដួន | ប្រុស | ៥៧៣ | ៣០.៣.៧៨ |
| ៦៩៨ | តុក ឆេងហួត | ប្រុស | ៥៧៣ | ៣០.៣.៧៨ |
| ៦៩៩ | មាស ផន-ប៉ា | ប្រុស | ៥៧៤ | ៣០.៣.៧៨ |
| ៧០០ | ហោ សេងម៉ៅ | ប្រុស | ៥៧៥ | ៣០.៣.៧៨ |
| ៧០១ | ជិន ដេង | ប្រុស | ៦៣៣ | ២៨.៦.៧៨ |
| ៧០២ | ដោក យឿនហាន | ប្រុស | ២ | ១.៤.៧៨ |
| ៧០៣ | រស់ សំអឿន | ប្រុស | ៣៧៤ | ២១.៦.៧៨ |
| ៧០៤ | យ៉ យ៉ាំងរួម | ប្រុស | ? | ១៤.៣.៧៨ (ប្រហែលជាវៀតណាម) |
| ៧០៥ | ញឹម មុត | ប្រុស | ២៧៤ | ១៣.៦.៧៨ |
| ៧០៦ | ហួន អុំ | ប្រុស | ២៧៥ | ១៣.៦.៧៨ |
| ៧០៧ | ម៉ម ឆែម | ប្រុស | ១៦៦ | ៧.៦.៧៨ |
| ៧០៨ | លន់ សារ៉ែម | ប្រុស | ៣៤៥ | ១៩.៦.៧៨ |
| ៧០៩ | ប្រាក់ ឡេះ | ប្រុស | ៧០៩ | ២៩.៦.៧៨ |
| ៧១០ | ឃ្មោក ដល្លី | ប្រុស | ៧៤ | ៨.៧.៧៨ |
| ៧១១ | យង ស៊ីវឡាយ | ប្រុស | ២៥៦ | ១២.៦.៧៨ |
| ៧១២ | វ៉ាម វ៉ៃ | ប្រុស | ៥៦៤ | ២៣.៦.៧៨ |

| | | | | | |
|---|---|---|---|---|---|
| ៧១៣ | ដឹង បាន | ប្រុស | ២២ | ៤.៣.៧៨ | |
| ៧១៤ | ឌឹម អឿន | ប្រុស | ៥៦៣ | ២៣.៦.៧៨ | |
| ៧១៥ | ប៉ែន វិនភាព | ស្រី | ៧៦ | ៨.៣.៧៨ | |
| ៧១៦ | មាឃ សីមផុន | ស្រី | ៧៣ | ៨.៣.៧៨ | |
| ៧១៧ | គិម ឈៀង | ប្រុស | ៦៨ | ៨.៣.៧៨ | |
| ៧១៨ | ខ្លែប រឿ-រឿម | ស្រី | ៧៤ | ៨.៣.៧៨ | |
| ៧១៩ | ដា នៅ | ប្រុស | ៣៦ | ១.៤.៧៨ | |
| ៧២០ | ធុច ថេត | ប្រុស | ៣៨ | ១.៤.៧៨ | |
| ៧២១ | ឈឹម ស្រេង-សឿន | ប្រុស | ១២៤ | ៧.៦.៧៨ | |
| ៧២២ | សេក ហឿន | ប្រុស | ១៩ | ១.៤.៧៨ | |
| ៧២៣ | គង់ ពែក | ប្រុស | ១៦៩ | ៧.៦.៧៨ | |
| ៧២៤ | ឃិន ឌុលរ៉េ | ប្រុស | ១៧៨ | ៧.៦.៧៨ | |
| ៧២៥ | យូ រាប | ប្រុស | ៧១១ | ២៩.៦.៧៨ | |
| ៧២៦ | ឡាយ ហាយ | ស្រី | ៣២៩ | ២០.៣.៧៨ | |
| ៧២៧ | រដ្ឋ សន | ប្រុស | ២៣៧ | ១១.៦.៧៨ | |
| ៧២៨ | ថាប់ សឿន | ប្រុស | ៣៨១ | ២១.៦.៧៨ | |
| ៧២៩ | រៀលសុំ សាមឿន | ប្រុស | ៧១០ | ១៩.៤.៧៨ | |
| ៧៣០ | ប៊ុន បូរ | ប្រុស | ៣៨០ | ២១.៦.៧៨ | |
| ៧៣១ | ទូច វុទ្ធា | ប្រុស | ៣៧៩ | ២១.៦.៧៨ | |
| ៧៣២ | ឃុត គុត | ប្រុស | ៣៦៩ | ២១.៦.៧៨ | |
| ៧៣៣ | ដុត ឈិត | ប្រុស | ៤៨០ | ២១.៦.៧៨ | |
| ៧៣៤ | ពុត សាម៉ន | ប្រុស | ៤៧៩ | ២១.៦.៧៨ | |
| ៧៣៥ | ង្វៀង យ៉ាំងផ្លូន | ប្រុស | ៧ | ១.៥.៧៨ | (វៀតណាម) |
| ៧៣៦ | ឈឹម ហ៊ាម | ប្រុស | ៤៨២ | ២១.៦.៧៨ | |
| ៧៣៧ | ម៉ង់ ផន | ប្រុស | ៤៨១ | ២១.៦.៧៨ | |
| ៧៣៨ | ឆ្លូ យ៉ុង | ប្រុស | ៥៨១ | ២៣.៦.៧៨ | |
| ៧៣៩ | ប្រុក យាន | ប្រុស | ៣៣៣ | ១៩.៦.៧៨ | |
| ៧៤០ | ផ្លូន ហៃ | ប្រុស | ៥៨៤ | ២៣.៦.៧៨ | |
| ៧៤១ | ឃិម រឿន | ប្រុស | ៥៨៥ | ២៣.៦.៧៨ | |
| ៧៤២ | ដុំ សុន | ប្រុស | ១៥០ | ៧.៦.៧៨ | |
| ៧៤៣ | ទេព អ៊ឹម | ប្រុស | ៦៥៧ | ២៨.៦.៧៨ | |
| ៧៤៤ | សុក ផាន | ប្រុស | ៥៤៨ | ២៣.៦.៧៨ | |

| | | | | |
|---|---|---|---|---|
| ៧៤៥ | ប៉ុត ឌីម៉ន | ប្រុស | ៤០៥ | ២១.៦.៧៨ |
| ៧៤៦ | ភិន ពើច | ប្រុស | ៣៨២ | ២១.៦.៧៨ |
| ៧៤៧ | ស៊ាម ឆាយ | ប្រុស | ៣៨៣ | ២១.៦.៧៨ |
| ៧៤៨ | មឿន ដឺនី | ប្រុស | ១៣៩ | ១៤.៣.៧៨ |
| ៧៤៩ | ញូង ញ៉ែន | ប្រុស | ៧១៥ | ២៩.៦.៧៨ |
| ៧៥០ | ដាង យ៉ាំងកែម | ប្រុស | ៤២ | ២៧.៩.៧៨ (វៀតណាម) |
| ៧៥១ | ចាន់ អូន | ប្រុស | ៧១៦ | ២៩.៦.៧៨ |
| ៧៥២ | ឌិញ យ៉ាំងលូវ | ប្រុស | ២៣ | ១៣.១១.៧៨ (វៀតណាម) |
| ៧៥៣ | អ៊ុង យ៉ឹម-យ៉ន | ស្រី | ២៥៥ | ១៧.៣.៧៨ |
| ៧៥៤ | ពុត សែម | ប្រុស | ២៥៤ | ១១.៦.៧៨ |
| ៧៥៥ | ម៉ី សាយភាព | ប្រុស | ៥៦០ | ១២.៤.៧៨ |
| ៧៥៦ | សុក យាង | ប្រុស | ២៣៤ | ១១.៦.៧៨ |
| ៧៥៧ | ទឹម ស៊ឹម | ប្រុស | ២៣៦ | ១១.៦.៧៨ |
| ៧៥៨ | សិត សុន | ប្រុស | ២៣៨ | ១១.៦.៧៨ |
| ៧៥៩ | កុយ ចុន | ប្រុស | ២៤៩ | ១១.៦.៧៨ |
| ៧៦០ | សោម ម៉ែន | ប្រុស | ២៤៨ | ១១.៦.៧៨ |
| ៧៦១ | ម៉ែន ម៉េង | ប្រុស | ២៤៧ | ១១.៦.៧៨ |
| ៧៦២ | ប៊ូច គង់ | ប្រុស | ២៤៦ | ១១.៦.៧៨ |
| ៧៦៣ | សេង សៀក | ប្រុស | ២៤៥ | ១១.៦.៧៨ |
| ៧៦៤ | គង់ ម៉ង់ | ប្រុស | ២៤៤ | ១១.៦.៧៨ |
| ៧៦៥ | ផៃ សាលី | ប្រុស | ២៣៩ | ១១.៦.៧៨ |
| ៧៦៦ | សូ ញ៉ិល | ប្រុស | ២៤០ | ១១.៦.៧៨ |
| ៧៦៧ | វេង ហួសំ | ប្រុស | ២៤១ | ១១.៨.៧៨ |
| ៧៦៨ | សុខ ម៉ុន | ប្រុស | ២៤២ | ១១.៦.៧៨ |
| ៧៦៩ | យូ ហុ | ប្រុស | ២៤៣ | ១១.៦.៧៨ |
| ៧៧០ | ឈិន អឿន វឿន | ប្រុស | ៣៦៤ | ១.៣.៧៨ |
| ៧៧១ | ឡាច ម៉ាង សារិម | ប្រុស | ៣៦២ | ១.៣.៧៨ |
| ៧៧២ | ម៉ី ដា | ប្រុស | ៣៦១ | ១.៣.៧៨ |
| ៧៧៣ | គោត អិប | ប្រុស | ៣៦០ | ១.៣.៧៨ |
| ៧៧៤ | ម៉ុំ សយ | ប្រុស | ៣៥៩ | ២៩.២.៧៨ |
| ៧៧៥ | សិម អូន | ប្រុស | ១១៧ | ១២.៣.៧៨ |
| ៧៧៦ | លន់ សារ៉ែម | ប្រុស | ៣៨៥ | ១៩.៦.៧៨ **(នៅមានគ)** |

# ការអប់រំរបស់ខ្មែរក្រហម : ការអប់រំកុមារឱ្យមានអំពើហិង្សា

## សេចក្តីផ្តើម

ឪពុកម្តាយមានឥទ្ធិពលតិចតួចណាស់ទៅលើកូនរបស់ខ្លួននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ចន្លោះឆ្នាំ១៩៧៥-១៩៧៩ ។ ខ្មែរក្រហមបានកាត់ផ្តាច់ចំណងគ្រួសារ កែប្រែសមាជិកគ្រួសារឲ្យប្រឈមមុខដាក់គ្នា និងធ្វើឲ្យកុមារលែងស្រលាញ់គ្រួសាររបស់ខ្លួនតាមរយៈការបំពាក់បំប៉នមនោគមវិជ្ជា ។ អត្ថបទស្រាវជ្រាវនេះផ្តោតទៅលើបញ្ហា និងផលប៉ះពាល់នៃការបំពាក់បំប៉នមនោគមវិជ្ជារបស់ខ្មែរក្រហម ។ ឯកសារនេះមានបំណងធ្វើការពិពណ៌នាអំពីមេរៀនសិក្សាដ៏សំខាន់នៃការបំពាក់បំប៉នមនោគមវិជ្ជាដល់កូនខ្មែររបស់ខ្មែរក្រហម ។ ដោយសារតែលក្ខណៈពិសេសនៃការសិក្សាស្រាវជ្រាវនេះ សំណួរខាងក្រោមត្រូវបានបង្កើតឡើងដើម្បីបង្ហាញអំពីដំណើរការនៃការស្រាវជ្រាវដូចជា តើកូនខ្មែរត្រូវបានបំពាក់បំប៉នមនោគមវិជ្ជាដោយខ្មែរក្រហមតាមរបៀបណា? ជាងនេះទៅទៀត តើកូនខ្មែរសិក្សាអំពីអ្វីនៅសម័យខ្មែរក្រហមដែលបណ្តាលឲ្យក្មេងៗទាំងនោះមានអំពើហិង្សា និងការស្អប់ខ្ពើម?

វិធីសាស្ត្រដែលប្រើសម្រាប់ទទួលបានទិន្នន័យដែលអាចជឿជាក់បាន និងមានតម្លៃសម្រាប់ការសិក្សាស្រាវជ្រាវនាពេលបច្ចុប្បន្ន គឺមានបីផ្នែក : ឯកសារដែលនៅសល់ពីរបបកម្ពុជាប្រជាធិបតេយ្យ ទស្សនាវដ្តីពីរក្នុងចំណោមទស្សនាវដ្តីបីដែលបោះពុម្ពដោយខ្មែរក្រហម គឺទស្សនាវដ្តី ទង់បដិវត្ត និង ទស្សនាវដ្តីយុវជនយុវនារីបដិវត្តន៍ និងតាមរយៈការសួរនាំអ្នករស់រានមានជីវិតដែលដឹងរឿងខ្មែរក្រហម ។ ឯកសារដែលខ្ញុំបាននិយាយគឺសំដៅលើឯកសារស្នាដៃរបស់ ដេវីដ ឆេនដល័រ, ប៉ែន ឃៀវនិន និង បន្ទូ ប៊ួ ។ អ្នកនិពន្ធទាំងបីនាក់បានបកប្រែឯកសាររបស់កម្ពុជាប្រជាធិបតេយ្យចំនួនប្រាំបី ពីភាសាខ្មែរទៅភាសាអង់គ្លេស ហើយបានបោះពុម្ពផ្សាយសៀវភៅមានចំណងជើងថា ប៉ុល ពត ធ្វើ



កុមារដែលជាកូនចៅរបស់កម្មាភិបាលខ្មែរក្រហមកំពុងរៀននៅក្នុងថ្នាក់ក្នុងរបបខ្មែរក្រហម ។

ផែនការអនាគត ៖ ឯកសារមេដឹកនាំសម្ងាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦-១៩៧៧ (Pol Pot Plans the Future: Confidential Leadership Documents from Democratic Kampuchea 1976-1977) ។ ឯកសារទាំងពីរដែលបានបកប្រែត្រូវបានធ្វើការពិគ្រោះយោបល់សម្រាប់ការប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនាពេលបច្ចុប្បន្ន ដោយសារឯកសារទាំងនោះទាក់ទងទៅនឹងការអប់រំ និងការបំពាក់បំប៉នមនោគមវិជ្ជាដល់កូនខ្មែរ ដូចជាផែនការបួនឆ្នាំរបស់បក្សដើម្បីកសាងសង្គមនិយមគ្រប់វិស័យ រវាងឆ្នាំ១៩៧៧-១៩៨០ និងការពន្យល់ជាបឋមមុនការអានផែនការដោយលេខាបក្ស ។ ប្រភពឯកសារទីពីររួមមាន ទស្សនាវដ្ដីបណ្ដាញផ្សព្វផ្សាយបរទេស ព្រឹត្តិបត្រ និងប្រភពឯកសារដែលអាចប្រើប្រាស់បាននៅលើប្រព័ន្ធអ៊ីនធឺណេត ។

ការសិក្សាស្រាវជ្រាវនេះ នឹងរួមចំណែកដ៏សំខាន់ដល់ទស្សនាវដ្ដីស្វែងរកការពិត និងការអានផ្សេងៗស្ដីពីនយោបាយមនោគមវិជ្ជា ការអប់រំថ្នាក់បឋម និងមធ្យមសិក្សា ដោយសារការបំពាក់បំប៉នមនោគមវិជ្ជាដល់កូនខ្មែរក្រោមរបបខ្មែរក្រហមត្រូវបានពន្យល់តិចតួចបំផុត ។ ដេវីដ អាយរ៉េស បានបញ្ចេញយោបល់ក្នុងសៀវភៅដែលបានបោះពុម្ពកាលពីឆ្នាំ២០០០មានចំណងជើងថា ប្រពៃណី ទំនើបកម្ម និងការអភិវឌ្ឍវិស័យអប់រំនៅប្រទេសកម្ពុជាថា «មានសៀវភៅសិក្សាស្រាវជ្រាវ ឬអត្ថបទមួយចំនួនដែលទាក់ទងទៅនឹងការបង្កើតគោលនយោបាយសង្គមរបស់ប្រទេសកម្ពុជា និងការដោះស្រាយបញ្ហាអប់រំធ្ងន់ធ្ងរមួយចំនួន» ។ ជាងនេះទៅទៀត ដេវីដ អាយរ៉េស បានលើកឡើងក្នុងសៀវភៅ ខ្មែរក្រហម និងការអប់រំ ៖ ក្រៅពីការនិយាយអំពីការបំផ្លាញថា «កិច្ចការត្រួតពិនិត្យមើលការអប់រំក្នុងប្រទេសកម្ពុជាក្នុងអំឡុងសម័យខ្មែរក្រហមពឹងផ្អែកយ៉ាងខ្លាំងលើកំណត់ហេតុរបស់កម្មាភិបាលជាន់ខ្ពស់ដែលសាធារណជនបានស្គាល់ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ» គោលនយោបាយត្រូវបានការពារក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយបានបន្សល់នូវឯកសារតិចតួចបំផុតស្ដីពីរបបនោះ លើកលែងតែសៀវភៅសិក្សាផ្នែកភូមិសាស្ត្រមួយក្បាល និងសៀវភៅគណិតវិទ្យាមួយក្បាលដែលលោក ថូម៉ាស ក្លេតុន បានអះអាងក្នុងសៀវភៅ កសាងកម្ពុជាថ្មី ៖ ការបំផ្លាញការអប់រំនិងការកសាងការអប់រំក្រោមសម័យខ្មែរក្រហមចន្លោះឆ្នាំ១៩៧៥-១៩៧៩ (Building the new Cambodia: Educational destruction and construction under the Khmer Rouge) ថា «មិនត្រូវបានយកមកបកស្រាយ និងស្ថិតក្នុងចំណោមបណ្ណសារដ្ឋានរបស់សារមន្ទីរទួលស្លែង» ។

## ការចម្រាញ់យុវជនខ្មែរឲ្យចូលជាសមាជិកបក្ស

ការប្រកាសជ្រើសរើសយុវជនមានសារសំខាន់ដល់ ប៉ុល ពត និងបក្សពួករបស់ខ្លួនដែលសិក្សានៅប្រទេសបារាំង ដើម្បីកសាងបដិវត្តន៍ ។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កម្មាភិបាលខ្មែរក្រហមត្រូវបាន ប៉ុល ពត ដាក់ផែនការឲ្យទៅបញ្ចុះបញ្ចូលយុវជននៅជនបទ និងទីប្រជុំជនក្រីក្រ ដែលនៅពាសពេញតាមជនបទរបស់ប្រទេសកម្ពុជា ។ មានយុវជនមួយចំនួនមានបំណងបំបាត់សង្គមចាស់ ដោយសារតែការអន់ចិត្តដែលខ្លួនមិនសូវមានតម្លៃក្នុងសង្គមនោះ ។ ការប្រកាសជ្រើសរើសយុវជនរបស់ ប៉ុល ពត បានធ្វើឡើងតាមរបៀបដូចគ្នាទៅនឹងយុទ្ធនាការរបស់ ម៉ៅ សេទុង បានបង្គាប់ឲ្យយុវជនចិនចូលរួមកងការពារក្រហម (Red Guards) ។ យុវជនដែលស្ម័គ្រស្មើរត្រូវបានកេណ្ឌចូលជាកងកម្លាំងបដិវត្តន៍ ដោយត្រូវបាននាំយកពីភូមិកំណើតរបស់ខ្លួន និងដាក់ក្នុងជំរំអប់រំមនោគមវិជ្ជា ។ ទោះបីជាយ៉ាងនេះក៏ដោយ យុវជនជាច្រើនគឺជាអ្នកស្ម័គ្រចិត្តដែលមានឆន្ទៈ ។

យុវជនដែលត្រូវបានកេណ្ឌ បានធ្វើជាយោធានៅអាយុប្រមាណ១២ឆ្នាំ ។ ឌិត ប្រ៉ិន បានបញ្ចេញទស្សនៈនៅក្នុងសៀវភៅរបស់គាត់ដែលបោះពុម្ពក្នុងឆ្នាំ១៩៩៧ ដែលមានចំណងជើងថា យុវជនក្នុងសម័យវាលពិឃាតរបស់កម្ពុជា ខ្មែរក្រហមក្មេងៗ ដែលទើបនឹងជ្រើសរើសមានភាពសាហាវព្រៃផ្សៃដែលមានអាយុក្នុងចន្លោះចាប់ពី១២ទៅ១៥ឆ្នាំ ។ របាយការណ៍របស់ទីភ្នាក់ងារអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួនបានថ្លែងថា ការជ្រើសរើសយោធាក្មេងៗ និងកម្មាភិបាលខ្មែរក្រហមកើតឡើងជាប្រចាំនៅចន្លោះឆ្នាំ១៩៧៥-៧៩ ។ ទីភ្នាក់ងារបានបង្ហាញយ៉ាងច្បាស់ថា ក្មេងៗដែលមានអាយុចាប់ពីប្រាំឆ្នាំត្រូវបានបណ្ដុះបណ្ដាលដើម្បីក្លាយជាកម្មាភិបាល ។ ព័ត៌មានមួយចំនួនអះអាងថាខ្មែរក្រហមបន្តជ្រើសរើសក្មេងប្រុសស្រីរហូតដល់ឆ្នាំ១៩៩៨

ក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់ខ្លួន ។ កុមារត្រូវបានបម្រើការក្នុងតួនាទីសំខាន់ៗ ឧទាហរណ៍អ្នកសែងគ្រាប់ និងបុងភៅ ។ អតីតខ្មែរក្រហមផ្តាច់ខ្លួនមួយរូបមកពីតំបន់ប៉ៃលិនបានអះអាងថា គាត់បានទទួលការបណ្តុះបណ្តាលខាងយោធាពីខ្មែរក្រហមតាំងពីគាត់មានអាយុប្រាំឆ្នាំ ។ អតីតកម្មាភិបាលរូបនោះបានរ៉ាយរ៉ាប់ថា សមាជិកក្នុងក្រុមមានក្មេងស្រីអាយុ១៨ឆ្នាំ ចាប់ពី២០០ ទៅ



កុមារដែលត្រូវបានជ្រើសរើសឲ្យធ្វើជាកងឈ្លបក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

៣០០នាក់ ។ ខ្មែរក្រហមបានផ្តត់ផ្គង់អាវុធ និងចាត់ចែងក្មេងៗទាំងនោះឲ្យទៅប្រយុទ្ធនៅសមរភូមិមុខ ។

### ការបំពាក់បំប៉ននយោបាយ និងមនោគមវិជ្ជាដល់ខ្មែរ

ខ្មែរក្រហមបានចាត់ចែងក្មេងៗរួចជាស្រេចឲ្យទៅបម្រើការជាមូលដ្ឋានសម្រាប់អនាគតបដិវត្តន៍ កសិកម្ម និងអនាគតដែលមានភាពម្ចាស់ការ ។ ទោះបីជាយ៉ាងនេះក៏ដោយ ខ្មែរក្រហមត្រូវការបង្កើតកម្មវិធីអប់រំដើម្បីបំពាក់បំប៉នមនោគមវិជ្ជាដល់កុមារដែលជាអនាគតដ៏ភ្លឺស្វាងរបស់បក្សកុម្មុយនីស្តកម្ពុជា ។ គោលបំណងសម្រាប់ការបំពាក់បំប៉នមនោគមវិជ្ជានយោបាយដល់កុមារមានបីចំណុច ៖ ទាក់ទាញភាពស្មោះត្រង់របស់ក្មេងទាំងនោះ ការញុះញង់ឲ្យមានកំហឹង និងអំពើហិង្សាប្រឆាំងនឹងសត្រូវខុសវណ្ណៈ និងសម្រួចបុគ្គលិកលក្ខណៈបដិវត្តន៍របស់ក្មេង ។ កម្មវិធីសិក្សាត្រូវបានបង្កើតឡើងដាច់ដោយឡែកដើម្បីសម្រេចឲ្យបានគោលបំណងនីមួយៗ ។ ទោះបីជាយ៉ាងនេះក៏ដោយ យុទ្ធសាស្ត្រសម្រាប់ការអប់រំមានលក្ខណៈខុសគ្នាដូចជា ការបង្រៀន ការផ្សាយតាមវិទ្យុ ការអានអត្ថបទខ្លីៗ និងការយកគំរូតវិយាបទ គឺជារឿងដ៏សំខាន់ ។ យុទ្ធសាស្ត្រសម្រាប់ការអប់រំ មិនបានកំណត់ត្រឹមតែសិក្សាពីព្រឹត្តិការណ៍ណាមួយនោះឡើយ ។

ច្បាប់ចេញផ្សាយទស្សនាវដ្តី យុវជន យុវនារីបដិវត្តន៍ សម្រាប់ខែតុលាឆ្នាំ១៩៧៦ ដែលជាការឃោសនារបស់ខ្មែរក្រហមដ៏សំខាន់បានពន្យល់ថា «ចាប់តាំងពីដំបូង បក្សបានសម្រេចចិត្តយកការងារមនសិការនយោបាយ ជាការងារដ៏សំខាន់បំផុតក្នុងចំណោមការងារទាំងអស់» ។ ប៉ុល ពត ជឿថា គំនិតរបស់កុមារប្រៀបបានទៅនឹងក្រដាសស និងមិនមានភាពលំអៀង ។ ប៉ុល ពត បានស្រមើស្រមៃថា កុមារនឹងចូលបដិវត្តន៍ដោយមិនបានគិតឲ្យគ្រប់ជ្រុងជ្រោយ ។ ប៉ុល ពត និងគូកនរបស់ខ្លួនបានដឹងថា មនោគមវិជ្ជារបស់ខ្លួន នឹងងាយទាញចំណាប់អារម្មណ៍កុមារជាជាងក្មេងជំទង់ ។ សម្រាប់ហេតុផលនេះសម្តេច នរោត្តម សីហនុ

បានពោលអះអាងនៅក្នុងសៀវភៅ សង្គ្រាម និង ក្តីសង្ឃឹម ៖ ករណីប្រទេសកម្ពុជា ថា ខ្មែរក្រហមបានឲ្យងារកិត្តិយសទៅក្មេងៗ ថាជា «ឧបករណ៍ផ្តាច់ការរបស់បក្ស» ។ ក្នុងឆ្នាំ១៩៧៧ ក្នុងថ្ងៃប្រារព្ធខួបលើកទី១៧របស់បក្សកុម្មុយនីស្តកម្ពុជា ប៉ុល ពត បាននិយាយអំពីលទ្ធភាពនៃបដិវត្តន៍របស់កូនខ្មែរ «បឋមវ័យ គឺជាអំឡុងពេលដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស វាគឺជាពេលវេលាដែលការគិតរបស់ក្មេងៗងាយនឹងទទួលយកគំនិតបដិវត្តន៍ និងជាពេលវេលាដែលយើងមានកម្លាំងកាយមាំមួន ។ នេះគឺជាសេចក្តីបង្គាប់ទូទៅរបស់បក្សរបស់យើង ។ យុវជននាពេលបច្ចុប្បន្ននឹងទទួលយកកិច្ចការបដិវត្តន៍សម្រាប់ពេលអនាគត» ។

វិធីដែលក្មេងៗទទួលបានការបំពាក់បំប៉នមនោគមវិជ្ជាខុសគ្នាតាមតំបន់នីមួយៗ គ្រូខ្ទេសម្នាក់ៗ និងការទទួលបានជំនួយសម្រាប់ការចូលរួមការបំពាក់បំប៉ននោះ ។ តំបន់មួយដែលការអប់រំទទួលបានជោគជ័យ គឺនៅភូមិភាគនិរតី ។ វ៉ាន់ ដែលជាអ្នករស់រានមានជីវិតពីតំបន់៣៥ (ខេត្តកំពត) ភូមិភាគនិរតីបានរៀបរាប់ថា ការអប់រំអាចលាងខួរក្បាលយុវជនដើម្បីឲ្យជឿស៊ប់ក្នុងបដិវត្តន៍ ។ លោក ម៉ៃឃើល វិកឃើរី បានរាយការណ៍អំពីអាស៊ីអាគ្នេយ៍នៅក្នុងសៀវភៅ ប្រទេសកម្ពុជាចន្លោះឆ្នាំ១៩៧៥-៨២ ថា យុវជនបានចូលរួមអង្គប្រជុំឃោសនា ឬជីវភាពយ៉ាងរីករាយ ។ បន្ទាប់ពីត្រឡប់មកពីចូលរួមវគ្គបណ្តុះបណ្តាលវិញ ក្មេងៗទាំងនោះបានញញឹមដោយក្តីរីករាយ និងសុទិដ្ឋិនិយម ។ ការបកស្រាយរបស់ វ៉ាន់ និងលោក ម៉ៃឃើល វិកឃើរី មានភាពស្រដៀងទៅនឹងការអង្កេតរបស់ ខេនណិត ឃ្វីន ក្នុងឆ្នាំ១៩៧៦ដែរ ។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យុវជនមួយក្រុមមកពីភូមិភាគនិរតី ប្រទេសកម្ពុជា បានត្រឡប់មកពីការអប់រំបណ្តុះបណ្តាលវគ្គនយោបាយពីទៅបីសប្តាហ៍ ។ ខេនណិត ឃ្វីន បានកត់សម្គាល់ថា យុវជនទាំងនោះបានត្រឡប់មកវិញដោយមានការចងកំហឹងនឹងរបបចាស់ ជិតទាស់ទៅនឹងឪពុកម្តាយ មានភាពស្មោះត្រង់ទៅនឹងបក្ស មើលងាយប្រពៃណី និងមានទស្សនៈធ្វើជាយោធា ។

ខ្ញុំបានកំណត់អត្តសញ្ញាណមេរៀនបំពាក់បំប៉នមនោគមវិជ្ជា និងនយោបាយទូទៅសម្រាប់ក្មេងៗពីប្រភពដែលបាននិយាយពីខាងលើរបស់ខ្ញុំ ដូចជា ភាពស្មោះត្រង់ទៅនឹងអង្គការ ការបំបាត់បុគ្គលនិយម ការពឹងផ្អែកលើខ្លួនឯង ការកេងប្រវ័ញ្ចលើអ្នកស្រែដោយជនចក្រពត្តិជិះជាន់ និងអ្នកទីក្រុង និងសាលារៀនអប់រំអំពើឃោរឃៅ ។

## ភាពស្មោះត្រង់នឹងអង្គការ

ក្មេងៗត្រូវបានបង្រៀនឲ្យគោរពអង្គការដោយមិនងាករេ ។ លោក ចន ម៉ាសស៊ុន បានចងក្រងឯកសារស្តីពីអ្នកបណ្តុះបណ្តាលរបស់ខ្មែរក្រហមដែលបង្រៀនក្មេងៗអំពីកាតព្វកិច្ចរបស់ខ្លួនចំពោះអង្គការដូចជា «កាតព្វកិច្ចទី១របស់អ្នក គឺចំពោះអង្គការ អ្នកគឺជាកូនចៅរបស់អង្គការ អ្នកគឺជាអនាគតរបស់យើង អង្គការស្រលាញ់អ្នកទាំងអស់គ្នា ។ នេះគឺជាហេតុផលដែលអង្គការផ្តល់អំណាចឲ្យអ្នក» ។ លើសពីនេះ គ្រូបង្រៀនបានបង្ហាញអំពីគំរូរបស់ខ្លួននៃការគោរពចំពោះអង្គការនៅក្នុងថ្នាក់រៀនដល់សិស្សខ្លួន ។

បក្សកុម្មុយនីស្តកម្ពុជា បានបង្ហាញថា ទំនាក់ទំនងគ្រួសារ គឺជាការធ្វើឲ្យបាត់បង់ភាពស្មោះត្រង់របស់ក្មេងៗចំពោះអង្គការ ។ ការបំពាក់បំប៉នមនោគមវិជ្ជានឹងក្លាយជាឥតបានការ ប្រសិនបើការស្រលាញ់ចំពោះគ្រួសារនៅតែបន្តបង្វែរឥទ្ធិពលរបស់អង្គការ ។ គោលបំណងនៃការបំពាក់បំប៉នមនោគមវិជ្ជា គឺដើម្បីបំផ្លាញរចនាសម្ព័ន្ធគ្រួសារ ។ សិទ្ធ គេង បានរៀបរាប់នៅក្នុងសៀវភៅ ការបញ្ចប់នៃជីវិតកុមារភាព ដែលបោះពុម្ពក្នុងឆ្នាំ១៩៩៧ថា «នៅក្នុងអង្គប្រជុំអប់រំ ខ្ញុំជឿជាក់លើយោធាខ្មែរក្រហម ពេលដែលយោធាទាំងនោះប្រាប់យើងថា គ្រួសាររបស់យើងមិនស្រលាញ់យើងទេ» ។ គ្រួសារត្រូវបានបែងចែកឲ្យទៅរស់នៅតាមជំរំផ្សេងៗគ្នា ។ ការទៅសួរសុខទុក្ខ ត្រូវបានកំណត់ជាពិសេស និងជាសិទ្ធិដែលទទួលបានដ៏ពិសេស ។ ប្រសិនបើសិទ្ធិជាពិសេសនោះត្រូវបានផ្តល់ឲ្យ ជាធម្មតាអាចអនុវត្តបានតែម្តងប៉ុណ្ណោះក្នុងមួយខែ ។ ការទៅសួរសុខទុក្ខ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ ។ ការបង្ហាញពីក្តីស្រឡាញ់ត្រូវបានហាមឃាត់ ។

ក្មេងៗត្រូវបានបង្រៀនឲ្យធ្វើជាភ្នាក់ងារភ្នែកម្ចាស់របស់អង្គការ ។ កាតព្វកិច្ចនេះ រួមមានក្មេងៗត្រូវរាយការណ៍សកម្មភាពក្បត់ទៅកម្មាភិបាលរបស់បក្ស ។ ក្មេងម្នាក់ដែលរស់រានមានជីវិតឈ្មោះ ខែល បានចងចាំអំពីការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះអង្គការ ដូចជា «អង្គការគឺជាមនុស្សតែម្នាក់គត់ដែលមានសន្តាន

ចិត្តល្អដល់យើង មិនមែនជាគ្រួសាររបស់ក្មេងៗទាំងនោះឡើយ ដូច្នេះ ក្មេងទាំងនោះ គួរតែធ្វើអ្វីក៏ដោយសម្រាប់បក្សបដិវត្តន៍ ប្រសិនបើអង្គការចង្អុលបង្ហាញអ្នកក្បត់ ក្មេងៗគួរតែហ៊ានកម្ទេចមនុស្សនោះដោយគ្មានការស្ទាក់ស្ទើរ សូម្បីតែជនក្បត់នោះគឺជាឪពុក ឬម្តាយរបស់ក្មេងៗទាំងនោះក៏ដោយ» ។ ក្មេងៗត្រូវបង្ហាញពីភាពស្មោះត្រង់របស់ខ្លួនចំពោះអង្គការ តាមរយៈការជេរប្រទេច និងការធ្វើទណ្ឌកម្មផ្នែករាងកាយ ដល់សមាជិកគ្រួសារនៅចំពោះមុខសមមិត្តខ្មែរក្រហមរបស់ខ្លួន ។ ដួង សុភារិទ្ធ បានរៀបរាប់ថា ក្មេងម្នាក់ឃើញម្តាយរបស់ខ្លួនលួចប៉េងប៉ោះពីចម្ការសហករណ៍ ។ ក្មេងប្រុសដែលមានកំហឹងបានស្ទុះទៅរកម្តាយរបស់ខ្លួន ហើយបានវាយម្តាយរបស់ខ្លួនដោយឥតសមហេតុផល ។ ក្មេងប្រុសនោះដែលមានមោទកភាពបានអះអាងថា ខ្លួនមិនបានវាយម្តាយឡើយ ប៉ុន្តែបានវាយចោរទៅវិញ ។

## ការបំបាត់បុគ្គលនិយម

គោលនយោបាយរបស់ ប៉ុល ពត លើបុគ្គលនិយម ស្រដៀងគ្នាទៅនឹងទស្សនៈរបស់ម៉ៅ ។ ស្របគ្នាទៅនឹងទស្សនៈរបស់ម៉ៅ ប៉ុល ពត ជឿថាដើម្បីរក្សាកុម្មុយនីស្ត បុគ្គលនិយមចាំបាច់ត្រូវដកចេញពីចិត្តគំនិតរបស់ប្រជាជនកម្ពុជា ។ ផែនការបួនឆ្នាំរបស់បក្សពោលអះអាងថា «នៅក្នុងប្រព័ន្ធអប់រំរបស់យើងមិនមានការប្រលង ឬសញ្ញាប័ត្រឡើយ ។ ប្រព័ន្ធអប់រំនោះគឺជាប្រព័ន្ធសិក្សាតាមរយៈសហករណ៍ និងតាមរយៈនៃចលនាបដិវត្តន៍សង្គមនិយមយ៉ាងច្បាស់លាស់ និងការកសាងសង្គមនិយមតាមបរិបទជាក់លាក់ ជាពិសេសសហករណ៍» ។ នៅពេលដែលបុគ្គលនិយមមាននៅក្នុងប្រព័ន្ធអប់រំក្នុងសាលារៀន ប៉ុល ពត ជឿជាក់ថា ការប្រគល់សញ្ញាប័ត្រ នឹងលើកស្ទួយដល់ទស្សនៈប្រកួតប្រជែង ។ ការប្រកួតប្រជែងគឺប្រឆាំងទៅនឹងទស្សនៈសមភាពនិយម ។

## ការពឹងផ្អែកលើខ្លួនឯង

ហាំង ង៉ោ បានរៀបរាប់ថា វគ្គបង្រៀនអំពីការបំពាក់បំប៉នមនោគមវិជ្ជាបានផ្តល់ហេតុផលផ្សេងៗគ្នាថាតើហេតុអ្វីរបបថ្មីបានគាំទ្រការជៀសវាងការពឹងផ្អែកលើបរទេស ។ ទោះបីជាយ៉ាងនេះក៏ដោយ ហាំង ង៉ោ បានបរិយាយអំពីហេតុផលដ៏សំខាន់សម្រាប់ការពឹងផ្អែកលើខ្លួនឯង ដូចជា «ទស្សនៈសំខាន់សម្រាប់សង្គមថ្មី គឺភាពម្ចាស់ការឯករាជ្យ ដូចដែលយើងត្រូវបានប្រាប់គ្រប់ពេលវេលា ក្នុងវគ្គសិក្សាឃោសនាមនោគមវិជ្ជា» ។ ហាំង ង៉ោ បានកត់សម្គាល់ថា ភាពឯករាជ្យម្ចាស់ការ រួមមានភាពឯករាជ្យខាងសេដ្ឋកិច្ច និងវប្បធម៌ និងការមិនទទួលរងឥទ្ធិពលដែលរារាំងពីការបំពេញការងារ ។ បក្សកុម្មុយនីស្តកម្ពុជាដែលធុញទ្រាន់ និងមានការប្រុងប្រយ័ត្នចំពោះការពង្រីកឥទ្ធិពលរបស់លោកខាងលិចក្នុងតំបន់អាស៊ីអាគ្នេយ៍បានធ្វើឲ្យ ប៉ុល ពត ពោលអះអាងឡើងថា «យើងកំពុងកសាងសង្គមនិយមដោយមិនយកគំរូតាមប្រទេសណាឡើយ យើងមិនចង់ចម្លងតាមនរណាឡើយ» ។

ទាក់ទងទៅនឹងការអប់រំ ផែនការអប់រំលើកមុនដែលបានបង្កើតឡើងដោយរបបសង្គមរាស្ត្រនិយមត្រូវបានលុបចោល ។ ក្នុងឆ្នាំ១៩៧៨ ប៉ុល ពត បាននិយាយថា «មិនមានសាលារៀនសកលវិទ្យាល័យ ឬមហាវិទ្យាល័យ តាមធម្មតានោះឡើយ ពីព្រោះយើងចង់កម្ចាត់ចោលអតីតកាលដែលនៅសេសសល់» ។ ខៀវ សំផន បានអះអាងថា ប្រព័ន្ធអប់រំចាស់ឥតមានប្រសិទ្ធភាពក្នុងការអប់រំសិស្សឲ្យបានគ្រប់គ្រាន់តាមវិទ្យាសាស្ត្រធម្មជាតិឡើយ ។ ខៀវ សំផន បានបញ្ចេញទស្សនៈថា សិស្សបានយល់ដឹងយ៉ាងច្បាស់អំពីការសាបព្រោះ និងការស្ទូងស្រូវ ។ ខៀវ សំផន បានបន្តរិះគន់ថា «អ្វីៗទាំងអស់ត្រូវបានធ្វើឡើងដោយយោងលើសៀវភៅបរទេស និងស្តង់ដាររបស់បរទេស ដូច្នេះហើយវាគ្មានប្រយោជន៍ និងមិនអាចបម្រើសេចក្តីត្រូវការរបស់ប្រជាជនរបស់យើង ហើយក៏មិនអាចជួយដល់ការកសាងប្រទេសរបស់យើងបានឡើយ» ។

## អ្នកជិះជាន់ និងអ្នកដែលត្រូវគេជិះជាន់

មុនថ្ងៃទី១៧ ខែមេសា ខ្មែរក្រហមបានចែកចាយខិតប័ណ្ណដែលពន្យល់ជាដំបូងអំពីខ្លឹមសារនៃការជិះជាន់ ។ សាស្ត្រាចារ្យ អាឡិច ហ៊ីនតុន បានពោលអះអាងក្នុងសៀវភៅ ហេតុអ្វីបានខ្មែរក្រហមសម្លាប់? ប្រទេសកម្ពុជានៅក្នុងស្រមោលនៃអំពើប្រល័យពូជសាសន៍ ថា ខិតប័ណ្ណមួយនេះ បានរៀបរាប់អំពីជនមូលធននិយមរស់នៅដោយសម្បូរទ្រព្យធនបង្កគ្រោះថ្នាក់ដល់វណ្ណៈពលករ និងមនុស្សដែលរស់នៅដោយក្តីទុរគត ។ ការសរសេរលិខិតខ្លីៗគិះដៀលខាងនយោបាយមុនបដិវត្តន៍ ស្តីពីការជិះជាន់មានលក្ខណៈ

ខូះខាតខាងពង្រឹងរចនាសម្ព័ន្ធ ។ ទោះបីជាយ៉ាងនេះក៏ដោយ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ខ្មែរក្រហមបានគ្រប់គ្រងមធ្យោបាយ ទំនាក់ទំនងទាំងអស់ ។ ការបំពាក់បំប៉ននយោបាយ អាចត្រូវបានរៀបចំនិងសម្រេចពេញប្រទេស ។

កម្មវិធីអប់រំផ្នែកនយោបាយបានដាក់ចេញនូវពាក្យបដិវត្តន៍ថ្មីក្នុងសន្ទានុក្រមរបស់កូនខ្មែរ ។ កូនក្មេងបានសិក្សាអំពីលក្ខណៈទ្រឹស្តីរបស់កុម្មុយនីស្ត ។ ការបង្កើតមនសិការនយោបាយ តម្រូវការសិក្សាអំពីទ្រឹស្តីស្នេហ៍គ្រចិត្តរបស់ ឡេនីន និងអត្ថបទសំណេរស្តីពីលទ្ធិម៉ាករបស់មនោគមវិជ្ជាម៉ៅ ។ បក្សកុម្មុយនីស្តកម្ពុជាជឿថា កុមារបានទទួលមនសិការនយោបាយដាច់ខាត នៅពេលដែលក្មេងទាំងនោះអាចយល់ច្បាស់ និងរៀបរាប់អំពីរបៀបវារៈរបស់បក្ស ក្រៅពីការយល់ដឹងអំពីការបង្រៀនជាមូលដ្ឋានរបស់ម៉ាក និង លេនីន ។ ខ្មែរក្រហមបានបង្រៀនកុមារស្តីពីការកេងប្រវ័ញ្ចវណ្ណៈ ការធ្វើឲ្យកសិករដែលរងការជិះជាន់ប្រឆាំងនឹងជនចក្រពត្តិគាបសង្កត់ និងជនមូលធននិយមនៅភ្នំពេញ ។ យុវជនបានសិក្សាអំពីការតស៊ូវណ្ណៈ លក្ខណៈនៃការតស៊ូវណ្ណៈ និងការជិតាស់ខ្វែងទស្សនៈ ។ គោលបំណងចម្បងនៃកម្មវិធីសិក្សានេះគឺមិនមែនជាការអប់រំឡើយ ប៉ុន្តែញុះញង់ឲ្យមានអារម្មណ៍ស្អប់វណ្ណៈទៅវិញទេ ។ ការអប់រំពីនយោបាយបានបំផុសកំហឹង និងការអន់ចិត្តក្នុងចំណោមអ្នករៀនសូត្រក្មេងៗ និងយុវជន ។ គ្រូបង្រៀនបានប្រដូចសត្រូវនៃលទ្ធិម៉ាក្ស លេនីន ដូចជា ជនចក្រពត្តិនិយម ជនសក្តិភូមិ និងជនមូលធននិយមទៅនឹងរបប លន់ នល់ របស់ប្រទេសកម្ពុជា និងអ្នករស់នៅក្នុងទីក្រុង ។ ការឃោសនាញុះញង់បានប្រៀបទំនាក់ទំនងនៃអ្នកដែលត្រូវជិះជាន់ និងអ្នកដែលជិះជាន់ទៅនឹងជ្រលងភ្នំដែលមិនអាចឆ្លងកាត់បាន ។ ឥទ្ធិពលរបស់អ្នកជិះជាន់អាចបង្ក្រាបបានតែតាមរយៈអំពើហិង្សា និងការកម្ទេចតែប៉ុណ្ណោះ ។ លោក អាឡិច ហ៊ីនតុន បានអះអាងទៀតថា យុវជននឹងសិក្សាអំពីឯកសារមួយចំនួន រួមមាន ឯកសារស្តីពីការតស៊ូវណ្ណៈ និងការស្អប់វណ្ណៈ ។ គាត់បានលើកឡើងបន្ថែមទៀតថា អំឡុងពេលអង្គប្រជុំបដិវត្តន៍ ការសម្តែងសិល្បៈ ដែលបង្ហាញអំពីលក្ខណៈបុណ្យសពរបស់សមមិត្តដែលបានស្លាប់ត្រូវបានរៀបចំឡើងដើម្បីញុះញង់ឲ្យមានកំហឹងបដិវត្តន៍ ដូច្នេះអ្នកចូលរួមបានឆេះកំហឹងជា



យុវជនដែលជាយោធាខ្មែរក្រហមកំពុងធ្វើសមយុទ្ធ ឬកំពុងប្រយុទ្ធនៅសមរភូមិក្នុងជំនាន់សង្គ្រាមស៊ីវិល ។

មួយនឹងសត្រូវ ។ ការទទួលរងឥទ្ធិពលនៃការឃោសនាពីអំពើហិង្សា និងរូបភាពនៃការប្រព្រឹត្តអំពើហិង្សា បានធ្វើឲ្យយុវជនលែងសូវយល់ដឹងពីផលអាក្រក់នៃអំពើហិង្សានោះ ។

**សាលាអប់រំឲ្យប្រព្រឹត្តអំពើយង់ឃ្នង**

ខាល ដេកសាន់ បានអះអាងនៅក្នុងសៀវភៅ កម្ពុជា ១៩៧៥-១៩៧៨ : ការជួបសេចក្តីស្លាប់ ដែលបោះពុម្ពក្នុងឆ្នាំ១៩៨៩ ថា យុវជនត្រូវបានបង្រៀនឲ្យស្អប់ និងប្រើអំពើហិង្សាប្រឆាំងទៅនឹងសត្រូវរបស់បក្ស ។ អំពើឃោរឃៅដែលមិនអាចនឹកស្មានដល់ បានកើតចេញពីក្មេងៗដែលបានបំពាក់បំប៉នមនោគមវិជ្ជាអំពើហិង្សា ។ សម្តេច នរោត្តម សីហនុ បានឃើញយុវជនប្រព្រឹត្តអំពើហិង្សាទៅលើសត្រូវដែលចាប់ខ្លួនបាន ។ សម្តេច នរោត្តម សីហនុ បានអះអាងថា ខ្មែរក្រហមបានបង្កើតសាលាអប់រំឲ្យប្រព្រឹត្តអំពើឃោរឃៅ ។ ព្រះអង្គបាននិយាយថា ប៉ុល ពត និង អៀង សារី បានគិតយ៉ាងត្រឹមត្រូវថា ប្រសិនបើខ្មែរក្រហមបណ្តុះបណ្តាលក្មេងៗអំពីល្បែងដែលមានអំពើឃោរឃៅ ក្មេងទាំងនោះនឹងក្លាយជាយោធា ដែលល្មោភសម្លាប់ និងល្មោភសង្គ្រាម ។ ព្រះអង្គជឿថា ខ្មែរក្រហមក្មេងៗនឹងមានចិត្តអង់អាចតាមរយៈការសម្លាប់ឆ្មា ឆ្កែ និងសត្វតូចៗជាមួយនឹងចំពុះទុង និងដំបង ។ យោងតាម សម្តេច សីហនុ ល្បែងដាក់ទណ្ឌកម្ម ត្រូវបានប្រើប្រាស់ជាឧបករណ៍បណ្តុះបណ្តាលដ៏សំខាន់របស់ខ្មែរក្រហម ។ សាលាអប់រំប្រព្រឹត្តអំពើយង់ឃ្នង បានធ្វើឲ្យមានការបំភិតបំភ័យ ការប្រើប្រាស់ក្មេងៗ និងជំរុញឲ្យក្មេងៗធ្វើការបំភិតបំភ័យដល់សត្រូវខុសវណ្ណៈដោយឥតលាក់លៀម ។ កុមារប្រព្រឹត្តអំពើយង់ឃ្នងតាមរយៈការអនុវត្តនៅក្នុងសាលា ។ ក្មេងទាំងនោះ រៀនចប់នៅពេលដែលក្មេងទាំងនោះបានសម្លាប់សត្រូវទី១របស់បក្ស ។

**ទំនាក់ទំនងរវាង ការអប់រំថ្នាក់បឋមសិក្សា និងមធ្យមសិក្សា និងមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា**

លោក ដេម ថាយណ័រ (២០១១) បានលើកឡើងនៅក្នុងសៀវភៅ ការអប់រំពីភូមិសាស្ត្រជាគោលនយោបាយប្រល័យពូជសាសន៍ក្រោមរបបខ្មែរក្រហម ថា «ខ្មែរក្រហម ខិតខំពន្យល់ហេតុផលអំពីកម្មវិធីសិក្សាស្តីពីសេដ្ឋកិច្ច និងនយោបាយតាមរយៈការអប់រំ» ។ ថាយណ័រ បានបញ្ចេញទស្សនៈថា របបកម្ពុជាប្រជាធិបតេយ្យ បានប្រើប្រាស់ការអប់រំដើម្បីបង្កើតមនសិការនយោបាយរបស់កុមារ ។ បក្សកុម្មុយនីស្តកម្ពុជា មានបំណងយ៉ាងច្បាស់ក្នុងការដាក់ចេញមនោគមវិជ្ជាបក្សនៅក្នុងការអប់រំថ្នាក់បឋមសិក្សា និង មធ្យមសិក្សា ។ លោក ប៉ែន យៀវនិន បានបង្ហាញឲ្យឃើញយ៉ាងច្បាស់នៅក្នុងសៀវភៅដែលមានចំណងជើងថា របប ប៉ុល ពត : ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍ក្នុងប្រទេសកម្ពុជាក្រោមរបបខ្មែរក្រហម ១៩៧៥-៧៩ ថា ការបង្រៀននយោបាយនៅបឋមសិក្សា និងមធ្យមសិក្សា នឹងចាប់ផ្តើមបន្ទាប់ពីបក្សបានទទួលគ្រូជំនាញ ដែលអប់រំខ្មែរក្រហមផ្ទាល់ក្នុងចលនាដំបូងរបស់ប្រជាជន» ។ បក្សបានស្វែងរកអ្នកជំនាញខាងមនោគមវិជ្ជារបស់បក្ស និងមុខវិជ្ជាទូទៅ ដូចជា គីមីវិទ្យា ។ ការដែលមានគ្រូបង្រៀនបែបនេះ នឹងអាចបញ្ចូលមនោគមវិជ្ជារបស់បក្សក្នុងមេរៀនគីមីវិទ្យាយ៉ាងមានប្រសិទ្ធភាព ។

ជាងនេះទៅទៀត «ផែនការបួនឆ្នាំរបស់បក្សក្នុងការកសាងសង្គមនិយមគ្រប់វិស័យ១៩៧៧-១៩៨០» ដែលជាផ្នែកទីបីក្នុងមុខវិជ្ជាវប្បធម៌ អក្សរសាស្ត្រ សិល្បៈ បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងការអប់រំអំពីមនុស្ស ការឃោសនា និងព័ត៌មាន បានរៀបរាប់មុខវិជ្ជាទូទៅចំនួន៦ ដែលត្រូវបង្រៀននៅសាលាបឋមសិក្សា និងមធ្យមសិក្សា ។

មុខវិជ្ជាទូទៅ

- ការអាន និងការសរសេរ
- គណិតវិទ្យា



កុមារដែលខ្មែរក្រហមកេណ្ឌឲ្យចូលធ្វើយោធា

◆ *ភូមិសាស្ត្រ (សារៈសំខាន់របស់ប្រទេស)*

◆ *ប្រវត្តិសាស្ត្រនៃការតស៊ូបដិវត្តន៍របស់ប្រជាជន ការតស៊ូបដិវត្តន៍សម្រាប់ប្រទេស ការតស៊ូបដិវត្តន៍សម្រាប់លទ្ធិប្រជាធិបតេយ្យ ការតស៊ូបដិវត្តន៍សម្រាប់បដិវត្តន៍សង្គមនិយម និងការតស៊ូដើម្បីកសាងសង្គមនិយម ។*

◆ *វិទ្យាសាស្ត្រធម្មជាតិ រូបវិទ្យា និងគីមីវិទ្យា ជាមូលដ្ឋាន*

◆ *គោលនយោបាយបក្ស មនសិការនយោបាយ និងអង្គការ*

*ភ័ស្តុតាងច្បាស់លាស់នេះបានបង្ហាញយ៉ាងច្បាស់ថា ខ្មែរក្រហមបានសង្កត់ធ្ងន់លើមនោគមវិជ្ជា ទាំងការបំពាក់បំប៉នមនោគមវិជ្ជាបដិវត្តន៍ និងនយោបាយក្នុងសាលាបឋមសិក្សា និងមធ្យមសិក្សាច្រើនជាងមុខវិជ្ជាទូទៅ ដូចជា រូបវិទ្យា និងគណិតវិទ្យា ។ ក្នុងការទទួលស្គាល់ការពិតនេះ មនោគមវិជ្ជាបានជ្រាបចូលក្នុងកម្មវិធីសិក្សាគ្រប់មុខវិជ្ជាទាំងអស់ និងផែនការបង្រៀន ។ ផ្នែកទីបីនៃឯកសារវប្បធម៌ អក្សរសាស្ត្រ សិល្បៈ បច្ចេកវិទ្យា វិទ្យាសាស្ត្រ ការអប់រំ បណ្តាញព័ត៌មាន និងឯកសារព័ត៌មាន ដែលមានចំណងជើងថា ការពន្យល់ជាបឋមមុនការអានផែនការ ដោយលេខាបក្សដែលត្រូវបានបង្កើតឡើងដោយមជ្ឈិមបក្ស នៅថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦ បក្សបង្កើតទំនាក់ទំនងយ៉ាងច្បាស់លាស់រវាងមុខវិជ្ជាអប់រំទូទៅ និងបដិវត្តន៍ ដូចជា «យើងសិក្សាដើម្បីបម្រើគោលដៅរបស់បដិវត្តន៍ ។ ប្រសិនបើយើងសិក្សាមុខវិជ្ជាទីមួយ យើងនឹងបម្រើចលនាដោយផ្ទាល់ ការសិក្សានិងការរៀនសូត្រមុខវិជ្ជាទីពីរ យើងនឹងបម្រើបដិវត្តន៍ដោយផ្ទាល់» ។*

*លោក ដេម ថាយណ័រ បានសន្និដ្ឋានថា បក្សបានប្រើអត្ថបទភូមិសាស្ត្រ និងផែនការបង្រៀនជាមួយនឹងមុខវិជ្ជាបដិវត្តន៍ និងនយោបាយដើម្បីបង្កើតមនសិការនយោបាយរបស់សិស្ស ។ ថាយណ័រ ជឿថាការបង្រៀនអំពីភូមិសាស្ត្រ គឺមានសារសំខាន់ក្នុងការបង្កើតនូវមនសិការនយោបាយ ។ លោកអះអាងថា សាលាបឋមសិក្សា និងមធ្យមសិក្សាក្នុងរបបកម្ពុជាប្រជាធិបតេយ្យបម្រើដល់ការបង្កើត និងការពង្រឹងមនោគមវិជ្ជាជាតិនិយមដ៏ជាក់លាក់ ។ ការអនុវត្តទាំងនេះ ដែលត្រូវបានប្រើដើម្បីពន្យល់ហេតុផល និងធ្វើឲ្យដំណើរការនយោបាយ និងការអនុវត្តផ្សេងស្របច្បាប់ រួមមាន «ការប្រើអំពើហិង្សាធ្ងន់ធ្ងរ និងអំពើប្រល័យពូជសាសន៍» ។ កុមារត្រូវបានបង្រៀនថាតើនរណាត្រូវដាក់បញ្ចូល និងថាតើនរណាត្រូវដកចេញពីប្រទេសកម្ពុជា ។ ដេម ថាយណ័រ បានវិភាគអត្ថបទភូមិសាស្ត្រថ្នាក់ទី២ដែលនៅសេសសល់ ដែលមានចំណងជើងថា ភូមិសាស្ត្រនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ ដែលបានសង្កត់ធ្ងន់លើមេរៀនស្តីពីភូមិសាស្ត្រនយោបាយ ។ អត្ថបទដែលបានបោះពុម្ពដោយក្រសួងអប់រំក្នុងឆ្នាំ១៩៧៧ មានចំនួន៧២ទំព័រ និង១២ជំពូក ។ ពីរឬបីជំពូកដំបូងបានផ្តល់នូវសេចក្តីសង្ខេបនៃការបង្កើតអង្គការចាត់តាំង និងទីតាំងភូមិសាស្ត្រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចជា ខេត្ត ភូមិភាគ ស្រុក តំបន់ ។ កុមារសិក្សាអំពីតំបន់ដែលជាប់ទាក់ទងនឹងបដិវត្តន៍ទាំងស្រុង ។ ផែនការបង្រៀន បានធ្វើសន្និដ្ឋានជាមួយនឹងការចោទសួរសង្ខេបស្តីពីជំពូកនោះដូចជា «អំឡុងពេលប្រាំឆ្នាំនៃសង្គ្រាមបដិវត្តន៍ តើប្រជាជននៅខេត្តព្រះវិហារចូលរួមជាមួយបដិវត្តន៍យ៉ាងដូចម្តេច?*

## សេចក្តីសន្និដ្ឋាន

*ដើម្បីកំណត់អត្តសញ្ញាណនៃទំនាក់ទំនងរវាងការអប់រំថ្នាក់បឋមសិក្សា និងមធ្យមសិក្សា និងការបំពាក់បំប៉ននយោបាយ មានការផ្សារភ្ជាប់គ្នាចង្អុលត្រូវបានសម្រេចដើម្បីបំពេញគម្លាតក្នុងប្រវត្តិសាស្ត្ររបស់ខ្មែរក្រហម ។ ខ្ញុំបានបង្ហាញអំពីមនោគមវិជ្ជារបស់បក្សត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធអប់រំថ្នាក់បឋមសិក្សា និងមធ្យមសិក្សាក្នុងការផ្តល់ផលប្រយោជន៍ដល់បដិវត្តន៍ខ្មែរក្រហម ។ បក្សបានបញ្ចូលការបំពាក់បំប៉នមនោគមវិជ្ជា និងនយោបាយក្នុងសាលាបឋមសិក្សា និងមធ្យមសិក្សាទូទៅដើម្បីសម្រេចឲ្យបានគោលបំណងនយោបាយ ។ បន្ទាប់ពីពិចារណាអំពីគំហើញស្រាវជ្រាវរបស់ ដេម ថាយណ័រ បច្ចុប្បន្ន យើងដឹងថាខ្មែរក្រហមបានបង្កើតការបង្រៀនដែលមានមូលដ្ឋានលើភូមិសាស្ត្រដើម្បីពង្រឹងនូវការស្រមើស្រមៃនៃទីតាំងភូមិសាស្ត្រ និងមនសិការនយោបាយដល់អ្នកសិក្សា ។ ការស្រាវជ្រាវរបស់ខ្ញុំ និងការស្រាវជ្រាវរបស់ ដេម ថាយណ័រ គឺជាការចាប់ផ្តើមដំបូងដ៏មានអត្ថប្រយោជន៍ ។ ទោះបីជាយ៉ាងនេះក៏ដោយ ការសិក្សាស្រាវជ្រាវស្តីពីអំពើប្រល័យពូជសាសន៍ដែលផ្តោតលើកម្មវិធីសិក្សា នៅតែមានដំណាក់កាលវែងឆ្ងាយដែលត្រូវធ្វើ ។*

**ក្រេកហ្គោរី ប្រូកណូច**

# ខ្ញុំបាត់បង់ឪពុក

ស៊ឹម សារ៉ាវី មានអាយុ៥៣ឆ្នាំ បច្ចុប្បន្នរស់នៅឃុំរការក្នុង ក្រុងដូនកែវ ខេត្តតាកែវ ។ កាលពីអាយុប្រហែលដប់ពីរឬដប់បីឆ្នាំ សារ៉ាវី បានរៀនដល់ថ្នាក់ទីប្រាំពីរទំនើបនៅសាលាមួយកន្លែង ដែលមានទីតាំងស្ថិតនៅម្តុំស៊ាំហួយ (ផ្លូវក្បាលពោធិ៍) ខេត្តតាកែវ ។ មកដល់ឆ្នាំ១៩៧០ សារ៉ាវី បានឃើញព្រឹត្តិការណ៍ចាប់ទាហាន ពាសពេញស្រុកភូមិ ដោយពេលនោះ ឪពុកគាត់ក៏បានចូលបម្រើកងទ័ព លន់ នល់ ដែរ ប៉ុន្តែនៅខាងផ្នែកកាត់សក់ ។

សង្គ្រាមបានបន្តរហូតដល់របប ប៉ុល ពត កាន់កាប់ប្រទេសកម្ពុជាទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ យោធាខ្មែរក្រហមបីនាក់បានដើរមកផ្ទះ សារ៉ាវី និងអ្នកភូមិ ដោយស្រែកប្រកាសឲ្យចាកចេញពីផ្ទះដោយមិនចាំបាច់យកអីវ៉ាន់ច្រើនទៅជាមួយទេ ។ អ្នកជិតខាងម្នាក់និយាយប្រាប់គ្រួសារគាត់ថា «យើងចេញទៅតែពីរបីថ្ងៃប៉ុណ្ណោះ ដូច្នេះមិនចាំបាច់យករបស់របរទៅច្រើនទេ យកតែប្រហុក អំបិលបន្តិចបន្តួចបានហើយ» ។ គ្រួសារ សារ៉ាវី បានប្រញាប់ប្រញាល់រៀបចំអីវ៉ាន់រួមមាន ចានឆ្នាំង ខោអាវ អង្ករ ដែលឪពុករបស់គាត់រៀបចំដាក់នឹងអម្រែក ។ ម្តាយ សារ៉ាវី បានពនិងបណ្តើរប្អូនតូចៗ ចំណែក សារ៉ាវី បានយកកង់ដែលខ្លួនជិះទៅសាលារៀនរាល់ថ្ងៃដាក់អីវ៉ាន់រួចបណ្តើរចេញដែរ ។ ពេលនោះ ខ្មែរក្រហមម្នាក់មូរជើងខោស្រែកគំរាមបាញ់សម្លាប់ ប្រសិនបើប្រជាជនណាមិនព្រមចាកចេញពីផ្ទះ ។ ទិដ្ឋភាពនោះបានធ្វើឲ្យ សារ៉ាវី ស្លុតចិត្តយ៉ាងខ្លាំងព្រោះគាត់មិននឹកស្មានថា មានហេតុការណ៍នេះកើតឡើងទេ ។



ស៊ឹម សារ៉ាវី

នៅតាមផ្លូវ មនុស្សម្នាជាច្រើនបានដើរប្រជ្រៀតគ្នា ។ សិស្សសាលាខ្លះត្រូវបានចងបន្តបន្ទាប់គ្នា ហើយបណ្តើរតាមផ្លូវដោយកងឈ្លប ។ សាកសពដេកដួលពាសពេញផ្លូវ ។ គ្រួសារ សារ៉ាវី ដើរតាមផ្លូវជើងចាប និងព្រៃលើ សំដៅទៅអង្គតាសោម ។ ពេលទៅដល់វត្តចម្ប៉ា ខ្មែរក្រហមបានឲ្យប្រជាជនទាំងអស់សម្រាកនៅទីនោះ ហើយចែកអង្ករឲ្យប្រាំកំប៉ុងសម្រាប់មនុស្សប្រាំនាក់ ។ ខ្មែរក្រហមទាំងនោះនិយាយប្រាប់ប្រជាជនទាំងអស់ឲ្យបេះសន្សំសំបៃ សម្រាប់ពេលខ្វះខាត ។ បន្ទាប់ពីចែកអង្កររួច ប្រជាជនជម្លៀសទាំងអស់ត្រូវបានហៅឲ្យចុះឈ្មោះនៅវត្តអង្គមន្ត្រី ហៅ វត្តនិគ្រោធ (ស្ថិតនៅក្នុងភូមិត្រពាំងថ្ម) ដោយឲ្យប្រាប់ពីតួនាទី កន្លែងដែលខ្លួនរស់នៅ ដើម្បីអង្គការបញ្ជូនទៅធ្វើការងារវិញ ។

បន្ទាប់មក គ្រួសារ សារ៉ាវី ត្រូវបានបញ្ជូនឲ្យទៅរស់នៅវត្តអង្គរលាយ ។ ខ្មែរក្រហមបានចាត់តាំងគ្រួសារ សារ៉ាវី ឲ្យធ្វើពលកម្មគ្រប់គ្នា ដោយឪពុកគាត់ត្រូវបានចាត់តាំងឲ្យស្ទូងរកបង្គីដើម្បីលើកដី ។ ដំបូងគ្រួសារ សារ៉ាវី មិនមានផ្ទះសម្រាប់ស្នាក់នៅទេ ដូច្នេះ អង្គការបានឲ្យគ្រួសារគាត់ទៅស្នាក់នៅក្នុងក្រុងស្រូវប្រវែងប្រាំម៉ែត្របួនជ្រុង ដែលទីនោះគឺជាអតីតក្រុងស្រូវរបស់ម្ចាស់ផ្ទះពីមុន ។ គ្រួសារ សារ៉ាវី រៀបចំស្រូវទុកទៅម្ខាង ហើយម្ខាងទៀតសម្រាប់ដេក ដូច្នេះហើយទើប សារ៉ាវី និងឪពុកគាត់បានឡើងភ្នំកាប់ឫស្សីយកមកធ្វើផ្ទះឲ្យបានធំទូលាយជាងមុន ។

ប៉ុន្តែមិនយូរប៉ុន្មាន គ្រួសារគាត់ត្រូវបានចាត់តាំងឲ្យទៅធ្វើការតាមកងរៀងៗខ្លួន ។ ឪពុកនិង ម្តាយគាត់ត្រូវបានចាត់តាំងឲ្យទៅនៅតាមកងមនុស្សធំ ។ គាត់ទៅតាមកងនារី ចំណែកឯប្អូន

ប្រុស និងប្អូនស្រីទៅតាមកងកុមារ ។ ប្រធានកងនារីឈ្មោះ យឿន ជាអ្នកភូមិអន្លង់តានិល បានដាក់ផែនការឲ្យគាត់ដឹកប្រឡាយ លើកទំនប់ រែកដី ដែលធ្វើឲ្យនារីក្នុងកងទាំងអស់ធ្លាក់ខ្លួនឈឺស្គមស្គាំង ។ ចំណែកការហូបចុក ពេលទៅដល់ដំបូងបានបាយមួយស្លាក និងសម្លមួយឆ្នាំងតូចសម្រាប់សមាជិកបួននាក់ ។ ក្រោយមក ការហូបចុកនេះកាន់តែតិចទៅៗ រហូតដល់ខែស្ទួងមានតែបបររាវលាយដំឡូងមីប៉ុណ្ណោះ ។ មានមនុស្សជាច្រើនបានរអ៊ូរទាំនឹងរបបអាហារដែលមិនស័ក្តិសមទៅនឹងការងារពេលកម្មប្រចាំថ្ងៃ ។ អ្នករអ៊ូរទាំទាំងនោះសុទ្ធតែជាអ្នកដែលមានចំណេះដឹង និងជាអ្នកទីក្រុងដែលមិនអាចទទួលយកការងារ និងរបបអាហារបែបនេះបាន ។ ប៉ុន្តែក្រោយមក អ្នកតវ៉ាទាំងនោះត្រូវអង្គការស្នើយកទៅរៀនសូត្រទាំងអស់ ។

សារ៉ាវី នៅចងចាំថា នៅពេលយប់មួយ មានកងឈ្លបខ្មែរក្រហមបីនាក់មកហៅអ្នកនៅក្នុងកងរបស់គាត់យកទៅរៀនសូត្រដោយប្រាប់ថា «រៀចខោអាវមក អង្គការយកទៅរៀនសូត្រ» ។ សារ៉ាវី មិនបានដឹងសោះថាតើការស្នើយកទៅរៀនសូត្រមានន័យបែបណានោះទេ?» ពេលនោះ សារ៉ាវី ក៏មិនហ៊ានសួរដេញដោលអ្វីទាំងអស់ ម្យ៉ាងទៀតដោយសារគាត់អស់កម្លាំងខ្លាំងពេក ។ លុះដល់ពេលព្រឹកឡើង ទើបគាត់ដឹងថាអ្នកដែលកងឈ្លបហៅទៅត្រូវបានសម្លាប់ចោលហើយ ។ កងឈ្លបទាំងនោះគឺជាអតីតអ្នកភូមិគួកដែលកងនារីរបស់ សារ៉ាវី ធ្លាប់ស្នាក់នៅ ។ សារ៉ាវី ធ្លាប់មកលេងផ្ទះពីរដង ដោយចម្ងាយផ្លូវពីកងរបស់គាត់ទៅវត្តអន្លង់វិលាយ (កន្លែងគ្រួសារគាត់ស្នាក់នៅ) មានចម្ងាយប្រវែងប្រាំគីឡូម៉ែត្រ ។ ពេលមកដល់ផ្ទះ សារ៉ាវី ឃើញមានការប្រែប្រួលខ្លះនៅក្នុងភូមិ ដូចជាមានបាត់មនុស្សដោយសារការយកទៅរៀនសូត្រដូចជា យុវជនម្នាក់ដែលជាអ្នកជិតខាង និងជាប្រជាជនជម្លៀសទៅថ្មីក៏ត្រូវអង្គការស្នើយកទៅរៀនសូត្រ ហើយក្រោយមកក៏ត្រូវអង្គការសម្លាប់ចោលដោយហេតុថាបុរសនោះជាពេទ្យទាហាន ។ ពេល សារ៉ាវី ត្រឡប់មកដល់កងវិញ ត្រូវបានអង្គការផ្លាស់ប្តូរឲ្យទៅដឹកប្រឡាយនៅស្រែរនោង និងទៅច្រូតស្រូវនៅបែកគុស ។

នៅប្រហែលជាឆ្នាំ១៩៧៧ ឪពុក សារ៉ាវី បានធ្លាក់ខ្លួនឈឺដែលកាលនោះ សារ៉ាវី នៅដាំដំណាំនៅទំនប់តាអី ។ សារ៉ាវី បានរើសដំឡូងបីមើម ដែលសេសសល់ពីការភ្ជួររាស់ប្រមូលផលយកមកឲ្យឪពុក ។ ប៉ុន្តែស្របពេលនោះ សារ៉ាវី ក៏កើតជំងឺរលួយបាតជើង ដែលអ្នកភូមិប្រាប់គាត់ថា បានដើរជាន់ទឹកនោមពស់ ។ អ្នកខ្លះថា នេះគឺជាជំងឺមហារីក ។ សារ៉ាវី ចងចាំថា នៅពេលមួយអង្គការវាយជួង កងចល័តរត់សម្រុកត្រឡប់មកកងដើម្បីហូបបាយវិញ ចំណែកគាត់ដែលរត់មិនទាន់គេបានស្រែកទ្រហោយំដោយសារតែជើងឈឺ ។ ប៉ុន្តែអង្គការបែរជាចោទគាត់ថាមានជំងឺសតិអារម្មណ៍ទៅវិញ ។ ក្រោយមកដោយសារមិនមានថ្នាំព្យាបាល សារ៉ាវី បានបុកអំបិលម្ទេសមកលាបព្យាបាលជើង ។

ជំងឺរបស់ សារ៉ាវី មិនបានធូរស្រាលទេ តែបែរជារឹតតែឈឺខ្លាំងឡើងថែមទៀត ។ ចំណែករបបអាហារ គាត់ទទួលបានតែបបរមួយវែកប៉ុណ្ណោះក្នុងមួយពេល ដោយហេតុថាគាត់មិនអាចជួយធ្វើការងារអង្គការ ។ ជំងឺរបស់ សារ៉ាវី កាន់តែធ្ងន់ធ្ងរឡើងៗ រហូតដល់ខ្មែរក្រហមបញ្ជូនគាត់ទៅព្យាបាលនៅពេទ្យត្រពាំងគល់ ខាងលិចអង្គតាសោម ។ បន្ទាប់ពីស្នាក់នៅព្យាបាលមួយរយៈ ជំងឺគាត់ក៏បានជាសះស្បើយ ។

នៅក្នុងឆ្នាំ១៩៧៧ ពេលដែល សារ៉ាវី ចេញពីមន្ទីរពេទ្យ ស្រាប់តែកងទ័ពវៀតណាមវាយសម្រុកមកលើយោធាខ្មែរក្រហម នៅខាងត្បូងស្រុកគិរីវង់ ។ ប្រធានកងនារីឈ្មោះ យឿន បានប្រាប់កងនារីទាំងអស់ថា «នារីទាំងអស់ឲ្យទៅប្រជុំនៅវត្តនិគ្រោធ និងរៀចបាយទៅផង» ។ នៅវេលាម៉ោងបួនទៀបភ្លឺ អង្គការបានដាំបាយដំណើបចែកឲ្យហូប ដោយមួយស្នុកសម្រាប់មនុស្សបួននាក់ ។ សារ៉ាវី មិនហូបរបបរបស់គាត់ទេ ព្រោះចង់ទុកឲ្យឪពុកដែលឈឺ ។ មនុស្សម្នាគ្រប់កងទាំងអស់រួសរាន់រត់ទៅប្រជុំនៅវត្តនិគ្រោធ ដោយគ្មាននរណាម្នាក់ដើរឡើយ ។

នៅពេលទៅដល់កន្លែងអង្គប្រជុំ ប្រជាជនទាំងអស់ត្រូវឈរតាមកងរៀងៗខ្លួន បន្ទាប់មកមេឃុំឈ្មោះ ខែម ឡើងនិយាយក្នុងអង្គប្រជុំថា «យប់មិញយើងចាប់បានខ្មាំងស៊ីរូងផ្ទៃក្នុង យើងត្រូវតាមរកខ្សែរយៈយកមកកម្ទេចចោល» ។ នៅក្នុងអង្គប្រជុំ សារ៉ាវី ដើរកាត់តាមកងផ្សេងៗដើម្បីសួររកឪពុក តែគ្មាននរណាម្នាក់ដឹងថាឪពុកគាត់នៅទីណាទេ ។ នៅពេលប្រជុំចប់ សារ៉ាវី បានដើរតាមមីងៗ ដែលនៅកងនារីក្នុងបំណងដើម្បីស៊ើបសួររកម្តាយ ។ មួយ

រយៈក្រោយមក សារ៉ាវី ឃើញម្តាយគាត់នៅលើផ្ទះមួយ ហើយគាត់ក៏សួរថា «ម៉ែម៉េចបានជាមិនទៅប្រជុំ? ហើយប៉ាទៅណាហើយ?» ម្តាយគាត់ឆ្លើយតបទាំងទឹកភ្នែកថា «ប៉ាឯងគេយកទៅរៀនសូត្រហើយ» ។ សារ៉ាវី និងម្តាយគាត់ស្រែកយំទាំងអស់គ្នា ។ ខណៈនោះ មីងម្នាក់ដែលស្នាក់នៅក្នុងផ្ទះជាមួយម្តាយគាត់ហាមថា កុំយំប្រយ័ត្នអង្គការសម្លាប់ទាំងម៉ែទាំងកូន ។ ស្តាប់ឮដូច្នេះ សារ៉ាវី និងម្តាយក៏ឈប់យំ បន្ទាប់មកម្តាយគាត់ក៏ទៅសុំបាយពីសហករណ៍មកឲ្យគាត់ហូប ។

ចំណែកប្អូនស្រីរបស់ សារ៉ាវី នៅកងកុមារបានអេះក្បាលរហូតកើតដំបៅរលួយ និងមានដង្កូវថែមទៀតផង ។ ម្តាយ សារ៉ាវី ខឹងសម្បារយ៉ាងខ្លាំង ហើយបានស្តីបន្ទោសឲ្យប្រធានកង រួចក៏យកថ្នាំចុក និងកំបោរបិតលើដំបៅរបស់កូនដោយខ្លួនឯង ។ ក្រោយពីបានដឹងរឿងរ៉ាវនេះហើយ សារ៉ាវី បានត្រឡប់ទៅនៅកងវិញ ដោយគាត់ត្រូវបានបញ្ជូនឲ្យទៅជីកទំនប់តាអ៊ឹ (នៅម្តុំប្រឡាយ ១០៥) និងនៅកំពង់យោល ។ សារ៉ាវី បានផ្លាស់ប្តូរការងារជាញឹកញាប់ គឺចាប់ពីកងចល័តឃុំ ចល័តស្រុក រហូតដល់កងតំបន់ ។ ថ្ងៃមួយ អង្គការបានហៅកងនារីឲ្យទៅប្រជុំនៅបន្ទប់បិទជិត រួចតាខែម បានក្រោកឈរ ហើយនិយាយថា «ស្រីៗទាំងអស់ដឹងទេថាអង្គការត្រូវការអភិវឌ្ឍ ដោយត្រូវឲ្យអ្នកទាំងអស់យកប្តី» ។ ពេលនោះ ដោយយល់ឃើញថាមិនមានអាហារហូបចុកគ្រប់គ្រាន់ សារ៉ាវី បានក្រោកឡើងតវ៉ា ជាមួយមេឃុំដោយមិនញញើតពីសេចក្តីស្លាប់ទេ ។ សារ៉ាវី បាននិយាយទៅកាន់មេឃុំ និងអង្គប្រជុំទាំងមូល ថាគាត់មានជំងឺស្ត្រីមិនអាចរៀបការបានទេ ។ ឮដូច្នេះ តាខែម អនុញ្ញាតឲ្យគាត់ទៅផ្ទះមុន ។ ការងាររបស់ សារ៉ាវី កាន់តែមានការលំបាកខ្លាំង ហើយរបបអាហារកាន់តែតិចទៅៗ ដោយសារផលស្រូវមិនសូវបានផលល្អ ហើយម្យ៉ាងទៀតកងទ័ពវៀតណាមបានវាយសម្រុកកាន់តែខ្លាំងនៅស្រុកគិរីវង្ស ។

នៅរដូវស្ទូង អង្គការចែកអង្ករពីរកំប៉ុងសម្រាប់មនុស្សដប់នាក់ ។ សារ៉ាវី មិនដែលហ៊ានតវ៉ាទេ ព្រោះឪពុកគាត់ត្រូវបានអង្គការចោទថាខ្មាំង ផ្ទុយទៅវិញគឺរឹតតែធ្វើឲ្យគាត់ខិតខំធ្វើការទ្វេដង ។ បន្ថែមលើរបបអាហារស្តួចស្តើង សារ៉ាវី រកចំណីអាហារដែលគិតថាអាចបំពេញក្រពះបានដែលគ្មានអ្វីក្រៅពីម្ទេសទេ ។ សារ៉ាវី បេះម្ទេសអាចម៍សត្វលេបចូលពោះដោយមិនខ្លាចហឹរឡើយ ។

ក្រោយមក សារ៉ាវី ត្រូវអង្គការចាត់តាំងឲ្យធ្វើការងារដាំទឹកសម្រាប់កងជីកប្រឡាយ ។ ម្តងនេះ ការងារគាត់មិនសូវលំបាកទេ តែការហូបចុកមានការខ្វះខាតដដែល ។ សារ៉ាវី ត្រូវរែកទឹកត្រពាំង និងត្រូវទៅសុំបើកថ្នាំពីខាងសង្គមកិច្ចយកមកបង់ក្នុងទឹក ។ ប៉ុន្តែមិនយូរប៉ុន្មាន កងនារីរបស់គាត់ត្រូវផ្លាស់ទៅជីកប្រឡាយនៅម្តុំផ្លូវកោះអណ្តែត ជិតព្រំប្រទល់ប្រទេសវៀតណាមវិញ ។ កាលនោះ សង្គ្រាមរវាងវៀតណាមជាមួយនឹងខ្មែរក្រហមបានផ្ទុះឡើងរាល់ថ្ងៃ សារ៉ាវី ឃើញយោធាខ្មែរក្រហមរងរបួសត្រូវបានសែងតាមខ្នងទំនប់ ។

ស្ថានភាពកាន់តែដុនដាបឡើង ប្រធានកងបានដេញកងនារីទាំងអស់ឲ្យឡើងលើទំនប់នៅម៉ោងប្រាំល្ងាច ចំណែកកងរបស់ សារ៉ាវី ដើរចុះទៅតាមផ្លូវបឹងក្បាលពោរដែលសំបូរទៅដោយឈើង ។ ខ្មែរក្រហមដេញកងនារីឲ្យរត់ទៅស្រែរនោង ។ សារ៉ាវី មិនព្រមទៅតាមការបញ្ជារបស់ខ្មែរក្រហមទេ តែគាត់បានលួចរត់ទៅជួបម្តាយនៅស្រុកត្រាំកក់វិញ ។

ក្រុមគ្រួសារ សារ៉ាវី បានជួបជុំគ្នានៅក្នុងភូមិលើកលែងតែឪពុកគាត់ ដែលត្រូវអង្គការយកទៅឃុំឃាំង និងសម្លាប់ចោលនៅគុកក្រាំងតាចាន់ ។ គ្រួសារ សារ៉ាវី ដើរតាមផ្លូវអង្គត្នោតសំដៅទៅផ្លូវជាតិលេខ៣ ក្នុងគោលបំណងវិលត្រឡប់មកស្រុកកំណើតវិញ ។ នៅតាមដងផ្លូវ មានទាហានវៀតណាមជាច្រើនត្រៀមបាញ់ខ្មែរក្រហម និងស្រែកថា «ប៉ុល ពតៗ» ពេលឃើញប្អូនប្រុសគាត់ស្លៀកពាក់ខោអាវខ្មៅដើរខាងមុខ ។ ភ្លាមនោះ ខ្ញុំបានឆ្លើយតបទៅវិញថា «មិនមែនទេ» ហើយសំណាងល្អអ្នកដំណើរជាមួយគ្នាចេះភាសាវៀតណាម រួចនិយាយប្រាប់កងទ័ពវៀតណាម ទើបវៀតណាមអនុញ្ញាតឲ្យគ្រួសារគាត់បន្តដំណើរទៅមុខទៀត ។ គ្រួសាររបស់ សារ៉ាវី បានវិលត្រឡប់ទៅរស់នៅស្រុកកំណើតវិញនៅឆ្នាំ១៩៧៩ ។ ប៉ុន្តែ ភាពសោកសង្រេង ឈឺចាប់ ការបាត់បង់ឪពុក មិនអាចរសាយពីក្រុមគ្រួសារគាត់បានឡើយ ។

**ភួង ច័ន្ទប្រណិត**

# ការិយាល័យព័ត៌មានសាធារណៈ

*“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឬសាលាក្តីខ្មែរក្រហម ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺជាឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។*

*តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ិរ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។*





















# បរិយាយជាមួយនឹងធីកដោះម្ដាយ



វ៉ាន ប៊ុ នៅសាលាក្ដីខ្មែរក្រហម

សព្វថ្ងៃមានអាយុ៤៨ឆ្នាំ និងជាក្រុមប្រឹក្សាឃុំ វ៉ាន ប៊ុ មានស្រុកកំណើតនៅស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ ។ ប៊ុ មានឪពុកឈ្មោះ តាំង វ៉ាន និងម្ដាយឈ្មោះ ឆាំ ធួន ជាអ្នកស្រែ ។ ប៊ុ មានបងប្អូនប្រាំបីនាក់ (ប្រុសប្រាំមួយនាក់ ស្រីពីរនាក់) ហើយគាត់ជាកូនទីប្រាំពីរ ។ ប៊ុ បានរៀបរាប់ព្រឹត្តិការណ៍មុននិងក្នុងរបបខ្មែរក្រហមបានយ៉ាងច្បាស់ ។ នៅប្រហែលឆ្នាំ១៩៧៣ ឬ១៩៧៤ ប៊ុ បានឮស្នូរសំឡេងគ្រាប់កាំភ្លើង គ្រាប់ផ្លោងចេញពីមូលដ្ឋានខ្មែរក្រហមចូលក្នុងភូមិរបស់គាត់ ប៉ុន្តែស្ថានភាពនៅក្នុងភូមិមិនមានសភាពផ្លាស់ប្ដូរឡើយ ប្រជាជនអាចធ្វើស្រែចម្ការបានជាធម្មតា ។ បងប្រុសច្បងរបស់ ប៊ុ ឈ្មោះ វ៉ាន យ៉េត បានចូលធ្វើទាហាន លន់ នល់ ដោយមានការអូសទាញពីទាហានម្នាក់ឈ្មោះ សេប ឈៀង ដែលជាមេទាហាន ។ កាលនោះ ឪពុករបស់ ប៊ុ ជាចុងភៅធ្វើម្ហូបឲ្យ សេប ឈៀង ហើយដោយខ្វះនីរសារ សេប ឈៀង ក៏បានយកបងប្រុសរបស់ ប៊ុ ធ្វើជានីរសាររបស់គាត់ និងមានក្របខណ្ឌពេញសិទ្ធិ ។ បងប្រុសរបស់ ប៊ុ បានដើរតាម សេប ឈៀង គ្រប់ទីកន្លែងក្នុងនាមជានីរសារនោះ ។ បងប្រុសរបស់ ប៊ុ បានបាត់ដំណឹងរហូត ក្រោយពេលដែលខ្មែរក្រហមបានទទួលជ័យជម្នះទាំងស្រុងលើរបប លន់ នល់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

ក្នុងរបបខ្មែរក្រហម ក្រុមគ្រួសាររបស់ ប៊ុ និងប្រជាជនក្នុងភូមិមិនត្រូវបានជម្លៀសទៅទីណាទេ ។ អ្នកភូមិទាំងអស់ត្រូវរស់នៅក្នុងភូមិ ប៉ុន្តែត្រូវរស់នៅតាមកងរៀងៗខ្លួន ។ ដោយស្ថិតក្នុងវ័យកុមារ ប៊ុ ត្រូវបានអង្គការបញ្ជូនទៅរស់នៅក្នុងកងកុមារដែលបានបែងចែកជាពីរកង គឺកងកុមារប្រុស និងកងកុមារស្រី ។ កុមារទាំងអស់ត្រូវរស់នៅក្នុងផ្ទះធំពីរដែលមានចម្ងាយឆ្ងាយពីគ្នាប្រមាណ២០០ម៉ែត្រ ។ ប៊ុ មិនខុសពីកុមារដទៃឡើយ ត្រូវធ្វើការងារដកស្មៅតាមសន្ទូង រើសគួរស្រូវ រែកអាចម៍គោ និងលាមកមនុស្ស កាប់ដីដំបូកកណ្ដៀរដើម្បីយកធ្វើជី ។ ប៊ុ បានយកក្រមារចងធ្វើជាកន្ត្រកសម្រាប់យួរដីដំបូករាល់ពេលដែលគាត់ទៅកាប់ដី ។ ជាញឹកញយ ប៊ុ បានដឹកនាំកុមារប្រហែល២០នាក់ ដើម្បីជួយជាកម្លាំងជំនួយដល់ការងារលើកទំនប់នៅត្រពាំងវែង ស្រុកសំរោង ខេត្តឧត្តរមានជ័យ ។ កុមារជំនួយទាំងនោះមិនត្រូវបានឲ្យធ្វើការងារធ្ងន់ធ្ងរដូចមនុស្សវ័យជំទង់ក្នុងកងចល័តឡើយ គឺគ្រាន់តែសែងដីក្នុងបង្គី ។ ដំបូងដែល ប៊ុ ដែលទៅដល់ការដ្ឋានការងារបានកត់សម្គាល់ថា ទំនប់នោះមិនទាន់មានទំហំធំនោះទេ ប៉ុន្តែពោរពេញទៅដោយលាមក ។ មួយរយៈក្រោយមក មនុស្សជាច្រើនដែលរស់នៅទីនោះចាប់ផ្ដើមរាគរូស ចុះអន់ខ្សោយកម្លាំង រួមទាំងកុមារផងដែរ ។ ប៊ុ ត្រូវដឹកនាំកុមារផ្សេងៗទៅជំនួសកុមារដែលបាក់កម្លាំង និងដឹកស្បៀងអាហារជំនួយរៀងរាល់មួយខែម្ដង ។ ដោយសារតែជាដំណាក់កាលដំបូងក្នុងការធ្វើការងារក្នុងរបប ប៉ុល ពត មនុស្សម្នាទាំងអស់មិនសូវត្រូវបានយកទៅរៀនសូត្រនោះឡើយ លើកលែងតែអ្នកទាំងនោះប្រព្រឹត្តខុសសីលធម៌លួចស្នេហារវាងមនុស្សប្រុស និងស្រី ។ នៅទីនោះក៏មានសាច់ញាតិ និងបងប្អូនបង្កើតរបស់ ប៊ុ មកធ្វើការដែរ ។ រាល់ពេលទៅការដ្ឋានលើកទំនប់ត្រពាំងវែង ប៊ុ តែងតែជួបជាមួយនឹងបងប្រុសបង្កើតឈ្មោះ វ៉ាន ប៉ែរ និងបងប្អូនជីដូនមួយឈ្មោះ វ៉ក់ ធី ។

មួយឆ្នាំក្រោយមក ប៊ុ ត្រូវបានផ្លាស់ប្ដូរឲ្យទៅឃ្វាលគោ

រយៈពីរខែជាមួយមនុស្សចាស់ និងកុមារប្អូននាក់ផ្សេងទៀត មុនពេលដែលខ្លួនត្រូវចាត់តាំងឲ្យទៅចិញ្ចឹមមាន់ ដែលកាលនោះ ប៊ិ កើតជំងឺដំបៅរលួយដូចជំងឺអុជស្វាយ នៅពេញមាត់និងជើង ។ អង្គការបានឲ្យ ប៊ិ ទៅសម្រាកនៅមន្ទីរពេទ្យដើម្បីព្យាបាលជំងឺ ។ រៀងរាល់ព្រឹក គាត់ត្រូវលេបថ្នាំប្អូនគ្រាប់ ប៉ុន្តែគាត់មិនដែលលេបថ្នាំទាំងនោះឡើយ ដោយគ្រាន់តែយកមកបង្ហាតួរួចលាក់ទុកក្នុងថតតុវិញ ។ មិនមានការដាក់ទណ្ឌកម្មចំពោះការដែលមិនលេបថ្នាំនោះទេសម្រាប់កុមារ ខ្មែរក្រហមបានត្រឹមតែស្តីឲ្យប៉ុណ្ណោះ ។ ក្នុងភូមិគោកខ្ពស់ទាំងអស់ មានកុមារក្នុងកងចល័តទាំងស្រី និងប្រុសប្រមាណ៣០០ទៅ៤០០នាក់ ។ ការហូបចុកក្នុងកងកុមារនៅក្នុងភូមិមិនបានគ្រប់គ្រាន់ទេ ។

បន្ទាប់ពីនោះមក ប៊ិ ត្រូវបានចាត់តាំងទៅរស់នៅក្នុងកងកុមារក្នុងព្រៃចម្ងាយប្រហែលប្រាំមួយគីឡូម៉ែត្រពីភូមិរបស់គាត់ ។ ប៊ិ នៅតែធ្វើការជាអ្នកធ្វើជីដដែល ។ ក្រៅពីការងារធ្វើជី ប៊ិ ត្រូវយាមយប់ចាំមើលខ្មាំង ។ កុមារទាំងអស់ ត្រូវបានបែងចែកឲ្យទៅយាមតាមទិសចំនួនបី ។ មេកងកុមារកាលនោះមានឈ្មោះថា ជ្រួន ជាអ្នកភូមិរស់នៅជាមួយនឹង ប៊ិ ។ ដោយហេតុនេះហើយ ទើបគាត់មិនតឹងតែងចំពោះក្មេងៗទាំងអស់ ប៉ុន្តែមានថ្ងៃខ្លះគាត់ក៏បានដេញវាយខ្លះដែរដោយសារក្មេងនោះបានដេកលក់នៅពេលយាម ។ គាត់ក៏ជាគ្រូបង្រៀនអក្សរសម្រាប់ក្មេងដែរ ។ ក្មេងៗទាំងអស់ត្រូវយាមចាំមើលខ្មាំង តែតាមពិត សុទ្ធតែប្រជាជនសាមញ្ញទាំងអស់ដែលផ្សងគ្រោះថ្នាក់ ឆ្លងកាត់ភូមិរបស់ ប៊ិ រត់សំដៅទៅប្រទេសថៃ ។

ប៊ិ បានមើលឃើញទិដ្ឋភាពដេញចាប់ខ្មាំងដោយកងចល័តមានគ្នា២០នាក់ ។ កងចល័តទាំងនោះ បានដេញព័ទ្ធចាប់ខ្មាំង (ប្រជាជនសាមញ្ញ) ដូចជាការដេញចាប់សត្វជ្រូកដូច្នោះដែរ ។ ប៊ិ បានឃើញមនុស្សដែលត្រូវចោទថាខ្មាំងត្រូវចងស្លាបសេកនៅក្រោមដើមឈើ នៅពេលគាត់ទៅមើលការសម្តែងសិល្បៈរឿង "យុទ្ធមិត្តសាយ" ។ ក្រៅពីនេះ បងប្អូនជីដូនមួយម្នាក់ឈ្មោះ បេង អាយុប្រហែល៣២ឆ្នាំ មានកូនពីរនាក់ ត្រូវបានអង្គការយកទៅរៀនសូត្រ ដោយសារតែគាត់ធ្លាប់ធ្វើជាទាហានសម័យ លន់ នល់ ។ ខ្មែរក្រហមបានមកយក បេង ទៅរៀនសូត្រខណៈពេលដែលគាត់នៅមានជំងឺជាប់នឹងខ្លួន ។ ខ្មែរក្រហមទាំងនោះ បាននិយាយថា "ឡានកំពុងតែចាំនៅខាងមុខ" ។ ម្តាយរបស់ បេង ប្រកែកយ៉ាងខ្លាំងថា "កូនរបស់គាត់កំពុងតែមានជំងឺ មិនគួរយកគេទៅរៀនសូត្រនោះទេ" ប៉ុន្តែ ខ្មែរក្រហមមិនយល់ព្រមតាមសំណើរបស់គាត់ឡើយ ។

អាការជំងឺរបស់ ប៊ិ មិនបានធូរស្បើយទេ ហើយដំបៅរលួយនោះ ធ្វើឲ្យឈឺរីតតែខ្លាំងជាងមុន រហូតដល់ហើមស្នូងជើង ដូច្នេះ ឪពុករបស់គាត់បាននាំគាត់ទៅកាប់ដើមត្បែងដើម្បីសម្រឹកយកទឹកមកឲ្យគាត់ផឹកដើម្បីព្យាបាលជំងឺ ។ នៅទីនោះ ឪពុករបស់ ប៊ិ បានចង្អុលបង្ហាញពីរណ្តៅដែលកប់បងជីដូនមួយឈ្មោះ បេង នោះ ។ គាត់ត្រូវបានសម្លាប់ដោយអារក រួចយកទៅកប់អង្គុយនៅក្នុងរណ្តៅតូចនោះ ។ បន្ទាប់ពីបានផឹកទឹកត្បែងបានមួយសប្តាហ៍ ប៊ិ ក៏ជាសះស្បើយពីជំងឺ ។ នៅក្នុងកងកុមារ ប៊ិ ទទួលបានបាយមួយកូនចានចង្កឹះ ហើយមិនបានគ្រប់ពេលទេ ដូច្នេះហើយ ការហូបចុកមានការខ្វះខាត ។ តែជាសំណាងល្អ ពេលដែលម្តាយរបស់ ប៊ិ ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅកន្លែងថ្មី គឺពីការងារតម្បាញទៅដកស្ទូងវិញ ។ គាត់ទទួលបានរបបបបរពីរចាន ។ គាត់ហូបតែមួយចាន ហើយទុកមួយចានសម្រាប់ ប៊ិ ។ គាត់បានយកបបរលាយជាមួយនឹងទឹកដោះគាត់ រួចយកទៅដុតដូចអន្សមផ្ញើឲ្យ ប៊ិ ជារៀងរាល់ថ្ងៃ ។ ក្រៅពីនេះ ឪពុករបស់ ប៊ិ បានយកបាយដែលគាត់ដាំជាមួយនឹងអង្ករពីរកំប៉ុងសម្រាប់របបអាហារប្រចាំថ្ងៃនោះទុកពាក់កណ្តាលសម្រាប់ផ្ញើប៊ិដងដែរ ។

នៅចុងឆ្នាំ១៩៧៨ កងកុមាររបស់ ប៊ិ ត្រូវបានឲ្យទៅជួបជុំជាមួយនឹងក្រុមគ្រួសាររបស់ខ្លួននៅក្នុងភូមិវិញ ។ ខ្មែរក្រហមមិនបាននិយាយអ្វីក្រៅពីការអនុញ្ញាតឲ្យទៅរស់នៅជាមួយគ្រួសារឡើយ ។ មេខ្មែរក្រហមទាំងអស់បានរត់គេចខ្លួនបាត់ ។ ខ្លះរត់ចូលព្រៃ ហើយខ្លះទៀតរត់ទៅទិសខាងលិចសំដៅទៅប្រទេសថៃ ។ ទ័ពវៀតណាមបានវាយបែកក្រុងភ្នំពេញ ។ ព័ត៌មាននេះបានលេចឮដល់មេខ្មែរក្រហមនៅភូមិរបស់ ប៊ិ រហូតដល់មេដឹកនាំទាំងនោះរត់គេចខ្លួន ។ បងប្រុសបង្កើតម្នាក់ឈ្មោះ វ៉ាន សុវណ្ណ និង ប៊ើយ ដែលជានីរសាររបស់មេខ្មែរក្រហមមួយរូប បានយកខោអាវមេរបស់គាត់ទៅលាក់ទុកនៅលើផ្ទះរបស់ ប៊ិ ដោយសារចង់លាក់

បាំងប្រវត្តិរូប ខណៈពេលដែលមេរបស់ខ្លួនលាក់ខ្លួននៅក្នុងព្រៃ ។ ប្រមាណមួយខែក្រោយមក មេខ្មែរក្រហមនោះបានត្រឡប់មកវិញ រួចសួរ ប៊ើយ ថា "យកខោអាវអញទៅណា?" ។ ភ្លាមនោះ ប៊ើយ ថាយកទៅទុកនៅលើផ្ទះ សុវណ្ណ ។ ឮដូច្នេះ មេខ្មែរក្រហមនោះ បានដកកាំភ្លើងបាញ់សម្លាប់ ប៊ើយ នៅហ្នឹងកន្លែងតែម្តង ហើយបានបញ្ជាឲ្យឪពុករបស់ ប៊ុ អូសខ្មោចយកទៅបោះចោល ។ មេខ្មែរក្រហមនោះ មានបំណងចង់សម្លាប់បងរបស់ ប៊ុ ឈ្មោះ សុវណ្ណ ទៀត តែគាត់បានរត់គេចខ្លួនបាត់រហូតដល់ទ័ពវៀតណាមបានចូលមកដល់ក្នុងភូមិ ។ នៅពេលទាហានវៀតណាមមកដល់ ឪពុករបស់ ប៊ុ អរយ៉ាងខ្លាំងហើយប្រាប់ ប៊ុ ថា "កូន! នេះជាទេវតាមករំដោះយើងហើយ" ។ ក្រោយពីដាំបាយហូបរួច ទ័ពវៀតណាមបានបោះទីតាំងនៅជាយភូមិដើម្បីការពារការវាយប្រហាររបស់ខ្មែរក្រហម ។

នៅវេលាម៉ោងបីរសៀល ខ្មែរក្រហមបានបើកការវាយប្រហារមកលើកងទ័ពវៀតណាមរយៈពេលពីរយប់ពីរថ្ងៃ ។ ខ្មែរក្រហមបានបាញ់ផ្លោងចូលមកក្នុងភូមិ បណ្តាលឲ្យឆេះផ្ទះជាច្រើនខ្នង ។ ផ្ទះរបស់ ប៊ុ រងការបំផ្លិចបំផ្លាញយ៉ាងដំណំ ។ ក្រុមគ្រួសាររបស់ ប៊ុ ទាំងអស់បាននាំគ្នាទៅស្នាក់នៅក្នុងលេណដ្ឋាន លើកលែងតែឪពុករបស់ ប៊ុ ដែលក្លាហានហ៊ានឡើងប្រក់ស្លឹកលើដំបូលផ្ទះ និងដេកក្រោមផ្ទះ ។ ក្រោយមក ទើបខ្មែរក្រហមដកទ័ពចេញ ។ ប៊ុ បានចងចាំថា មុនពេលដែលទាហានវៀតណាមមកដល់ ខ្មែរក្រហមបានបើកត្រាក់ទ័រប្រមាណ៣០០គ្រឿង សំដៅទៅប្រទេសថៃ ដើម្បីគេចខ្លួនពីវៀតណាម ។ ស្ថានភាពនៅក្នុងភូមិក៏ទទួលបានសន្តិសុខចាប់ពីពេលនោះមក ក៏ប៉ុន្តែទ័ពវៀតណាមបានជម្លៀសប្រជាជនទៅរស់នៅភូមិទន្លេសមួយរយៈ ហើយបីខែក្រោយមកទើបអនុញ្ញាតឲ្យប្រជាជនទាំងនោះត្រឡប់មករស់នៅក្នុងស្រុកភូមិវិញ ។

ជាចុងក្រោយ ប៊ុ បានបង្ហាញពីចំណាប់អារម្មណ៍ក្នុងការមកចូលរួមសវនការលើកទីមួយនេះថា គាត់មិនសូវយល់ដឹងច្រើនពីនីតិវិធីរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ ។ ប៉ុន្តែគាត់ចង់ដឹងថាតើនរណានៅពីក្រោយការសម្លាប់មនុស្សរាប់លាននាក់ ។ រីឯចំណាប់អារម្មណ៍ផ្ទាល់សម្រាប់ការមកទស្សនាមន្ទីរស-២១ ឬគុកទួលស្លែង ប៊ុ បានសម្តែងភាពសោកសង្រេងពេលដែលមើលឃើញកន្លែងធ្វើទារុណកម្ម ។ ខណៈនោះ ប៊ុ ក៏បានដើរសម្លឹងរកមើលរូបថតបងប្រុសបង្កើតរបស់គាត់ឈ្មោះ វ៉ាន យ៉េត ដែលជាអតីតទាហានលន់នល់ដែរ ។ **ភួង ច័ន្ទប្រណិត**

# ដំណឹងស្វែងរកប្អូន

នាងខ្ញុំឈ្មោះ ហង្ស ហួន និងប្តីឈ្មោះ សរ មឿន រស់នៅភូមិត្រពាំងសំរិត សង្កាត់គងនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ នាងខ្ញុំសូមប្រកាសរកប្អូនពីរនាក់ គឺ ៖ ◆ ប្អូនស្រី ហង្ស ហ៊ឹម និងប្តីឈ្មោះ មុំ ភឺន ។ អ្នកទាំងពីរមានកូនបួននាក់ ទី១) ស្រីញឹប, ទី២) សុភី, ទី៣) សុផាត និង ទី៤) អាចក់ ◆ ប្អូនប្រុស ហង្ស សំណាង ហៅ ក្រឹម និងប្រពន្ធឈ្មោះ សយ ឃឿន ។ អ្នកទាំងពីរមានកូនពីរនាក់ ទី១) ណាក់ និង ទី២) ណូត ។

សូមបញ្ជាក់ថា គ្រួសារប្អូនៗទាំងពីរបែកគ្នាជាមួយនាងខ្ញុំនៅម្តុំអូរបែកក្អមក្នុងឆ្នាំ១៩៧៥ ក្រោយពេលដែលខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ ។ ក្រោយមកនាងខ្ញុំឮដំណឹងថា គ្រួសារប្អូនទាំងពីរត្រូវខ្មែរក្រហមជម្លៀសទៅខេត្តបាត់ដំបង ហើយក៏បាត់ដំណឹងរហូតមកដល់ពេលនេះ ។

អាស្រ័យហេតុនេះ បើបងប្អូនណាបានដឹង ឬស្គាល់ឈ្មោះដែលបានរៀបរាប់ខាងលើសូមទំនាក់ទំនងតាមរយៈអាសយដ្ឋានផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬតាមរយៈទូរស័ព្ទលេខៈ ០ ១៦ ៨៩៦ ៦៩២ ។ ***សូមអរគុណ!***

គម្រោងឃ្លាំមើលតុលាការខ្មែរក្រហម
CAMBODIA TRIBUNAL MONITOR
តាមដានដំណើរកាត់ទោស ករណី០០២ រៀងរាល់ថ្ងៃ
ចាប់ពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ តទៅ
សូមចុច www.cambodiatribunal.org

# បានត្រឹមតែដឹង

នៅក្នុងវ័យ១២ឆ្នាំ ក្នុងរបបខ្មែរក្រហម ព្រហ្ម ដារី បានចងចាំនូវរឿងរ៉ាវជាច្រើនរបស់ក្រុមគ្រួសារ និងរឿងរ៉ាវដែលគាត់បានឆ្លងកាត់ ។

ដារី កើតនៅភូមិថ្មី ឃុំត្រពាំងស្តៅ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។ ដារី មានឪពុកឈ្មោះ ព្រហ្ម ថៃ អាយុ៧០ឆ្នាំ និងម្តាយឈ្មោះ សារ៉ាន់ណើ អាយុ៧១ឆ្នាំ បច្ចុប្បន្នធ្វើជាមេភូមិ ។ ដារី ជាកូនប្រុសទោលនៅក្នុងគ្រួសារ ។

កាលពីកុមារ ដារី មិនបានចូលរៀនទេ ព្រោះគាត់មិនហ៊ានដើរឆ្លងកាត់ព្រៃទៅរៀនសាលាបឋមសិក្សាចន្ទ្រីដែលមានចម្ងាយប្រមាណជាងមួយគីឡូម៉ែត្រពីផ្ទះរបស់គាត់ ។ ដារី រស់នៅជាមួយឪពុកម្តាយរហូតដល់ឆ្នាំ១៩៧៤ ទើបគាត់ចូលរៀនអក្សរជាមួយអ៊ំប្រុសរបស់គាត់ឈ្មោះ ប្រាក់ សាម៉ុត ជាគ្រូបង្រៀនក្មេងដែលមិនចេះអក្សរនៅក្នុងភូមិព្រោះពេលនោះភូមិរបស់ ដារី ត្រូវយោធាខ្មែរក្រហមចូលមកគ្រប់គ្រងហើយ ។

ខ្មែរក្រហមតែងតែជួយប្រជាជនក្នុងភូមិ ដូច្នេះហើយ ទើបឪពុកម្តាយរបស់ ដារី រួមជាមួយអ្នកភូមិស្រលាញ់ជឿជាក់ ហើយតែងតែផ្តល់ស្រូវអង្ករដែលគាត់ធ្វើបានឲ្យខ្មែរក្រហម ។ លើសពីនោះទៅទៀត ម្តាយគាត់តែងតែវេចខ្ចប់បាយ ត្រីសាច់ឲ្យយោធាខ្មែរក្រហមពេលចេញទៅវាយជាមួយទាហាន លន់ នល់ ។ ដូច្នេះហើយ ទើបខ្មែរក្រហមចាត់ទុកគ្រួសារ ដារី ជាអ្នកមូលដ្ឋាននៅពេលខ្លួនទទួលជ័យជម្នះលើទាហាន លន់ នល់ នៅឆ្នាំ១៩៧៥ ។

ដារី រស់នៅក្នុងភូមិដដែល ហើយក្រោយមកគាត់បានឃើញគ្រួសារអ្នកដែលរស់នៅភ្នំពេញ និងក្រុងស្វាយរៀងប្រមាណ៣០ គ្រួសារបានមកដល់ភូមិរបស់គាត់ ។ ប្រធានភូមិបានបែងចែកគ្រួសារមកដល់ថ្មីទាំងនោះឲ្យទៅរស់នៅជាមួយប្រជាជនមូលដ្ឋាន ហើយពេលនោះ មានអ្នកភ្នំពេញមួយគ្រួសារដែលមានប្តីបួសជាព្រះសង្ឃ និងនៅគ្រងស្បងនៅឡើយព្រះនាម ហំ បាននាំប្រពន្ធ និងកូនជំទង់របស់គាត់ពីរនាក់គឺឈ្មោះ គុម (ស្រី) និងឈ្មោះ ជៀន (ប្រុស) មករស់នៅផ្ទះរបស់ ដារី ។ ព្រះតេជគុណ ហំ ត្រូវខ្មែរក្រហមផ្សឹករយៈពេលមួយសប្តាហ៍ក្រោយពេលព្រះអង្គមកដល់ភូមិ ។

នៅពេលនោះ ខ្មែរក្រហមមិនទាន់រឹតបណ្តឹងខ្លាំងទេ គឺអនុញ្ញាតឲ្យគ្រួសារលោកតា ហំ រួមជាមួយគ្រួសារជម្លៀសទាំងអស់ដាំបាយហូបនៅតាមផ្ទះរៀងៗខ្លួន ។ ចំណែកការងារក៏ប្រធាន



ព្រហ្ម ដារី អំឡុងពេលចូលរួមសិក្ខាសាលានៅសារមន្ទីរជាតិកាលពីខែមករា ឆ្នាំ២០១៣

សហករណ៍ចាត់តាំងឲ្យអ្នកថ្មីធ្វើការដូចឪពុកម្ដាយ ផារី និង អ្នកមូលដ្ឋានផ្សេងទៀតដែរគឺច្រូតកាត់ ដក ស្ទូង លើកភ្លឺស្រែ ជីក ប្រឡាយ ភ្ជួរ និងកាប់ដីដឹកបូកលាយជាមួយលាមកសត្វ និងលាមក មនុស្សធ្វើជីដាក់ស្រែ ។

ចំណែក ផារី ប្រធានភូមិឲ្យចូលរៀនអក្សរនៅសាលា (ដែលពីមុនជារោងសិប្បកម្មក្នុងភូមិ) ជាមួយកូនអ្នកមូលដ្ឋាន និងក្មេងដែលទើបមកដល់ថ្មីផ្សេងទៀត ដែលភាគច្រើនមានអាយុ ក្រោមដប់ឆ្នាំ ។ ផារី ត្រូវមករៀនមួយថ្ងៃបីម៉ោងជាមួយគ្រូដែល ចេះអានអក្សរបន្តិចបន្តួចប៉ុណ្ណោះ ។ បន្ទាប់ពីរៀនចប់ គ្រូបានដាក់ ការងារឲ្យ ផារី និងសិស្សទាំងអស់យកស្បោងម្នាក់មួយ រួចហើយឲ្យ ដើរប្រមូលអាចម៍គោ ក្របីមកលាយជាមួយដើមទន្រ្ទានខែត្រ ធ្វើជី ។

ក្រោយមកដោយសារ ផារី ធុញទ្រាន់នឹងការបង្រៀន បែបនេះ គាត់ក៏ឈប់ទៅរៀន ហើយមិនយូរប៉ុន្មានសាលាក៏បិទទ្វារ ដែរ ។ ផារី ត្រូវប្រធានកងចាត់តាំងឲ្យទៅឃ្វាលក្របីវិញ ។ ផារី មិន សូវបានជួបមុខឪពុកញឹកញាប់ទេ ព្រោះឪពុកគាត់ត្រូវខ្មែរក្រហម ចាត់តាំងឲ្យទៅជីកព្រែកជម្រៅ១០ម៉ែត្រ ភ្ជាប់ពីឃុំជ្រៃ ស្រុក រមាសហែក ទៅហែកសំណាញ់ ស្ថិតនៅស្រុករំដួល ហើយទាល់តែ ចប់ការងារទើបឪពុកគាត់ត្រឡប់មកលេងផ្ទះ ។

មកដល់ដើមឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្ដើមប្រមូល សម្ភារ និងរបស់របរប្រើប្រាស់មកដាក់រួម និងប្រមូលប្រជាជន ទាំងអស់មកហូបបាយរួមនៅរោងសហករណ៍ (ភូមិថ្មី) ដែលជា ញឹកញាប់មានតែសម្លម្ជូរព្រលិត ត្រកួនប៉ុណ្ណោះ ។ ថ្ងៃមួយពេល កំពុងហូបបាយ ផារី ឃើញលាមកនៅជាប់នឹងដើមត្រកួនតែម្ដង ដោយសារតែចុងភៅខ្ជិលលាងសម្អាត ។ ដូច្នេះហើយទើបម្ដាយ ផារី តែងតែលួចយកបាយក្រៀម អំបិល ស្ករ ដែលគាត់លួចលាក់ បានមកធ្វើហូបនៅផ្ទះវិញ ។ ប៉ុន្តែគាត់មិនដែលហ៊ានឲ្យអង្គការ ដឹងឡើយ ទោះបីគាត់ជាអ្នកមូលដ្ឋានក៏ដោយ ។

មានពេលមួយ ដោយសារ ឪពុក ផារី ចូលចិត្តជក់បារី គាត់ក៏ដើរទៅសុំបារីពីប្រជាជននៅក្នុងភូមិ ស្រាប់តែខ្មែរក្រហម ឃើញ រួចហើយបានចោទគាត់ថា "ដើរសេរី" ព្រមទាំងគំរាមយក ឪពុកគាត់ទៅរៀនសូត្រទៀត ។ ចាប់តាំងពីពេលឮពាក្យនោះមក ឪពុកគាត់ភិតភ័យរហូត ។ ស្របពេលនោះ ផារី ក៏បានឃើញ ខ្មែរក្រហមដឹកកងយោធាដែលរងរបួស និងប្រជាជនដែលឈឺ ដោយសារធ្វើការងារធ្ងន់ធ្ងរ និងខ្វះអាហារហូបមកព្យាបាលនៅ មន្ទីរពេទ្យ (តំបន់) ដែលស្ថិតនៅទល់មុខនឹងផ្ទះរបស់គាត់ ។ ចំពោះ អ្នកដែលព្យាបាលមិនជា និងស្លាប់ ខ្មែរក្រហមបានដឹកចេញនៅ ពេលយប់ដើម្បីកុំឲ្យប្រជាជនឃើញ ។

មកដល់ឆ្នាំ១៩៧៨ ខ្មែរក្រហមចាប់ផ្ដើមធ្វើការជម្លៀស ប្រជាជនថ្មី រួមទាំងគ្រួសារ តាហំ ឲ្យទៅរស់នៅខេត្តកំពង់ចាម ។ ក្រោយមកទើបជម្លៀសគ្រួសារ ផារី មកឈប់នៅអ្នកលឿង រួចហៅឈ្មោះឪពុកម្ដាយគាត់ឡើងជិះកប៉ាល់បន្តមកច្បារអំពៅ ។ នៅទីនោះ ខ្មែរក្រហមបានចែកក្រមា និងខោអាវឲ្យម្នាក់មួយកំប្លេ ព្រមទាំងចែកត្រីចំហុយឲ្យហូបជាមួយបាយទៀត ។ ផារី មិនដែល បានហូបត្រីចំហុយ ដែលមានក្លិនឈ្ងុយនោះយូរហើយ ដូច្នេះ ហើយទើបគាត់ហូបត្រីនោះអស់យ៉ាងច្រើន រហូតដល់ស្លាក់ឆ្អឹងជាប់ នឹងករបស់គាត់ (ដែលទើបតែជាសះស្បើយនៅពេលថ្មីៗនេះ) ។

បន្ទាប់មក ខ្មែរក្រហមបានយកឡានមកដឹកគ្រួសារ ផារី កាត់តាមផ្លូវមុខរោងកុនគីរីរម្យ ស្ពានអូរឡាំពិក និងខាងមុខក្រសួង សេនាធិការដេអិន (បច្ចុប្បន្ន ក្រសួងការពារជាតិ) មកឈប់នៅ ស្ថានីយ៍រថភ្លើងដើម្បីជិះបន្តទៅខេត្តពោធិ៍សាត់ ។ ផារី បានទៅដល់ ចំណតរថភ្លើងស្វាយដូនកែវ នៅវេលាម៉ោង១០យប់ រួមជាមួយ គ្រួសារអ្នកជម្លៀសប្រមាណ១០០គ្រួសារផ្សេងទៀត ។ ព្រឹកឡើង ខ្មែរក្រហមបានបែងចែកគ្រួសារ ផារី ឲ្យទៅនៅក្នុងកូនខ្ទមមួយ ស្ថិតនៅក្នុងសហករណ៍ខ្នា ដែលមានចម្ងាយប្រមាណពីរគីឡូម៉ែត្រ ពីផ្លូវជាតិលេខ៥ ។ នៅទីនោះ ប្រធានសហករណ៍បានចាត់តាំង ឪពុកម្ដាយ ផារី និងគាត់ឲ្យទៅច្រូតស្រូវនៅព្រៃស្រោង និងឲ្យ ស្នាក់នៅទីនោះតែម្ដង ដោយទុកតែយាយរបស់គាត់ និងបងប្អូន ជីដូនមួយម្នាក់ឲ្យនៅចាំខ្ទម ។ ចំណែកគ្រួសារផ្សេងទៀតដែលបែក ចេញពីគ្រួសារ ផារី ពេលទៅដល់សហករណ៍ខ្នានោះ ត្រូវខ្មែរក្រហម យកទៅសម្លាប់នៅភូមិព្រៃផ្អាវស្ទើរទាំងអស់ ដូចជា គ្រួសារអ៊ីរបស់ គាត់ឈ្មោះ អាំ ធ្វើគ្រូបង្រៀន រួមទាំងប្រពន្ធកូនបីនាក់ និងម្ដាយ ក្មេកម្នាក់ ។

នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ នៅសហករណ៍ដែល ផារី

រស់នៅមានការច្របូលច្របល់យ៉ាងខ្លាំង ហើយបន្តិចក្រោយមកទើបឃើញនីរសាររបស់ខ្មែរក្រហមបានមកប្រាប់អ្នកនៅក្នុងសហករណ៍ទាំងអស់ឲ្យដាំបាយហូប ។ ចំណែកមេៗកងរបស់ខ្មែរក្រហមក៏ចាប់ផ្តើមរៀបចំអីវ៉ាន់ រួចហើយនាំគ្នាដឹកជញ្ជូនដាក់លើរទេះដាស្រេច ។ ដាវី មិនដឹងថាមានហេតុការណ៍អ្វីកើតឡើងនោះទេ ព្រោះគាត់នៅក្មេងពេក ។

បន្ទាប់ពីហូបបាយរួច ប្រធានកងបានមកហៅប្រជាជននៅសហករណ៍ឲ្យធ្វើដំណើរឡើងទៅភ្នំ ប៉ុន្តែឪពុករបស់ ដាវី បានបដិសេធ ដោយគាត់សម្រេចចិត្តស្នាក់នៅក្នុងសហករណ៍ដដែល ។ បន្ទាប់ពីមេកងចេញអស់ ឪពុកម្តាយ ដាវី ចាប់ផ្តើមប្រមូលស្រូវមកបុកដើម្បីទុកដាំបាយហូប ហើយព្រឹកឡើង គាត់ក៏នាំក្រុមគ្រួសារធ្វើដំណើរតាមណោយផ្លូវជាតិលេខ៥ ដើម្បីត្រឡប់មកស្រុកកំណើតវិញ ។

ពេលធ្វើដំណើរ ដាវី ឃើញខោអាវ សម្ភារ នៅរាយប៉ាយពេញផ្លូវ ហើយគាត់ក៏បានជួបនឹងរថក្រោះកងទ័ពរបស់វៀតណាមនៅស្វាយអាត់ ដែលធ្វើឲ្យគ្រួសារគាត់រឹតតែមានការភិតភ័យថែមទៀត ព្រោះគិតថានឹងមានហេតុការណ៍វាយប្រយុទ្ធគ្នាមិនខាន ។ ដាវី បានប្រញាប់ប្រញាល់ធ្វើដំណើរមកស្នាក់នៅក្នុងទីរួមខេត្តពោធិ៍សាត់បណ្តោះអាសន្ន រហូតដល់ខែមេសា ឆ្នាំ១៩៧៩ ទើបគាត់បន្តដំណើរទៅរស់នៅស្រុកកំណើតនៅខេត្តស្វាយរៀង ។

ដាវី បានចូលរៀននៅសាលាបឋមសិក្សាចន្ទ្រី រួចហើយចូលរៀនបន្តនៅវិទ្យាល័យរមាសហែក ដល់ថ្នាក់ឌីប្លូម ។ បន្ទាប់មកគាត់ប្រលងចូលធ្វើការនៅក្រសួងវប្បធម៌ និងឃោសនាការនៅភ្នំពេញ ។ បច្ចុប្បន្ន ដាវី ជាអនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត និងទទួលបន្ទុកការងារសារមន្ទីរ ។

**សោម ប៊ុនថន**

# ខ្សែភាពយន្តឯកសាររឿង "ក្បង់ទឹកទន្លេ"



"ក្បង់ទឹកទន្លេ" គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងឧបត្ថម្ភការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត "ក្បង់ទឹកទន្លេ" ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១២ហើយ ។ "ក្បង់ទឹកទន្លេ" បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាលនិងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទចុងកាត់មាត់ញក ព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះនឹងចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ នៅទូទាំងប្រទេសកម្ពុជា ដោយបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថានដើម្បីស្វែងរកដំណោះស្រាយ ។ ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទងកញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខៈ ០១២ ៥១១ ៩១៤

អ៊ីម៉ែល ៖ truthfatily.s@dccam.org គេហទំព័រ ៖ www.ariverchangescourse.com

# ម្តាយបូជាជីវិតដើម្បីកូន

នៅក្នុងរបបខ្មែរក្រហម មនុស្សមិនតិចទេដែលត្រូវខ្មែរក្រហមយកទៅសម្លាប់ដោយសារលួចដាំបាយហូប លួចពោតដំឡូង ឬបន្លែផ្សេងៗ ដើម្បីបំពេញនូវភាពស្រេកឃ្លានរបស់ខ្លួន បន្ទាប់ពីធ្វើការមួយថ្ងៃពេញ ប្តូរនឹងរបបបបររាវមួយវែក ។ មនុស្សមួយចំនួនហ៊ានប្រថុយជីវិតទៅលួចបាយ លួចដោះដូរជាមួយអ្នកដទៃនូវអាហារបន្តិចបន្តួចយកមកឲ្យគ្រួសារ ឪពុកម្តាយកូនចៅ ទោះបីជាដឹងថាការប្រព្រឹត្តបែបនេះ មានទោសស្មើនឹងខ្មាំងក្បត់អង្គការបដិវត្តន៍ ដែលត្រូវតែកម្ទេចក៏ដោយ ។ ជាក់ស្តែងម្តាយរបស់លោក សឿ គោន ត្រូវខ្មែរក្រហមសម្លាប់ព្រោះតែយកខោអាវទៅលួចប្តូរនឹងបាយក្រៀមអ្នកមូលដ្ឋាន ។

ស្ថិតក្នុងបរិវេណសាលាក្តីខ្មែរក្រហម បន្ទាប់ពីសម្រាកពីការចូលរួមសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម សឿ គោន មានអារម្មណ៍រីករាយដែលបានមកចូលរួមសវនាការនេះ ព្រោះនេះជាលើកទីមួយសម្រាប់គាត់ដែលបានមកឃើញផ្ទាល់ ។ ទឹកមុខរបស់គាត់ប្រែស្រពោនមួយរំពេច នៅពេលគាត់ឆ្លើយសំណួរអំពីដំណើរជីវិតរបស់គាត់ និងគ្រួសារក្នុងរបបខ្មែរក្រហម គាត់បានរំឭកគ្រួសៗពីជីវិតដ៏ជូរចត់មួយនេះ ។ កាលពីសម័យ លន់ នល់ គោន មានអាយុជាង១០ឆ្នាំ ក្នុងចំណោមបងប្អូនប្រុសស្រីប្រាំនាក់ និងមានឪពុកម្តាយជាកសិករ រស់នៅឃុំជើងទៀន ស្រុកចុងកាល ខេត្តឧត្តរមានជ័យ ។ គោន បានរៀនត្រឹមថ្នាក់ទី១០ (សង្គមចាស់) ប៉ុណ្ណោះ ។ ក្រោយមក ខ្មែរក្រហមក៏ចូលមកកាន់កាប់ភូមិស្រុកដែលគាត់រស់នៅ ។ មុនពេលដែលខ្មែរក្រហមចូលមកដល់បន្តិច អ្នកភូមិមួយចំនួននាំគ្នារត់ទៅនៅភ្នំគូលែន ចំណែកគោន និងគ្រួសារនាំគ្នារត់មកខាងខេត្តឧត្តរមានជ័យ ។ គាត់បានបញ្ជាក់ថា ក្រោយពេលដែលអ្នកភូមិរត់ចេញអស់ ខ្មែរក្រហមបានដុតបំផ្លាញផ្ទះក្នុងភូមិចោលទាំងអស់ ។ ក្រោយមក យោធាខ្មែរក្រហម បានបន្តវាយកាន់កាប់ខេត្តឧត្តរមានជ័យបាន ហើយក៏កៀរគ្រួសារ គោន និងអ្នកឯទៀតឲ្យត្រឡប់ទៅភូមិជើងទៀនវិញ ។ ពេលទៅដល់ភូមិ ខ្មែរក្រហមបានបញ្ជាឲ្យប្រជាជនធ្វើផ្ទះឡើងវិញ ។ ឪពុកម្តាយរបស់គាត់ត្រូវបានអង្គការចាត់តាំងឲ្យធ្វើស្រែជាមួយប្រជាជនឯទៀត ។ ចំណែក គោន និងប្អូនមិនទាន់ចាត់តាំងឲ្យធ្វើអ្វីនោះព្រោះនៅក្មេងពេក ។ ចំពោះការហូបចុកនៅពេលនោះខ្វះខាត គឺចាប់ផ្តើមហូបបបររាវ ។



សឿ គោន នៅសាលាក្តីខ្មែរក្រហម

អំឡុងឆ្នាំ១៩៧៥-១៩៧៦ ការរស់នៅក្នុងភូមិមិនទាន់ពិបាកខ្លាំងនោះទេ អង្គការអនុញ្ញាតឲ្យរស់នៅជុំគ្រួសារ មិនមានការបំបែកទេ ប៉ុន្តែនៅចុងឆ្នាំ១៩៧៦ មានការផ្លាស់ប្តូរអ្នកគ្រប់គ្រងថ្មីដែលមកពីខាងភូមិភាគនិរតី ហើយអ្នកគ្រប់គ្រងចាស់មួយចំនួនត្រូវបានសម្លាប់ និងបាត់ខ្លួន ។ ជាពិសេស ក៏មានការចាប់ខ្លួនគ្រួសារមួយចំនួនដែលធ្លាប់រត់ចេញពីភូមិជើងទៀនមុនពេលខ្មែរក្រហមចូលមកដល់ដែរ គឺធ្វើតាមការបញ្ជារបស់ប្រធានសហករណ៍ឈ្មោះ នឿន ។ ដោយដឹងដំណឹងនេះមុន ឪពុករបស់

គោន និងអ្នកភូមិមួយចំនួនបានរៀបចំផែនការរត់ទៅប្រទេសថៃ ។ ក្រោយពីការលួចរត់នេះ មិនមាននរណាម្នាក់ដឹងថាអ្នកទាំងនោះមានវាសនាយ៉ាងណានោះទេ ។ បន្ទាប់ពីការរត់គេចរបស់ឪពុកគាត់ គ្រួសាររបស់គាត់ និងគ្រួសារដែលមានអ្នកលួចរត់ផ្សេងទៀតត្រូវអង្គការចាត់ទុកថាជាគ្រួសារខ្មាំងត្រូវតែលត់ដំឲ្យបានខ្លាំងបំផុត ។ ក្រោយមកអង្គការបានជម្លៀសគ្រួសារ គោនរួមមានម្តាយនិងប្អូនពីរនាក់ទៀតមកដល់ទីរួមខេត្តសៀមរាប ។ នៅសៀមរាបបានមួយអាទិត្យ ទើបអង្គការជម្លៀសបន្តដោយដឹកតាមឡាន មកខាងស្រុកជីក្រែងវិញ ។ គោន មានប្អូនបីនាក់ តែពេលជម្លៀសចេញពីភូមិដើងទៀន ម្តាយគាត់បានយកប្អូនប្រុសគាត់ម្នាក់ទៅផ្ញើនៅនឹងបងប្អូននៅភូមិដែលត្រូវជាឪពុកមា ។ ទៅដល់ជីក្រែង មិនថាកុមារ ឬមនុស្សពេញវ័យទេគឺត្រូវធ្វើការទាំងអស់គ្នាដើម្បីប្តូរនូវបបររាវមួយវែកប៉ុណ្ណោះ ។ គោន ត្រូវអង្គការចាត់តាំងឲ្យទៅរែកដី ។ តំបន់ដែលគាត់រស់នៅនោះគឺជាកន្លែងលត់ដំខ្លាំងបំផុត ហើយពិបាករស់នៅណាស់ព្រោះគ្មានទឹក ដោយសារទីនោះនៅឆ្ងាយពីប្រភពទឹក ដូច្នេះគាត់និងម្តាយត្រូវដើរទៅភូមិក្បែរនោះដើម្បីសុំទឹកយកមកផឹក ។ អ្នកភូមិមូលដ្ឋាននៅក្បែរនោះគឺមានចិត្តល្អ តែងតែមានចិត្តអាណិតអាសូរដល់អ្នកជម្លៀសទាំងអស់ ពិសេស តែងតែលួចឲ្យបាយក្រៀម ឬម្ហូបខ្លះដល់ គោន ពេលដែលទៅសុំទឹកម្តង ។ ដោយសារលក្ខខណ្ឌរស់នៅលំបាកយ៉ាងនេះ ម្នាក់ៗចុះស្គមយ៉ាងរហ័ស ដោយសារគ្មានអ្វីបរិភោគផង គ្មានអាហារផង គឺមានមនុស្សស្លាប់ជារៀងរាល់ថ្ងៃ ។

គោនបន្តដោយសំឡេងខ្សឹកខ្សួល «ដោយនឹកសង្វេគដល់កូនដែលឈឺ និងហូបមិនគ្រប់គ្រាន់ ម្តាយខ្ញុំបានសម្រេចយកខោអាវ ដែលនៅសល់បន្តិចបន្តួចទៅដូរបាយក្រៀមនឹងអ្នកភូមិក្បែរនោះដើម្បីយកមកឲ្យកូន តែជាអកុសល អ្នកដែលទៅជាមួយគាត់ត្រូវអង្គការចាប់ខ្លួនបាន ហើយក៏រាយការណ៍ប្រាប់អង្គការពីអ្នកដែលពាក់ព័ន្ធទាំងអស់ប្រហែលដប់នាក់ ក្នុងនោះក៏មានម្តាយគាត់ដែរ» ។ ពេលនោះ អង្គការបានចាប់ខ្លួនម្តាយគាត់ និងអ្នកឯទៀតទៅដាក់នៅគុកក្នុងវត្តភ្នាព្រហ្ម ស្ថិតនៅភូមិថ្នល់លោក ។ អ្នកទោសទាំងអស់ត្រូវខ្មែរក្រហមចាប់យកទៅដាក់នៅក្នុងឃុបមួយដែលមានទំហំប្រាំម៉ែត្របួនជ្រុងដែលពីមុនជាឃ្លាំងសម្រាប់ដាក់ចានឆ្នាំងរបស់វត្ត ។ ខ្មែរក្រហមមិនបានយកទៅសម្លាប់ភ្លាមនោះទេ គឺយកទៅធ្វើទារុណកម្មដោយបង្អត់បាយ នៅរវាងពីរបីថ្ងៃម្តង ខ្មែរក្រហមយកអ្នកទោសមួយចំនួនទៅធ្វើទារុណកម្ម សួរចម្លើយរួច ទើបយកទៅសម្លាប់ក្នុងរណ្តៅរួមមួយដែលនៅក្បែរនោះ ។

គោន មិនចាំថា តើខ្មែរក្រហមបានធ្វើអ្វីខ្លះចំពោះអ្នកទោសទាំងអស់នោះទេ ។ ប្រហែលដប់ថ្ងៃបន្ទាប់ពីថ្ងៃចាប់ខ្លួនម្តាយរបស់គាត់ត្រូវខ្មែរក្រហមយកទៅសម្លាប់ ។ គាត់ដឹងរឿងនេះតាមរយៈអ្នកភូមិដែលស្គាល់គាត់ ដោយប្រាប់ថា ម្តាយរបស់គាត់ត្រូវខ្មែរក្រហមយកទៅសម្លាប់កាលពីយប់មិញនេះ ។ ដំណឹងដំណឹងនេះ ធ្វើឲ្យ គោន មានការតក់ស្លុតយ៉ាងខ្លាំង ព្រោះថា ខ្លួនបានបាត់បង់ឪពុកម្នាក់ហើយ ឥឡូវនេះត្រូវបាត់បង់ម្តាយម្នាក់ទៀតដែលជាទីពឹងចុងក្រោយ ។ មរណភាពរបស់ម្តាយគាត់ធ្វើឲ្យជីវិតគាត់កាន់តែមានភាពលំបាកវេទនា គាត់ត្រូវដើរសុំទឹក និងបាយក្រៀមខ្លះយកមកឲ្យប្អូនស្រីទាំងពីររបស់គាត់រាល់ថ្ងៃ ព្រោះបបរដែលទទួលបានគឺតិចតួចណាស់ ។ គាត់បន្តថា ការដែលដើរទៅសុំបាយអ្នកភូមិជិតខាងហូបគឺប្រថុយនឹងគ្រោះថ្នាក់ណាស់ បើឈ្លប ឬប្រធានកងកុមារចាប់បាន នោះនឹងពិបាកខ្លួនមិនខាន ។ មានពេលមួយ កងឈ្លបចាប់បានកុមារមួយចំនួនដែលគេចពីការងារដើរសុំអាហារអ្នកភូមិក្បែរខាងហូប ឈ្លបបានចងកុមារទាំងនោះជាខ្សែ ហើយឲ្យរត់តាមកង់របស់ខ្លួនជុំវិញវត្តភ្នាព្រហ្ម ។ កុមារខ្លះត្រូវយកទៅសម្លាប់ ហើយការសម្លាប់នេះគឺធ្វើឡើងនៅពេលយប់ស្ងាត់ទៀតផង កុមារខ្លះទៀតត្រូវស្លាប់តាមភ្លឺស្រែដោយសារការធ្វើការហួសកម្លាំង និងអត់ឃ្លាន ។ ភ្នែកសម្លឹងទៅមើលកញ្ចក់ទូរទស្សន៍ ដែលដាក់បញ្ចាំងការផ្សាយផ្ទាល់សវនាការតុលាការខ្មែរក្រហម គោន បន្តថា ទិដ្ឋភាពទាំងឡាយដែលកើតឡើងនៅពេលនោះគឺដក់ជាប់នៅក្នុងអារម្មណ៍របស់គាត់ជានិច្ច ជាពិសេសគឺការពលីជីមហិមារបស់ម្តាយគាត់ ព្រោះតែចង់ឲ្យកូនទាំងអស់បានហូបឆ្អែត សុខចិត្តប្រថុយជីវិតយករបស់ទៅប្តូរនឹងបាយក្រៀមបន្តិចបន្តួចយកមកឲ្យកូន ។ គាត់ និងប្អូនៗក៏ទទួលរងនូវការប្រមាថពីសំណាក់កម្មាភិបាលខ្មែរក្រហម និងក្មេងៗកូនអ្នកមូលដ្ឋានមួយចំនួនដែលជៀលត្មិះគាត់ថាជា «កូនខ្មាំង» ។

អំឡុងឆ្នាំ១៩៧៨ ថ្ងៃមួយ ពេលដែល គោន លួចចេញ

ទៅសុំបាយអ្នកភូមិដូចសព្វដង ពេលត្រឡប់មកខ្ទមវិញក៏បាត់ប្អូនស្រីទាំងពីរ ។ ក្រោយមកទើបគាត់ដឹងថា អង្គការបានចេញបញ្ជាឲ្យរំសាយអ្នកដែលនៅភូមិនេះឲ្យទៅរស់នៅជាមួយប្រជាជននៅតាមភូមិស្រុកដទៃ ។ ពេលដែលដឹងថាបាត់ប្អូនដោយមិនដឹងថាអង្គការជម្លៀសទៅខាងណា គោន ហាក់បីដូចជាបាត់បង់ស្មារតីមិនដឹងត្រូវធ្វើបែបណា ចេះតែដើរគ្មានទិសដៅរហូតដល់ក្បែរវត្តភ្នាព្រហ្ម កន្លែងដែលម្ដាយរបស់គាត់ត្រូវសម្លាប់ ក៏បានសុំគ្រួសារអ្នកមូលដ្ឋានមួយនៅជាមួយដែលមានប្ដីឈ្មោះ គួរ និងប្រពន្ធឈ្មោះ នី ។ អ្នកទាំងពីរមានចិត្តអាណិតគាត់ដែលគ្មានញាតិមិត្តក៏ទទួលគាត់ឲ្យរស់នៅជាមួយ ដោយចាត់ទុកគាត់ជាកូនបង្កើត ប៉ុន្តែមិនបានប៉ុន្មានផង អង្គការក៏បញ្ជាឲ្យកងឈ្លបតាមចាប់អ្នកដែលជាប់និន្នាការជាគ្រួសារនាយទុន ឬ ខ្មាំង គោន ក៏ត្រូវអង្គការចាប់ខ្លួនដែរដោយចោទថាជាកូនខ្មាំងព្រោះតែឪពុកលួចរត់ ។ ពេលនោះ ទោះបីជាមានការអង្វរកពីឪពុកម្ដាយចិញ្ចឹមរបស់គាត់ថាគាត់នៅតូចណាស់ឲ្យទុកនៅទីនេះហើយ និងឲ្យជួយលាក់គាត់ម្នាក់ ក៏ឈ្លបនោះមិនយល់ព្រមដែរ ហើយថែមទាំងឆ្លើយថាទោះបីជាក្មេងក៏មិនអាចលើកលែងឲ្យដែរ នេះជាបញ្ជាអង្គការ ។

គោន ត្រូវអង្គការបញ្ជូនចូលទៅក្នុងកងចល័តដែលអង្គការចាត់ទុកថាកងចល័តកសាងព្រោះអ្នកទាំងអស់នៅកងចល័តនោះមិនថាក្មេង ឬចាស់ សុទ្ធសឹងតែជាប់និន្នាការនាយទុននិងអ្នកដែលមានសមាជិកគ្រួសារលួចរត់ ដូច្នេះអង្គការត្រូវតែលត់ដំ កសាងឲ្យខ្លាំងបំផុត ។ នៅកងចល័តរបស់ គោន កុមារជាច្រើនត្រូវបង្ខំឲ្យរែកដី លើកភ្លឺស្រែ ហើយកន្លែងខ្លះត្រូវកាយដីភក់បិទភ្លឺស្រែដោយប្រើដៃ ហើយកំណត់ប្រវែងឲ្យធ្វើទៀតផង ដោយម្នាក់ធ្វើប្រហែលប្រាំបួនម៉ែត្រក្នុងមួយថ្ងៃឲ្យហើយ ទើបឲ្យហូបបបរ ។ ជាពិសេស ខ្មែរក្រហមបានគំរាមថា បើធ្វើមិនហើយតាមផែនការទេ មិនត្រឹមតែគ្មានបបរនោះទេ គឺយកទៅវាយចោលតែម្ដង ។ គោន បញ្ជាក់ថា កុមារទាំងអស់នៅពេលនោះគឺសាមគ្គីគ្នាខ្លាំងណាស់ អ្នកដែលធ្វើហើយគឺមកជួយធ្វើអ្នកដែលមិនទាន់ធ្វើហើយ ។ ប្រកបដោយទឹកមុខក្រៀមក្រំ គាត់បន្តថា ខ្ញុំដួលសន្លប់ជាច្រើនដងអំឡុងពេលធ្វើការនោះ ដោយសារឃ្លានផង និងគ្មានកម្លាំងសូម្បីតែបន្តិច តែដោយសារខ្លាចខ្មែរក្រហមសម្លាប់ទើបខំប្រឹងទាំងត្រដាបត្រដួសយ៉ាងនេះ ។

ក្រោយពីបញ្ចប់តាមផែនការ អង្គការបានបញ្ជាឲ្យប្រមូលកុមារទាំងអស់យកមកខាងស្រុកដីក្រែងវិញ ។ កុមារនៅពេលនោះ ភាគច្រើនអង្គការចាត់តាំងឲ្យរែកដី វាយថ្ម ចំណែក គោន ស្ថិតក្នុងក្រុមកើបខ្សាច់ និងវាយថ្ម ដែលមានសមាជិកដប់ពីរនាក់ ។ ចំណែកការហូបចុកគ្រាន់បើជាងការដែលរស់នៅកងចល័តកសាង ដោយមានបបរខាប់បន្តិច ព្រោះមានគ្នាមិនច្រើនដូចកាលនៅកងចល័តកសាងនោះទេ ។ នៅឆ្នាំ១៩៧៩ ពេលកំពុងធ្វើការ គោន ឮសំឡេងគ្រាប់កាំភ្លើងមិនដឹងជាបាញ់មកពីខាងណានោះទេ តែនៅក្នុងពេលនោះមានភាពជ្រួលច្របល់ ហើយឃើញម្នាក់ៗនាំគ្នារត់ គាត់ក៏រត់មករកឪពុកម្ដាយចិញ្ចឹមគាត់វិញ ហើយក៏បានជួបប្អូនស្រីរបស់គាត់ដែលបានបែកគ្នាអំឡុងពេលដែលអង្គការរំសាយភូមិ តែជាអកុសលប្អូនស្រីតូចរបស់គាត់ម្នាក់បានស្លាប់ដោយសារបាក់ទឹកដោះ និងកើតដំបៅផាររនៅក្បាល ។

ក្រោយរបបខ្មែរក្រហម ប្រហែលឆ្នាំ១៩៨១ ឪពុករបស់ គោន ដែលរត់ទៅថៃបានត្រឡប់មកវិញ ហើយរកឃើញប្អូនប្រុសម្នាក់ដែលម្ដាយគាត់ផ្ញើនឹងបងប្អូននៅភូមិមុនពេលចាកចេញពីភូមិដើងទៀន និងក្រោយពីដើរស៊ើបសួរដំណឹងពីគាត់តាមភូមិទើបបានមករក គោន ឃើញនៅឃុំដីក្រែងនេះ ជាមួយនឹងប្អូនស្រីគាត់ម្នាក់ទៀត ។ ពេលដែលមកដល់ក៏មិនបានជួប គោន ភ្លាមទេ ព្រោះគាត់បានទៅរកត្រីជាមួយឪពុកចិញ្ចឹម រហូតដល់ព្រលប់ទើប គោន មកដល់ផ្ទះហើយឃើញមុខឪពុកបង្កើត មើលស្ទើរតែមិនស្គាល់ ព្រោះបែកគ្នាយូរពេក តែគាត់នៅចំណាំស្នាមដៅដែលនៅលើថ្ពាសឪពុក ទើបគាត់ដឹងថា បុរសម្នាក់នេះជាឪពុករបស់គាត់ដែលគាត់ធ្លាប់បានគិតថាស្លាប់បាត់ទៅហើយ ។ អ្នកទាំងបួនរកពាក្យអ្វីនិយាយមិនបានក្រៅពីយំឱបគ្នាដោយក្ដីនឹករព្ទកនោះទេ ។ បន្ទាប់មក គោន ក៏បានជម្រាបសុំលាឪពុកម្ដាយចិញ្ចឹមមករស់នៅជាមួយឪពុកបង្កើត និងបងប្អូនប្រុសស្រីនៅភូមិដើងទៀន ឃុំដើងទៀន ស្រុកចុងកាល ខេត្តឧត្ដរមានជ័យ រហូតដល់បច្ចុប្បន្ន ។ សព្វថ្ងៃនេះ សឿ គោន មានប្រពន្ធ និងកូនប្រុសស្រីបួននាក់ ហើយប្រកបរបរជាកសិករ ។

**ឆាយ សារៈមុនិន្ទ**

# ឈាយនឹងសង្គ្រាម អតីតយោធាខ្មែរក្រហមម្នាក់ គ្មានចង់បានអ្វីក្រៅពីសន្តិភាព

ឆ្លងកាត់បទពិសោធសង្គ្រាមអស់រយៈពេលជិតម្ភៃឆ្នាំ អតីតយោធាខ្មែរក្រហមឈ្មោះ សំ ភិន លែងចង់បានអ្វីទាំងអស់ ក្រៅតែពីសន្តិភាពនិងការរួបរួមគ្នានៅក្នុងសហគមន៍ដែលគាត់កំពុងរស់នៅ និងប្រទេសជាតិទាំងមូល ។ ភិន បញ្ជាក់ថា សង្គ្រាមមិនផ្តល់ផលប្រយោជន៍អ្វីទាំងអស់ និងគ្មានផលចំណេញអ្វីទេ ហើយថា រូបគាត់ផ្ទាល់បានតស៊ូនិងសង្គ្រាមអស់ជាច្រើនឆ្នាំទីបំផុតគ្មានសេសសល់អ្វីទាំងអស់ ការមានជីវិតរស់គឺជាភពសំណាងបំផុតក្នុងនាមជាយុទ្ធជន ។ ក្នុងវ័យ៥៧ឆ្នាំ សព្វថ្ងៃរស់នៅអន្លង់វែង ដែលជាអតីតទីតាំងចុងក្រោយរបស់ខ្មែរក្រហម ភិន បានធ្វើដំណើរដោយកម្រមួយមកកាន់ទីក្រុងភ្នំពេញកាលពីខែមេសាកន្លងទៅដើម្បីចូលរួមមើលដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម និងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងជាលើកដំបូង ។ ទីតាំងទាំងពីរដែលបានចូលរួមទស្សនា ភិន មិនសូវមានអារម្មណ៍វិជ្ជមាន និងពេញចិត្តប៉ុន្មានទេ ព្រោះគាត់ពេញចិត្តច្រើនជាងទៅនឹងអ្វីដែលរដ្ឋាភិបាលកម្ពុជាបានធ្វើ និងកំពុងធ្វើ ។ ទាក់ទងនឹងសាលាក្តីខ្មែរក្រហម ភិន បញ្ជាក់ថា សាលាក្តីនេះបានប្រើប្រាស់លុយជាច្រើនដោយកាត់ទោសតែមនុស្សពីរបីនាក់ប៉ុណ្ណោះ និងស្ទើរតែមិនអាចរកយុត្តិធម៌បានផង «ខ្ញុំមិនជឿថាសាលាក្តីខ្មែរក្រហមអាចរកយុត្តិធម៌ជូនប្រទេសជាតិបានទេ បើកាត់ទោសតែពីរបីនាក់ចាស់ៗដូច្នេះនេះ» ។ ចំណែកឯសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងវិញ ក្រោយពីមើលពីអគារមួយទៅអគារមួយទៀត ភិន បានប្រទះឃើញវត្ថុមួយដែលធ្វើឲ្យគាត់នឹកឃើញដល់អតីតកាល ។ នោះគឺខ្សែលួសដែលដាក់នៅអគារ «គ» ដើម្បីការពារពីការរត់គេច និងការព្យាយាមសម្លាប់ខ្លួនរបស់អ្នកទោស ។ ភិន បានចង្អុលទៅខ្សែលួសនោះ



សំ ភិន កំពុងសម្លឹងមើលលួសបន្លានៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងដែលគាត់អះអាងថាជាលួសបន្លាអាមេរិក

ហើយនិយាយថា «នេះគឺខ្សែលួសអាមេរិកាំង ។ ខ្សែលួសនេះស្អិតជាប់ណាស់ តែមុតហើយមិនងាយនឹងដោះចេញពីសាច់បានទេ» ។

សម្រាប់ ភិន អតីតកាលគឺជារឿងឈឺចាប់ ។ អ្វីដែលគាត់ចង់បានគឺការរួបរួមគ្នាដូចអ្វីដែលមានសព្វថ្ងៃ ។

ភិន អះអាងថា សព្វថ្ងៃនេះ ការបង្រួបបង្រួមជាតិគឺជាកិច្ចការសំខាន់បំផុតសម្រាប់ប្រទេសកម្ពុជា ហើយមានតែខ្មែរប៉ុណ្ណោះដែលអាចស្វែងរកការបង្រួបបង្រួមជូនប្រទេសជាតិបាន ។ ភិន មិនសូវជឿជាក់លើសាលាក្តីខ្មែរក្រហមទេ ដែលមានការចូលរួមពីសំណាក់បរទេស ។ ឥទ្ធិពលបរទេសកាលពីអតីតកាលធ្វើឲ្យ ភិន លែងទុកចិត្តបរទេស ។ បរាជ័យរបស់អ៊ុនតាក់ក្នុងការធានាបាននូវការរួបរួមគ្នារឹតតែធ្វើឲ្យ ភិន អស់ជំនឿលើបរទេសកាន់តែខ្លាំងឡើង ។ ភិន និយាយថា «ទីបំផុតមានតែសម្តេច ហ៊ុន សែន ទេ ដែលអាចបង្រួបបង្រួមប្រទេសបាន ។ បរទេសមិនអាចធ្វើឲ្យខ្មែររួបរួមគ្នាបានទេ ។ បារាំងកាត់ដីឲ្យវៀតណាម ។ អាមេរិកទម្លាក់គ្រាប់បែកលើកទឹកដីខ្មែរ ។ តើបរទេសជួយអ្វីខ្លះដល់ខ្មែរ? មានតែខ្មែរទេដែលស្រលាញ់ខ្មែរ» ។

ដូចអតីតកម្មាភិបាលខ្មែរក្រហមនៅអន្លង់វែង និងនៅតំបន់ផ្សេងទៀតដែរ ភិន ស្រលាញ់ចូលចិត្តមេដឹកនាំកម្ពុជាសព្វថ្ងៃជាខ្លាំងដោយសារតែមេដឹកនាំកម្ពុជាជាអ្នកបញ្ចប់សង្គ្រាម ជាពិសេសនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ភិន ស្រលាញ់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយសារតែនយោបាយ «ឈ្នះ! ឈ្នះ!» ដែលនាយករដ្ឋមន្ត្រីបានអនុវត្តកាលពីទសវត្សរ៍៩០ ដើម្បីនាំមកនូវសន្តិភាពនិងការបង្រួបបង្រួមជាតិសម្រាប់ខ្មែរដែលធ្លាប់បែងចែកបក្សពួកគ្នាកាលពីអំឡុងសង្គ្រាម ។ ភិនយល់ថា គោលនយោបាយ «ឈ្នះ! ឈ្នះ!» គឺជាទីបញ្ចប់នៃវិវាទនៅកម្ពុជា ហើយថា គោលនយោបាយនេះហើយដែលអាចធ្វើឲ្យគាត់ជួបជុំបងប្អូនសាច់ញាតិគាត់វិញដែលគាត់បែកតាំងពីឆ្នាំ១៩៧១មក ធ្វើឲ្យគាត់មានផ្ទះរស់នៅសមរម្យ និងធ្វើឲ្យគាត់អាចមានផ្លូវសម្រាប់ធ្វើដំណើរបានដូចសព្វថ្ងៃ ។ ភិន និយាយថា «បើគ្មានគោលនយោបាយឈ្នះ ឈ្នះទេ មិនដឹងពេលណាសង្គ្រាមចប់ទេ» ។

ពេលនឹកឃើញដល់អតីតកាលក្នុងតំបន់ខ្មែរក្រហម ភិន តែងតែស្ងើចសរសើរខ្លួនឯងថា គាត់មិនគួរនឹងរស់រានមានជីវិតរហូតដល់ពេលនេះទេដោយសារតែគាត់ជួបប្រទះហេតុការណ៍រន្ធត់ៗជាច្រើនកាលពីសម័យសង្គ្រាម ។ ភិន និយាយបន្ថែមទៀតថា «សង្គ្រាមសាហាវណាស់ ប្រយុទ្ធគ្នាគ្មានពេលសម្រាកទេ អត់បាយ អត់ទឹក ។ យើងបាញ់គេ គេបាញ់យើង» ។

ក្រោយសន្ធិសញ្ញាសន្តិភាពនៅទីក្រុងប៉ារីសឆ្នាំ១៩៩១ ទាហានរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិបានមកបំពេញបេសកកម្មនៅប្រទេសកម្ពុជាដើម្បីអនុវត្តកិច្ចព្រមព្រៀងសន្តិភាព ក្រោយការចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពរវាងភាគីជម្លោះខ្មែរទាំងបួនរួច ។ ប៉ុន្តែ អង្គការសហប្រជាជាតិមិនបានស្វែងរកសន្តិភាពជូនខ្មែរឲ្យបានពេញលេញទេ ដោយបន្សល់នូវកងកម្លាំងខ្មាំងខ្មែរក្រហមកំពុងនៅតស៊ូប្រដាប់អាវុធនៅឡើយ ។ ចាប់តាំងពីពេលនោះមក ភិន លែងទុកចិត្តបរទេសទៀតហើយ ព្រោះតាំងពីទសវត្សរ៍៧០មក បរទេសមិនអាចស្វែងរកសន្តិភាពពេញលេញជូនប្រទេសកម្ពុជាទេ ។

ទើបតែចុងទសវត្សរ៍៩០ប៉ុណ្ណោះ ទើប ភិន ដឹងច្បាស់ថា «ការបង្រួបបង្រួមជាតិ» កើតឡើងនៅក្នុងប្រទេសក្រោយពីរចនាសម្ព័ន្ធខ្មែរក្រហមបានខ្ចាត់ខ្ចាយ ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ភិន និងកម្មាភិបាលខ្មែរក្រហមភាគច្រើនដឹងថា នេះគឺជាការបង្រួបបង្រួមជាតិនៅកម្ពុជា ។ ភិន ស្អប់សង្គ្រាមនិងចង់ចាប់យកសន្តិភាព ហើយបាននិយាយថា «សង្គ្រាមមិនមែនជារឿងល្អសោះ សង្គ្រាមគឺជាល្បែងដើម្បីតែអំណាចរបស់ថ្នាក់ដឹកនាំតែប៉ុណ្ណោះ ។ អ្នកស្លាប់ក៏ខ្មែរ អ្នករបួសក៏ខ្មែរ ។ យើងសុទ្ធតែជាខ្មែរទាំងអស់» ។

ភិន បានដុងខ្លួននៅក្នុងសង្គ្រាមស៊ីវិលតាំងពីគាត់មានអាយុ១៨ឆ្នាំមកម្ល៉េះ ក្នុងឆ្នាំ១៩៧១ ។ គាត់កើតក្នុងគ្រួសារកសិករមួយនៅស្រុកទ្រាំង ខេត្តតាកែវ ។ ក្រោយព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់ប្រមុខរដ្ឋ សម្តេចនរោត្តម សីហនុ ក្នុងឆ្នាំ១៩៧០ ឪពុករបស់ ភិន បានចូលរួមមហាបាតុកម្មប្រឆាំងនឹងរដ្ឋាភិបាល លន់ នល់ ដែលបានដណ្តើមយកអំណាចពីសម្តេច សីហនុ ។ កាលនោះឪពុករបស់ ភិន ត្រូវទាហាន លន់ នល់ បាញ់ត្រូវជាច្រើនគ្រាប់ធ្វើឲ្យគាត់ធ្លាក់ចូលទៅក្នុងអូរមួយ រួចសន្លប់អស់មួយយប់ ។ ជាភ័ព្វសំណាងឪពុករបស់គាត់អាចរួចរស់ជីវិត ។

មួយឆ្នាំក្រោយមក ក្នុងឆ្នាំ១៩៧១ ភិន បានចូលធ្វើយោធាខ្មែរក្រហមដោយសារតែកម្មាភិបាលខ្មែរក្រហមដើរទាំងហ្វូងស្រែកគំរាមដោយប្រើព្រះនាមសម្ដេច សីហនុ ថា "ជយោសម្ដេចឪ! អ្នកណាមិនទៅដុតផ្ទះចោល" ។ យុវជនធ្វើតាមអ្នកក្នុងភូមិចូលបដិវត្តន៍ ហើយឪពុកម្ដាយក៏មិនមានអំណាចនិងឥទ្ធិពលមករារាំងកូនរបស់ខ្លួនដែរ ។ ភិន បាននិយាយថា "ក្មេងៗនៅក្នុងភូមិចូលខ្មែរក្រហមទាំងអស់ ។ គ្មាននរណានៅផ្ទះទេ លើកលែងតែគ្រួសារចាស់ៗប៉ុណ្ណោះ" ។

ក្រោយពីចូលធ្វើយោធាខ្មែរក្រហម ភិន និងយុវជនដទៃទៀតដែលមានអាយុប្រហាក់ប្រហែលគ្នា ត្រូវធ្វើដំណើរដោយថ្មើរជើងទៅកាន់មូលដ្ឋានបង្អែកម្ដុំផ្លូវភ្នំដីវីរមៀលក្នុងស្រុកគ្រាំកក់ ដែលនៅទីនោះ ភិន ត្រូវបានដុះខាត់ខួរក្បាលពីមនោគមវិជ្ជាកុម្មុយនីស្ត ការតស៊ូប្រដាប់អាវុធ បណ្ដុះឲ្យមានកំហឹងវណ្ណៈ និងឈប់នឹកផ្ទះ និងឪពុកម្ដាយ ។ ក្រោយមក ភិន ត្រូវបានបណ្ដុះបណ្ដាលអំពីយុទ្ធសាស្ត្រយោធាអស់រយៈពេលពីរបីខែ ។ ក្រោយពីនោះមក យោធាខ្មែរក្រហមត្រូវចាត់តាំងជាក្រុមតូចធំដើម្បីទៅវាយឆ្មក់មូលដ្ឋានទ័ព លន់ នល់ ។ ដំបូងឡើង ភិន មិនទាន់មានកាំភ្លើងកាន់ទេ ក្រៅតែពីឧបករណ៍បន្តិចបន្តួចសម្រាប់ការពារខ្លួន ។ ភិន បានរៀបរាប់ថា "កាលនោះ កាំភ្លើងមិនសូវមានច្រើន ។ ម្ល៉ោះហើយមេខ្ញុំប្រាប់ថា ពេលទៅវាយខ្មាំងត្រូវចេះរឹបអូសកាំភ្លើង ហើយយកកាំភ្លើងនោះមកប្រើ" ។

ភិន បានដើរជាច្រើនគីឡូម៉ែត្រក្នុងមួយថ្ងៃ ។ អ្វីដែលគាត់ខ្លាចជាងគេគឺមិនមែនទាហាន លន់ នល់ ទេ តែយន្តហោះទម្លាក់គ្រាប់បេ-៥២របស់អាមេរិកដែលតែងមកទម្លាក់គ្រាប់ និងបង្ករវិនាសកម្មយ៉ាងធំធេង ។ ភិន និយាយថា "បេ-៥២ សាហាវណាស់ អ្នកណាក៏ខ្លាចវាដែរ អ្នកភូមិខ្លាចគ្រប់គ្នាហើយមិនហ៊ានចេញក្រៅទេ រស់នៅតែក្នុងលេណដ្ឋានដូចសត្វកណ្ដុរអញ្ចឹង" ។

ដើមឆ្នាំ១៩៧៤ យោធាខ្មែរក្រហមមានយុទ្ធសាស្ត្រវាយយកទីរួមខេត្តកំពត ។ កងវរសេនាធំរបស់ ភិន បានវាយបំបែកខ្សែប្រយុទ្ធរបស់ទាហាន លន់ នល់ បានជាច្រើនកន្លែង ។ ការវាយប្រយុទ្ធបានដេញទាហាន លន់ លន់ ឆ្ងាយទៅៗរហូតដល់កន្លែងមួយដែលយោធាក្នុងកងវរសេនាធំរបស់ ភិន លំបាកប្រយុទ្ធព្រោះទីនោះជាមូលដ្ឋានដ៏រឹងមាំជាងកន្លែងមុនៗ ។ ភិន បាននិយាយថា កងរបស់គាត់បានចំណាយពេលជាច្រើនថ្ងៃដើម្បីវាយបំបែកមូលដ្ឋានទ័ព លន់ នល់ តែនៅតែមិនអាចបំបែកបាន ។ ក្រោយពីប្រយុទ្ធអស់ជាច្រើនថ្ងៃ ភិន បានរងរបួសដោយគ្រាប់កាំភ្លើង អឹម-ស៊ី (M-16) របស់ទាហាន លន់ នល់ ដោយជើងរបស់គាត់ត្រូវបំនួនពីរគ្រាប់ធ្វើឲ្យគាត់មិនអាចប្រយុទ្ធតទៅទៀតបាន និងត្រូវបានមិត្តភក្ដិជូនទៅព្យាបាលមន្ទីរពេទ្យចក្រីទីង ។ ដោយសារតែថ្ងៃនោះ ភិន ទទួលរងគ្រោះថ្នាក់ធ្ងន់ធ្ងរ គាត់នៅចងចាំថ្ងៃនោះជានិច្ច គឺនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៤ នៅវេលាម៉ោង៨យប់ ។ ពេលកំពុងតែព្យាបាលនៅចក្រីទីងទើប ភិនដឹងថា កន្លែងដែលគាត់រងរបួសគឺនៅទីរួមខេត្តកំពតដែលមានមូលដ្ឋានទ័ព លន់ នល់ រឹងមាំ និងជាទីតាំងចុងក្រោយដែលកងវរសេនាធំរបស់ ភិន មានបំណងវាយបំបែក ។

ក្រោយពីរងរបួស ភិន ទទួលការព្យាបាលប្រហែលជាបីខែ និងមិនអាចដើរបានធម្មតាទេអស់រយៈពេលមួយឆ្នាំពេញ ។ ក្នុងឆ្នាំ១៩៧៦ គាត់ត្រូវអង្គការចាត់តាំងឲ្យទៅក្ដោបក្ដាប់អង្គភាពភ័ស្ដុភារជនពិការរបស់កងពល១៦៤ នៃទ័ពជើងទឹកខ្មែរក្រហម នៅកំពង់សោមក្រោមការដឹកនាំរបស់ មាស មុត ដែលជាប្រធានកងពល១៦៤ ។ មួយឆ្នាំក្រោយមក ភិន បានរៀបការជាមួយប្រពន្ធគាត់ដែលជានារីកម្មាភិបាលមកពីចម្ការដូងរាម ។

នៅពេលដែលទាហានវៀតណាមវាយចូលប្រទេសកម្ពុជា ភិន បានបរទេះគោគេចខ្លួនឆ្ពោះទៅកាន់ព្រំដែនថៃ ។ មួយរយៈពេលខ្លីក្រោយមក កងទ័ពវៀតណាមក៏តាមជិតទាន់ ។ ដោយសារខ្លាចទាហានវៀតណាមចាប់ខ្លួនបាន ភិន បានបោះបង់ចោលរទេះគោរួចរត់ចូលព្រៃ និងដើរទៅកាន់ព្រំដែនថៃ ។ ពីរបីខែក្រោយមក រថយន្តធំៗជាច្រើនគ្រឿងបានដឹកប្រជាជនទៅនៅតំបន់ជួរភ្នំដងរែកដែលជាមូលដ្ឋានរបស់ខ្មែរក្រហម ។ ភិន ក៏ទៅទីនោះដែរ ។ ក្រោយពីទាហាននៅអន្លង់វែងផ្ដាច់ខ្លួនចុះចូលជាមួយរដ្ឋាភិបាលកម្ពុជា ភិន បានចុះមករស់នៅអន្លង់វែង ជាកន្លែងដែលគាត់រស់នៅរហូតដល់សព្វថ្ងៃ ។ ភិន រីករាយយ៉ាងខ្លាំងក្រោយពេលសមាហរណកម្មយោធាខ្មែរក្រហម ព្រោះគាត់យល់ថា សង្គ្រាមបានបញ្ចប់ហើយ ។ ភិន ក៏ចាប់ផ្ដើមមានសេរីភាព

ឡើងវិញ ។ ក្នុងឆ្នាំ១៩៩៩ ភិន បានទៅលេងស្រុកកំណើតក្នុងស្រុកទ្រាំង ខេត្តតាកែវ ព្រោះបែកតាំងពីឆ្នាំ១៩៧១មក ។ ពេលទៅដល់ផ្ទះទើប ភិន ដឹងថាឪពុកម្ដាយរបស់គាត់ស្លាប់អស់ហើយដោយសារជំងឺ ។ ភិនមិនដែលគិតថា ពេលគាត់បែកឪពុកម្ដាយក្នុងឆ្នាំ១៩៧១ បែករហូតដូច្នេះទេ ។

ប៉ុន្តែ អ្វីដែល ភិន រីករាយខ្លាំងបំផុតគឺការបញ្ចប់សង្គ្រាមដ៏រ៉ាំរ៉ៃអស់រយៈពេលជាច្រើនឆ្នាំកន្លងមក ។ ភិន បានផ្ដល់ការកោតសរសើរដល់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាអ្នកបញ្ចប់សង្គ្រាមនេះ ។ ភិន បញ្ជាក់ថា គាត់បានជួបជុំគ្រួសារនៅពេលនេះក៏ដោយសារតែគោលនយោបាយឈ្នះឈ្នះរបស់នាយករដ្ឋមន្ត្រីដែរ ។ ភិន បាននិយាយថា «គ្មាននរណាធ្វើបានដូចគាត់ (នាយករដ្ឋមន្ត្រី ហ៊ុន សែន) ទេ» ។

សព្វថ្ងៃ ជើងខាងស្ដាំរបស់ ភិន មិនអាចដើរបានជាប្រក្រតីបានទេចាប់តាំងពីគាត់ត្រូវរបួសនោះមក ។ គាត់ត្រូវពាក់ស្បែកជើងពីរផ្សេងគ្នាគ្រប់ពេល ។ ជើងដែលគាត់ត្រូវរបួសមិនត្រូវជាមួយនិងស្បែកជើងផ្សេងទៀត ក្រៅតែពីស្បែកជើងកង់ឡានរបស់ខ្មែរក្រហមទេ ព្រោះស្បែកជើងកង់ឡាននេះអាចចងជាប់មិនឲ្យរបូតបាន ។ ចំណែកជើងខាងឆ្វេងអាចពាក់ជាមួយស្បែកជើងគ្រប់ប្រភេទជាធម្មតា ។ ពេលដែលគាត់មកភ្នំពេញកាលពីខែមេសាកន្លងទៅនេះ ជើងខាងឆ្វេងរបស់គាត់ពាក់ស្បែកជើងផ្ទាត់ ។

សព្វថ្ងៃ ភិន រស់នៅជាមួយប្រពន្ធ និងមានកូនបីនាក់ ។ កូនពៅបង្អស់កំពុងសិក្សានៅសាកលវិទ្យាល័យមួយនៅភ្នំពេញ ។ ភិន និងគ្រួសារមានជីវភាពរស់នៅសមរម្យដោយប្រកបរបរធ្វើស្រែនិងដាំដំណាំផ្សេងៗ ។ ភិន ជាមនុស្សចូលចិត្តនិយាយច្រើននិងជាមនុស្សពូកែរៀបរាប់កំប្លែង ។ ដោយរីករាយនឹងជីវិតប្រចាំថ្ងៃ ភិន ពេញចិត្តនិងសន្តិភាពនិងការរួបរួមគ្នាដែលប្រទេសកម្ពុជាមាន ។ អ្វីដែល ភិន ចង់បាន គឺសន្តិភាពដូចសព្វថ្ងៃ និងស្អប់សង្គ្រាមជាទីបំផុត ។ ភិន និយាយដោយទឹកមុខញញឹមថា «ខ្ញុំលែងចង់ធ្វើសង្គ្រាមទៀតហើយ ។ បើមាននរណាមកអូសទាញខ្ញុំក៏ខ្ញុំមិនទៅដែរ ហើយខ្ញុំនឹងប្រាប់កូនថែមទៀតមិនឲ្យចូលធ្វើសង្គ្រាមដាច់ខាត» ។

**ញាណ សុជាតិ**



សំ ភិន កំពុងមើលរូបថតអ្នកទោសនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

# ម៉ាឡៃពីតំបន់ជម្លោះជូរចត់ មកជាតំបន់នៃការផ្សះផ្សា


ផ្លូវដែលទើបកសាងថ្មីនៅស្រុកម៉ាឡៃ

ស្រុកម៉ាឡៃ គឺជាទីតាំងដ៏មានសារសំខាន់មួយសម្រាប់សិក្សាពីប្រវត្តិសាស្ត្រប្រទេសកម្ពុជាទាក់ទងនឹងរបបខ្មែរក្រហម ការតស៊ូក្នុងអំឡុងសង្គ្រាមស៊ីវិល ការចងចាំពីអតីតកាល និងការផ្សះផ្សាក្នុងប្រទេស ។ ភ្ជាប់ទៅនឹងការសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមសាលារៀនសម្រាប់សិស្សមធ្យមសិក្សាពីថ្នាក់ទី៩ដល់ថ្នាក់ទី១២ មជ្ឈមណ្ឌលឯកសារកម្ពុជាដោយមានកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានសម្ពោធពាក្យស្លោករំឭកការចងចាំ និងអំពើប្រល័យពូជសាសន៍ នៅវិទ្យាល័យម៉ាឡៃ ស្ថិតនៅក្នុងភូមិដូងយុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ ។ កម្មវិធីតម្លើងពាក្យស្លោកនេះ គឺជាសកម្មភាពមួយនៅក្នុងគម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានគោលបំណងផ្សារភ្ជាប់ជាមួយនឹងការបង្រៀនប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍កម្ពុជា និងការយល់ដឹងរបស់ប្រជាជននៅមូលដ្ឋានពីអំពើឃោរឃៅរបស់របបខ្មែរក្រហម ចន្លោះខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ។ ពាក្យស្លោកនេះបង្កប់នូវអត្ថន័យចំនួនពីរដែលរំឭកឡើងវិញនូវអំពើឃោរឃៅក្នុងអំឡុងរបបខ្មែរក្រហម និងសារសំខាន់នៃការចងចាំ ការអប់រំ និងសន្តិភាព ។ អត្ថន័យនៃពាក្យស្លោកទាំងពីរនេះគឺ «និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឲ្យអត់ឱន អធ្យាស្រ័យគ្នា» និង «រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍» ។

ពាក្យស្លោកដែលដាក់តាំងនៅក្នុងវិទ្យាល័យម៉ាឡៃនេះ ត្រូវបានចារឹកលើផ្ទាំងអ៊ីណុកពណ៌ស ហើយត្រូវដាក់បង្ហាញនៅទីតាំងដែលសិស្សានុសិស្ស និងលោកគ្រូ-អ្នកគ្រូអាចមើលឃើញគ្រាន់តែឈានជើងចូលក្នុងបរិវេណសាលាភ្លាម ។ គោលបំណងនៃអត្ថន័យនៃពាក្យស្លោកនេះ មិនគ្រាន់តែជួយក្រើនរំឭកនោះទេ

ប៉ុន្តែថែមទាំងបំផុសគំនិតឲ្យមានការត្រិះរិះពិចារណា ។ ការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនឹងជួយក្រើនរម្លឹកពីអតីតកាល និងរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ការផ្សះផ្សាជាតិ ការអត់ឱន និងការអធ្យាស្រ័យគ្នា ។

ម៉ាឡៃ ជាស្រុកមួយក្នុងចំណោមស្រុកទាំងប្រាំបួនរបស់ខេត្តបន្ទាយមានជ័យ ដែលស្ថិតនៅទិសពាយ័ព្យប្រទេសកម្ពុជា ។ ម៉ាឡៃមានចម្ងាយ៤១៧គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៥ ។ ប្រវត្តិនៃការដាក់ឈ្មោះ "ម៉ាឡៃ" ត្រូវយកតាមឈ្មោះភ្នំម៉ាឡៃ នៅតំបន់នេះផ្ទាល់តែម្តង ។ កាលពីដើមឡើយ ម៉ាឡៃជាតំបន់គ្របដណ្តប់ដោយព្រៃឈើយ៉ាងក្រាស់ក្រែលដែលលាតសន្ធឹងតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ចាប់ពីតំបន់ម៉ាឡៃរហូតទៅដល់ខេត្តប៉ៃលិន ។

ក្រោយការដួលរលំនៃរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ កម្មាភិបាលខ្មែរក្រហមជាច្រើន រួមមានកម្មាភិបាល និងយោធា បានរត់គេចមកជ្រកកោននៅតំបន់នានាតាមបណ្តោយព្រំដែនកម្ពុជា-ថៃពីការវាយប្រហាររបស់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ស្ថិតក្រោមការជួយជ្រោមជ្រែងពីកងទ័ពវៀតណាមដែលក្នុងនោះក៏មានតំបន់ម៉ាឡៃផងដែរ ។ ភាគច្រើននៃអតីតខ្មែរក្រហមដែលបានរត់ភៀសខ្លួនមកដល់តំបន់ម៉ាឡៃជាអតីតកម្មាភិបាលដែលធ្លាប់បម្រើការងារនៅក្នុងក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងចំណោមតំបន់តស៊ូសំខាន់ៗរបស់ចលនាខ្មែរក្រហម ម៉ាឡៃ ធ្លាប់ជាតំបន់តស៊ូដ៏រឹងមាំ ហើយក៏ជាសមរភូមិក្តៅរវាងទ័ពខ្មែរក្រហម និងកងទ័ពរដ្ឋាភិបាលកម្ពុជាអស់រយៈពេល១៧ឆ្នាំ ចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៦ ។ ជាមួយនឹងតំបន់តស៊ូប៉ៃលិន កំរៀង សំពៅលូន ភ្នំព្រឹក និងម៉ាឡៃ អាចសន្និដ្ឋានបានថា តំបន់តស៊ូខ្មែរក្រហមដែលលាតសន្ធឹងចាប់ពីតំបន់ម៉ាឡៃដល់តំបន់ប៉ៃលិន ជាតំបន់ខ្សែក្រវាត់ការពារដ៏រឹងមាំ ។ តំបន់ខ្សែក្រវាត់ការពាររបស់ទ័ពខ្មែរក្រហម មានបួនកងពលដែលឈរជើងការពារ ។ កងពលខ្មែរក្រហមទាំងបួននោះ រួមមានកងពល៤៥០ ឈរជើងនៅតំបន់ម៉ាឡៃ កងពល៣២០ ឈរជើងនៅតំបន់សំពៅលូន កំរៀង និងភ្នំព្រឹក កងពល៥១៩ ឈរជើងនៅតំបន់ភ្នំឆ័ត្រ និងកងពល៤១៥ ឈរជើងនៅតំបន់ប៉ៃលិន ។

ម៉ាឡៃ បានក្លាយទៅជាមូលដ្ឋានទីបញ្ជាការសមរភូមិកងពល៤៥០ របស់កងទ័ពខ្មែរក្រហម ចាប់ពីទសវត្សរ៍៨០ ដល់ពាក់កណ្តាលទសវត្សរ៍៩០ ។ តំបន់ម៉ាឡៃ និងតំបន់ប៉ៃលិន ស្ថិតក្រោមការគ្រប់គ្រងរបស់ អៀង សារី ។

នៅអំឡុងសង្គ្រាមស៊ីវិល ម៉ាឡៃ អាចចាត់ទុកថាជារដ្ឋធានីមួយរបស់ខ្មែរក្រហម ។ ការលើកឡើងបែបនេះព្រោះថាទោះជារបបកម្ពុជាប្រជាធិបតេយ្យដួលរលំក៏ដោយ ក៏អាសនៈរបស់ខ្មែរក្រហមនៅតែមាននៅអង្គការសហប្រជាជាតិដោយស្របច្បាប់ដដែល ។ ស្ថិតក្រោមរបបអន្តរកាលរបស់ប្រទេសកម្ពុជា បណ្តាប្រទេសដែលប្រកាន់ខ្ជាប់នូវរបបសេរីមិនត្រឹមតែមិនគាំទ្ររដ្ឋាភិបាលថ្មីនេះទេ ថែមទាំងដាក់ទណ្ឌកម្មហ៊ុមព័ទ្ធសេដ្ឋកិច្ចទៀតផង ដោយយកលេសថា រដ្ឋាភិបាលដែលគាំទ្រដោយវៀតណាមជារដ្ឋាភិបាលមិនស្របច្បាប់ ។ ដូចនេះ ម៉ាឡៃ ត្រូវយកធ្វើជាកន្លែងថ្វាយសារតាំងដល់ថ្នាក់ដឹកនាំខ្មែរក្រហមពីឯកអគ្គរាជទូត និងឯកអគ្គរដ្ឋទូតរបស់បណ្តាប្រទេសមានទំនាក់ទំនងជាមួយថ្នាក់ដឹកនាំខ្មែរក្រហម ។

តាមការសាកសួរអតីតកម្មាភិបាលខ្មែរក្រហមនៅតំបន់ម៉ាឡៃបានឲ្យដឹងថា ការរត់ភៀសខ្លួនមកដល់តំបន់ម៉ាឡៃដំបូង អតីតខ្មែរក្រហមជាច្រើននៅតំបន់នេះផ្ទាល់មានការលំបាកវេទនាជាខ្លាំងសម្រាប់ជីវភាពរស់នៅរបស់ខ្លួន ។ បញ្ហាប្រឈមសំខាន់ៗទាំងនោះមានដូចជា កង្វះស្បៀងអាហារ ជំងឺ និងជម្រក ។ នៅដំណាក់កាលដំបូង អតីតខ្មែរក្រហមជាច្រើនរួមទាំងកម្មាភិបាល



ច្រកព្រំដែនកម្ពុជា-ថៃ នៅក្នុងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

និងយោធាបានបាត់បង់អាយុជីវិតតាមផ្លូវធ្វើដំណើរដោយសារការមិនមានអាហារគ្រប់គ្រាន់បរិភោគ និងជំងឺគ្រុនចាញ់ ។ នៅពេលមិនមានអ្វីបរិភោគ អតីតខ្មែរក្រហមទាំងនោះ ត្រូវដឹកមើមក្តួចយកមកហូប ឬលួចចូលភូមិប្រជាជន ដើម្បីសុំអាហារហូបជាដើម ។ ជាងនេះទៅទៀត ស្ថានភាពរស់នៅក្នុងព្រៃពិតជាមានការលំបាកខ្លាំងណាស់ ជាពិសេសនៅរដូវវស្សា ពីព្រោះមិនមានអ្វីធ្វើជាជម្រក ក្រៅពីយកស្លឹកឈើ និងតង់កៅស៊ូបន្តិចបន្តួចមកបាំងទឹកភ្លៀងទេ ។

ទាក់ទងទៅនឹងការបង្កើតកម្លាំងតស៊ូរបស់ខ្មែរក្រហមនៅតំបន់ម៉ាឡៃ ខ្មែរក្រហមបានធ្វើការទាក់ទងគ្នាជាសម្ងាត់ជាមួយបណ្តាញរបស់ខ្លួន ដែលបានសម្ងំលាក់ខ្លួនក្នុងព្រៃនៅតាមតំបន់ផ្សេងៗ មកបង្កើតជាកម្លាំងតស៊ូប្រឆាំងនឹងកងទ័ពវៀតណាម ។ កែ ខន អតីតយោធាខ្មែរក្រហមរបស់កងពល៤៥០ បានរៀបរាប់ថា នៅដើមឆ្នាំ១៩៧៩ ភ្លាមៗបន្ទាប់ពីរងការវាយប្រហារយ៉ាងធ្ងន់ធ្ងរពីកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងទ័ពវៀតណាម ខន បានដឹកនាំទាហានប្រមាណជាង១០០នាក់ ពីខេត្តបាត់ដំបង មកសម្ងំលាក់ខ្លួនក្នុងព្រៃក្នុងខេត្តបន្ទាយមានជ័យ ។ រយៈពេលប្រាំមួយខែក្រោយមក ខន បានទទួលបញ្ជាពីអតីតប្រធានតំបន់៣ តាមរយៈវិទ្យុទាក់ទងឲ្យដឹកនាំកម្លាំងទៅចូលរួមជាមួយកម្លាំងផ្សេងទៀតនៅតំបន់ម៉ាឡៃ ។ ខន បានបន្តថា សម្រាប់ការដឹកនាំរបស់កងពល៤៥០ សុខ ភាព ជាប្រធាន ហើយកងពលនេះត្រូវបែងចែកចេញជាបីវរសេនាធំ មានដូចជា ៖ វរសេនាធំ ១០៧, ១០៨ និង១០៩ ។

ជាក្បួនយុទ្ធសាស្ត្រ ខ្មែរក្រហមបានធ្វើការកេណ្ឌប្រជាជន និងអតីតកម្មាភិបាលដែលរត់ភៀសខ្លួនមកជាមួយចូលរួមធ្វើជាកងទ័ព ក្នុងគោលបំណងពង្រីកកម្លាំងរបស់ខ្លួនឡើងវិញ ។ មួយវិញទៀត ខ្មែរក្រហមមិនមានមូលដ្ឋានយោធាច្បាស់លាស់នោះទេ ។ ជាទូទៅ យោធាខ្មែរក្រហមចល័តគ្រប់ទីកន្លែងនៅតាមព្រៃភ្នំ ប្រើយុទ្ធសាស្ត្រសង្គ្រាមឈ្លប វាយឆ្មក់ម្តងម្កាលមកលើកងទ័ពវៀតណាម ។ វិធីនេះគឺជាយុទ្ធសាស្ត្រមួយដែលខ្មែរក្រហមបានប្រើ ។ មេដឹកនាំជាន់ខ្ពស់ជាច្រើនរបស់ខ្មែរក្រហមយល់ថាការចល័តកងទ័ពគ្រប់ទីកន្លែង និងការវាយឆ្មក់ជាលក្ខណៈជា




ពាក្យស្លោកដើម្បីរំឭកពីរបបប្រល័យពូជសាសន៍ ត្រូវបានសម្ពោធនៅក្នុងបរិវេណវិទ្យាល័យម៉ាឡៃ កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣

ទ្រង់ទ្រាយតូចនៅតាមតំបន់នានា ជាស្ថានភាពល្អសម្រាប់ខ្លួន ពីព្រោះធ្វើឲ្យសត្រូវមិនដឹងពីមូលដ្ឋានពិតប្រាកដ និងកម្លាំងយោធារបស់ខ្លួន ។ បើរំឭកពីប្រវត្តិចាស់មកវិញបន្តិច ផ្ទុយពីការស្អប់និងការប្រឆាំងវត្តមានកងទ័ពវៀតណាមនៅលើទឹកដីកម្ពុជានៅមុនឆ្នាំ១៩៧៣ ទំនាក់ទំនងរវាងខ្មែរក្រហម និងវៀតណាមអាចនិយាយបានថា ជាទំនាក់ទំនងល្អកល្អិនចាក់ទឹកមិនលិច រហូតដល់មានការផ្លាស់ប្តូរគណៈប្រតិភូធ្វើទស្សនកិច្ចទៅវិញទៅមក ។

លើសពីនេះ ខ្មែរក្រហមក៏ធ្លាប់បានទទួលជំនួយផ្នែកយោធាជាច្រើនសន្ទឹកសន្ធាប់ពីវៀតណាម ទាំងសម្ភារ សព្វាវុធ និងជំនាញការបណ្តុះបណ្តាលយោធា ។ ចំណុចទាំងនេះ បញ្ជាក់ឲ្យឃើញថាវៀតណាមជាគ្រូរបស់ខ្មែរក្រហមក្នុងការបង្ហាត់បង្រៀនពីក្បួនយុទ្ធសាស្ត្រយោធាសម្រាប់ការប្រយុទ្ធ ។ នេះមិនមែនជារឿងចៃដន្យនោះទេ ក្រោយរដ្ឋប្រហារនៅឆ្នាំ១៩៧០ នៅតាមបណ្តាខេត្តមួយចំនួនក្នុងប្រទេសកម្ពុជា បានក្លាយជាតំបន់រំដោះរបស់ខ្មែរក្រហម ហើយរហូតឈានដល់ការផ្តួលរំលំរបប លន់ នល់ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ភាពអំនួត និងគំនិតជាតិនិយមជ្រុលហួសហេតុរបស់ខ្មែរក្រហម បានធ្វើឲ្យសិស្សម្នាក់នេះឲ្យលែងស្គាល់គ្រូ ។ ជាលទ្ធផល កូនសិស្សដែលមានភាពមានះរឹងរូសដូចខ្មែរក្រហម បានទទួលមេរៀនយ៉ាងចាស់ដៃពីវៀតណាម ។ ចេញពីការប្រឆាំងរបស់យោធាខ្មែរក្រហមចាប់ពីឆ្នាំ១៩៨៣ ដល់ឆ្នាំ១៩៨៥ កងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជាបានធ្វើការបោសសម្អាតតំបន់តស៊ូរបស់ខ្មែរក្រហមនៅតាមបណ្តាព្រំដែនកម្ពុជា-ថៃ ។ យុទ្ធនាការធ្វើការបោសសម្អាតបែបនេះត្រូវបានខ្មែរក្រហមឲ្យឈ្មោះថា “រុកសម្បុកអង្ក្រង” ។ ង៉ែត ធួន អតីតយោធាខ្មែរក្រហមបានពន្យល់ថា ការចាត់វិធានការរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ចំពោះការបោសសម្អាតតំបន់ខ្មែរក្រហម ហាក់បីដូចជា រុកសម្បុកអង្ក្រងឲ្យបែក ដូចនេះអង្ក្រងមិនមកខាំវិញទេ ។ តបទៅនឹងពាក្យថា “រុកសម្បុកអង្ក្រង” ភាគីខាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានថ្លែងថា នេះមិនមែនជាការរុកសម្បុកអង្ក្រងឲ្យបែកនោះទេ ប៉ុន្តែវាជាយុទ្ធនាការ “ការបងមុងទះមូស” ។ ស្របពេលជាមួយគ្នា រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានអនុវត្តផែនការ ក-៥ ក្នុងការកេណ្ឌយុវជនពេញកម្លាំងឲ្យទៅកាប់ឆ្ការព្រៃ ដើម្បីងាយស្រួលវាយបំបែកកម្លាំងខ្មែរក្រហមទាំងនោះ ។ បន្ថែមលើនេះ កងទ័ពវៀតណាមដើរតួនាទីជាអ្នកបង្កប់គ្រាប់មីន និងជាកម្លាំងវាយសង្គ្រប់ទៅលើកងទ័ពខ្មែរក្រហម ។

ចំពោះការដួលរលំមូលដ្ឋានកងទ័ពរបស់ខ្មែរក្រហមនៅឆ្នាំ១៩៨៥ មានមូលហេតុចម្បងៗចំនួនពីរ ។ មូលហេតុទី១ ៖ ក្នុងការបង្កើតជាតំបន់តស៊ូនានានៅតាមបណ្តោយព្រំដែនកម្ពុជាថៃ កងទ័ពខ្មែរក្រហមប្រើប្រាស់សម្ភារ សព្វាវុធធ្ងន់ តូចចាស់ៗ ។ មូលហេតុទី២ ៖ បន្ទាប់ពីឆ្នាំ១៩៧៩ កម្លាំងរបស់ខ្មែរក្រហមមានការថមថយយ៉ាងច្រើន និងការខ្វះខាតស្បៀងអាហារសម្រាប់ធ្វើសឹក ដូច្នេះចំណុចទាំងនេះ ក៏ជាបញ្ហាប្រឈមរបស់ខ្មែរក្រហមដែលនាំឲ្យទទួលបរាជ័យ ។ ប្រជាជនស៊ីវិល និងយោធាខ្មែរក្រហមនៅតំបន់ម៉ាឡៃ បាននាំគ្នារត់ទៅជ្រកកោននៅជំរំជនភៀសខ្លួនក្នុងខេត្តអារញ្ញយ៉ាប្រាថេត ប្រទេសថៃ ។ នាគ្រានោះ ប្រជាជនស៊ីវិលបានរត់ភៀសខ្លួនទៅកាន់ជំរំសាយអេច ឬជំរំភ្នំតាដ៊ុក រីឯយោធាខ្មែរក្រហម បានរត់ភៀសខ្លួនទៅកាន់ជំរំជុំថង ឬថ-៨៥ ។ នៅដំណាក់កាលនោះ អតីតខ្មែរក្រហមទាំងប្រជាជនស៊ីវិល និងយោធារស់នៅលក្ខណៈជាជនភៀសខ្លួននៅក្នុងប្រទេសថៃ និងទទួលបានជំនួយផ្នែកមនុស្សធម៌នានាពីបណ្តាលប្រទេសសហគមន៍អន្តរជាតិ ។ ទន្ទឹមនឹងការកើនឡើងនូវជនភៀសខ្លួនខ្មែរជារៀងរាល់ថ្ងៃ នេះពិតជាបន្ទុកដ៏ធ្ងន់សម្រាប់រដ្ឋាភិបាលថៃ ដែលត្រូវធ្វើការដោះស្រាយនឹងបញ្ហាទាំងនេះ ។ នៅក្នុងអត្ថបទសារព័ត៌មានមួយចុះផ្សាយ ថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៧៩ ដែលមានចំណងជើងថា *“Thai Play Unwilling Hosts to Refugees”* មានអត្ថន័យជាខេមរភាសាថា “ថៃមានសន្តានចិត្តស្ទាក់ស្ទើរក្នុងការទទួលស្វាគមន៍ជនភៀសខ្លួន” លោក ជូល ព្រីងឃ្លី (*Joel Brinkley*) បានសរសេររិះគន់យ៉ាងចាស់ដៃពីទង្វើអមនុស្សធម៌មួយចំនួនរបស់រដ្ឋាភិបាលថៃ មកលើជនភៀសខ្លួនខ្មែរ ក្នុងខេត្តអារញ្ញយ៉ាប្រាថេត ។ ជូល ព្រីងឃ្លី បានសរសេរថា មានមន្ត្រីថៃជាច្រើន បានបដិសេធដោយមិនទទួលជនភៀសខ្លួនខ្មែរបន្ថែម ដោយមន្ត្រីទាំងនោះនិយាយថា ប្រទេសក្រីក្ររបស់ខ្លួនក៏មានមាត់ប្រជាជនរបស់ខ្លួនជាច្រើនដែលត្រូវផ្គត់ផ្គង់ដែរ ។ ជូល ព្រីងឃ្លី បានបន្តទៀតថា ថ្ងៃមួយមាន

សេចក្តីសម្រេចពីទីក្រុងបាងកកថា រាល់ជនភៀសខ្លួនទាំងអស់ត្រូវតែត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ ។ ដូច្នេះ ទាហានថៃបានចុះស្រាវជ្រាវនៅក្នុងជំរុំជនភៀសខ្លួន ហើយចាប់បញ្ជូនជនភៀសខ្លួនខ្មែរណាដែលមិនមានឯកសារត្រឹមត្រូវ ។ ភ្លាមនោះ ក៏បានរកឃើញថា មានជនភៀសខ្លួនទាំង បុរស ស្ត្រី និងកុមារ ដែលមិនមានឯកសារត្រឹមត្រូវប្រហែល៨៥០នាក់ ត្រូវទាហានថៃធ្វើការចាប់បញ្ជូនមកប្រទេសកម្ពុជា ។ ទាំងនេះ មិនខុសពីសុភាសិតបុរាណខ្មែរពោលថា "ចុះទឹកជួបក្រពើ ឡើងលើជួបខ្លា" នោះទេ ។ អស់រយៈពេលជាច្រើនខែ រដ្ឋាភិបាលថៃខ្លួនឯងប្រឈមនឹងបញ្ហាយ៉ាងធ្ងន់ធ្ងរ ពីព្រោះតាមបណ្តាប្រទេសអន្តរជាតិ ធ្វើការដាក់សម្ពាធទៅលើប្រទេសថៃឲ្យផ្តល់ជម្រកបណ្តោះអាសន្នដល់ជនភៀសខ្លួនខ្មែរ ។ ស្របពេលនោះ ប្រជាពលរដ្ឋថៃយ៉ាងច្រើនមានការត្អូញត្អែរថា ជនភៀសខ្លួនទាំងនោះ គួរតែហាមឃាត់មិនឲ្យចូលក្នុងប្រទេសថៃ ។ ដោយរងនូវសម្ពាធពីបណ្តាប្រទេសអន្តរជាតិ ទើបនៅដើមខែតុលា ឆ្នាំ១៩៧៩ នាយករដ្ឋមន្ត្រីថៃ លោក គ្រាំងសាក់ ជុំម៉ាណន បានសម្រេចចិត្តដាក់ប្រទេសរបស់ខ្លួនជាជម្រកដល់ជនភៀសខ្លួនខ្មែរជាផ្លូវការ ។ នៅឆ្នាំ១៩៨៥ បន្ទាប់ពីកងទ័ពវៀតណាម បានបោសសម្អាតតំបន់តស៊ូខ្មែរក្រហមនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ កម្លាំងតស៊ូរបស់ខ្មែរក្រហមទាំងនោះបានរត់មកតាំងមូលដ្ឋានរបស់ខ្លួនក្នុងប្រទេសថៃ ។ មានពេលខ្លះមេដឹកនាំខ្មែរក្រហមមិនមែនជាតួអង្គកម្សត់ ដែលត្រូវសម្តែងឈុតសោកសៅរហូត ដូចក្នុងរឿងល្ខោនខ្មែរ "ព្រះធិនវង្ស" នោះទេ ។ ខុសពីការគិតចេញពីសាច់រឿងនេះ មេដឹកនាំខ្មែរក្រហមជាមនុស្សឆ្លាត ព្រោះខ្លួនចេះស្គាល់កាលៈទេសៈ និងពេលវេលាច្បាស់លាស់ ។ ដោយមិនបង្អង់យូរ មេដឹកនាំខ្មែរក្រហម ក៏គៀងគរជំនួយផ្សេងៗពីបរទេស ដើម្បីយកមកផ្គត់ផ្គង់ និងពង្រឹកកម្លាំងយោធា ។ នៅចុងឆ្នាំ១៩៨៩ ខ្មែរក្រហមបានដណ្តើមកាន់កាប់តំបន់ម៉ាឡៃពីរដ្ឋាភិបាលកម្ពុជា ស្របពេលដែលកងទ័ពវៀតណាមដកទ័ពចេញពីប្រទេសកម្ពុជា ។

ការវិលត្រឡប់ចូលមកវិញរបស់ប្រជាជនស៊ីវិល និងយោធាខ្មែរក្រហម ត្រូវជួបប្រទះនឹងផលលំបាកមួយទៀតគឺគ្រាប់មីនដែលបង្កប់ដោយកងទ័ពរដ្ឋាភិបាលកម្ពុជា និងវៀតណាម ។ គ្រាប់មីនទាំងនោះបានធ្វើឲ្យប៉ះពាល់ដល់ស្ថានភាពរស់នៅរបស់អតីតខ្មែរក្រហមនៅតំបន់ម៉ាឡៃ ដោយខ្លះត្រូវពិការដៃ ជើង ភ្នែក និងបាត់បង់ជីវិត ដោយសារតែជាន់មីន ។ ជាក់ស្តែង ហឿន អតីតប្រធានវរសេនាធំ១០៨ កងពល៤៥០ របស់ខ្មែរក្រហម បានឲ្យដឹងថា ដោយសារតែគ្រាប់មីនត្រូវបង្កប់ស្ទើរតែពាសពេញស្រុកម៉ាឡៃ ពីសំណាក់យោធាខ្មែរក្រហមផង និងទ័ពរដ្ឋាភិបាលផង ធ្វើឲ្យប្រជាជនដែលវិលត្រឡប់មកវិញត្រូវស្លាប់ របួស និងធ្លាក់ខ្លួនពិការច្រើនដោយសារជាន់មីន ។ ហឿន ប៉ាន់ប្រមាណថា ចំនួនជនពិការមានប្រហែល១៥ភាគរយនៃចំនួនប្រជាជននៅស្រុកម៉ាឡៃ ។ ដូចគ្នានឹងលោក ឃុន អ៊ឹម អតីតទាហានខ្មែរក្រហមរបស់វរសេនាធំ ១០៨ បាននិយាយថា គាត់បានដើរជាន់មីននៅក្នុងឆ្នាំ១៩៨៥ នៅពេលគាត់ចល័តជាមួយកម្លាំងរបស់វរសេនាធំរបស់គាត់ធ្វើឲ្យគាត់បាត់បង់ជើងខាងស្តាំ ។ នៅឆ្នាំ ១៩៩០ បន្ទាប់ពីវិលត្រឡប់ពីជំរំជនភៀសខ្លួនវិញ អ៊ឹម បានបាត់បង់ជើងឆ្វេងរបស់គាត់ទៀតនៅ



អគារសិក្សានៃវិទ្យាល័យម៉ាឡៃ

ពេលដែលគាត់ទៅដងទឹកប្រឡាយ បច្ចុប្បន្នជាខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ដោយខ្វះការប្រុងប្រយ័ត្ន ។

បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ដែលសម្របសម្រួលដោយអង្គការសហប្រជាជាតិ ខ្មែរក្រហមត្រូវផ្តាច់ជំនួយនានាពីបរទេស ។ នៅកាលៈទេសៈពិបាកបែបនេះ ក្រៅពីជំនួយដែលនៅសេសសល់បន្តិចបន្តួច ខ្មែរក្រហមចាប់ផ្តើមធ្វើអាជីវកម្មទាញយកផលប្រយោជន៍ពីធនធានធម្មជាតិផ្សេងៗ ដូចជាការកាប់ព្រៃឈើ រ៉ែត្បូង និងវត្ថុបុរាណជាដើម ។ ហេតុដូច្នេះទើបយើងឃើញថា ក្រោយពីសមាហរណកម្មឆ្នាំ១៩៩៦ ម៉ាឡៃក្លាយជាតំបន់វាល និងមិនសម្បូរព្រៃឈើដូចមុនឡើយ ។ ដូចពាក្យសុភាសិតខ្មែរពីបុរាណពោលថា "ហត់កាយ កុំឲ្យតែហត់ចិត្ត" ស្តែងចេញឲ្យឃើញពីភាពនឿយណាយរបស់អតីតកម្មាភិបាលគ្រប់រូបសូម្បីតែមេដឹកនាំក៏ដូច្នេះដែរ ដោយមិនចង់ធ្វើសង្គ្រាមតទៅទៀតទេ ។ យើងអាចសន្និដ្ឋានដោយខ្លីបានថា មេដឹកនាំខ្មែរក្រហមរង់ចាំតែការបើកភ្លើងខៀវពីភាគីរដ្ឋាភិបាលកម្ពុជា ខ្លួននឹងចុះចូលតែម្តង ។ នាក់ វង់ អតីតយោធាខ្មែរក្រហមរបស់កងពល៥១៩ បានដកស្រង់ពាក្យសម្តីរបស់ អៀង សារី ដោយនិយាយថា អៀង សារី មានអារម្មណ៍នឿយណាយជាខ្លាំង ក្នុងការរត់គេចពីការតាមវាយប្រហាររបស់កងទ័ពរដ្ឋាភិបាលកម្ពុជាម្តងៗ ។ ក្រោយមក អៀង សារី ដឹងថា ភាគីរដ្ឋាភិបាលកម្ពុជាបានប្រកាសពីគោលនយោបាយឈ្នះៗ ដោយធ្វើការបង្រួបបង្រួមជាតិដើម្បីបញ្ចប់ជម្លោះនិងការផ្សះផ្សាជាតិ ។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលកម្ពុជា ក៏បានសន្យានឹងរក្សាទុកនូវតួនាទី និងតំណែងរបស់មេដឹកនាំខ្មែរក្រហមណាដែលចុះចូល ។ វង់ បានបន្ថែមថា អៀង សារី បានចាត់ឲ្យ អ៊ី ឈាន បច្ចុប្បន្នជាអភិបាលខេត្តប៉ៃលិន និង សុខ ភាព បច្ចុប្បន្នជាមេបញ្ជាការកងយុទ្ធពលខេមរភូមិន្ទប្រចាំនៅតំបន់ប៉ោយប៉ែតជាអ្នកចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ នៅឆ្នាំ១៩៩៦ បន្ទាប់ពីការចរចាយ៉ាងស្វិតស្វាញជាមួយរាជរដ្ឋាភិបាលកម្ពុជា អៀង សារី បានដឹកនាំកម្លាំងក្រោមឱវាទនិងប្រជាជនស៊ីវិលនៅតំបន់ម៉ាឡៃនិងតំបន់ប៉ៃលិនធ្វើសមាហរណកម្មដ៏ធំមួយ ដើម្បីចូលរួមរស់ជាមួយរាជរដ្ឋាភិបាលកម្ពុជាវិញ ។

**ម៉ម សុវណ្ណ**



សិស្សានុសិស្សនៅវិទ្យាល័យម៉ាឡៃទទួលបានសៀវភៅ និងឯកសារផ្សេងៗទាក់ទងនឹងរបបខ្មែរក្រហមកាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ កន្លងទៅ

# តើការអត់ឃ្មានចិត្តនៅយ៉ាងដូចម្តេច ហើយមេដឹកនាំខ្មែរក្រហមបានដឹងអ្វីខ្លះទាក់ទងនឹងការអត់ឃ្លានដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម?

## សំឡេងយុត្តិធម៌ ៖ អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

***កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (វគ្គទី៣)***

វគ្គនេះ ផ្តោតសំខាន់ទៅលើការវិវត្តនៃការអត់ឃ្លាន និងធ្វើការប្រៀបធៀបទៅនឹងការអត់ឃ្លានដែលបានកើតមានឡើងនៅក្នុងរបបខ្មែរក្រហម និងស្វែងយល់ថា តើមេដឹកនាំខ្មែរក្រហមសំខាន់ៗ បានដឹងអ្វីខ្លះទាក់ទងនឹងការអត់ឃ្លានដែលបានកើតឡើងនៅរបបខ្មែរក្រហម? សំណួរទាំងអស់ខាងលើនេះមានសារសំខាន់ក្នុងការកំណត់ថាតើគោលនយោបាយដែលបានបង្កើតឡើងដោយមេដឹកនាំខ្មែរក្រហមអាចជាឧក្រិដ្ឋកម្ម ឬគ្រាន់តែជាកំហុសឆ្គងនៃការដឹកនាំ?

បច្ចុប្បន្ន ជនជាប់ចោទនៅក្នុងសំណុំរឿង០០២របស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅសល់តែពីរនាក់ប៉ុណ្ណោះ គឺ នួន ជា និង ខៀវ សំផន បន្ទាប់ពី អៀង សារី បានស្លាប់ដោយសារជំងឺកាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ និង អៀង ធីរិទ្ធ ដែលជាប្រពន្ធរបស់ អៀង សារី ត្រូវបានតុលាការដោះលែងឲ្យនៅក្រៅឃុំ ដោយសារតុលាការរកឃើញថាមានជំងឺវង្វេងវង្វាន់។ អៀង សារី បានស្លាប់មុនការប្រកាសសាលក្រមរបស់តុលាការនេះ មានន័យថា រាល់បទចោទប្រកាន់ទាំងឡាយដែលពាក់ព័ន្ធនឹង អៀង សារី នឹងត្រូវលុបចេញពីសំណុំរឿង។ម្យ៉ាងវិញទៀត នៅពេលដែលបទចោទប្រកាន់នឹង អៀង សារី និង អៀង ធីរិទ្ធ ត្រូវបានដកចេញពីសំណុំរឿងតុលាការនឹងមិនអាចធ្វើការដកហូតទ្រព្យសម្បត្តិរបស់ជនជាប់ចោទទាំងពីរសម្រាប់ប្រើប្រាស់នៅក្នុងគម្រោងសំណងជំងឺចិត្តដល់ជនរងគ្រោះបាននោះទេ។

ដូចដែលយើងបានពិភាក្សានៅក្នុងវគ្គទី២កន្លងមក កង្វះ



ប្រជាជនកម្ពុជាកំពុងដាំស្ល និងរង់ចាំស្រឡាងដើម្បីត្រឡប់ទៅកាន់លំនៅដ្ឋានវិញ ក្រោយរបបខ្មែរក្រហមដួលរលំនៅខែមករា ឆ្នាំ១៩៧៩

អាហារូបត្ថម្ភបានបង្កជាបញ្ហាសុខភាពដែលធ្វើឲ្យប៉ះពាល់ដល់រូបរាងកាយ និងស្មារតីរបស់មនុស្ស ព្រមទាំងធ្វើឲ្យបុគ្គលនោះងាយស្រួលឆ្លងនូវជំងឺផ្សេងៗ ។

នៅពេលដែលការអត់ឃ្លានកើតមានឡើងចំពោះប្រជាជន នោះវានឹងធ្វើឲ្យមានការប៉ះពាល់ដល់សង្គមទាំងមូល ។ នៅពេលដែលមនុស្សគ្រប់គ្នាខំត្រដររស់ក្នុងកាលៈទេសៈដែលសង្គមទាំងមូលកំពុងជួបប្រទះការអត់ឃ្លាន មនុស្សអាចចាប់ផ្តើមបែកបាក់សាមគ្គី បាត់បង់សីលធម៌សង្គម ហើយអំពើហិង្សាអាចនឹងកើតមាន ។ ជាឧទាហរណ៍ នៅពេលដែលការអត់ឃ្លានកើតឡើង ឪពុកម្តាយអាចនឹងលក់ខ្លួនឯង ឬកូនៗរបស់ខ្លួនឲ្យធ្វើជាទាសករ ដោយសង្ឃឹមនឹងទទួលបានអាហារបរិភោគច្រើនជាងមុន ។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនកម្ពុជាជាច្រើនបាននាំគ្នាចុះចូលជាមួយខ្មែរក្រហម ដោយសង្ឃឹមថានឹងអាចទទួលបានរបបអាហារល្អប្រសើរជាងមុន បើទោះជាដឹងថារបបខ្មែរក្រហមបានធ្វើឲ្យប្រជាជនទាំងនោះក្លាយទៅជាមនុស្សឃោរឃៅក៏ដោយ ។ ជាងនេះទៅទៀត នៅពេលដែលរបបខ្មែរក្រហមជិតដួលរលំបក្សកុម្មុយនីស្តកម្ពុជាបានប្រកាសថា ប្រជាជនគ្រប់វណ្ណៈទាំងអស់អាចចុះឈ្មោះចូលបម្រើកងទ័ពបដិវត្តន៍បាន បើទោះបីជាប្រជាជនមួយចំនួនមិនមានប្រវត្តិបដិវត្តន៍ស្អាតស្អំពីមុនក៏ដោយ ។ នៅពេលនោះមានប្រជាជនជាច្រើនបានស្ម័គ្រចូលបម្រើយោធាខ្មែរក្រហមក្នុងការច្បាំងប្រឆាំងនឹងកងទ័ពវៀតណាមនៅសមរភូមិមុខ ដោយសង្ឃឹមថានឹងទទួលបានអាហារូបត្ថម្ភប្រសើរជាងមុន ។

នៅពេលដែលមានការអត់ឃ្លានកើតឡើង អត្រានៃការធ្វើអត្តឃាតក៏កើតមានឡើងដែរ ហើយនេះក៏ជាករណីមួយដែលបានកើតមានឡើងនៅប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម ។ ធ្ងន់ធ្ងរជាងនេះទៅទៀត នៅពេលដែលការអត់ឃ្លានអូសបន្លាយរយៈពេលយូរ និងឈានដល់ដំណាក់កាលធ្ងន់ធ្ងរខ្លាំង អំពើសាហាវព្រៃផ្សៃផ្សេងៗអាចនឹងកើតមាន ដូចជាការបរិភោគសាច់មនុស្ស និងការសម្លាប់កូនខ្លួនឯងជាដើម ។ ជាមួយគ្នានេះដែរ អ្នកដែលរស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើនបាននិយាយថា សកម្មភាពដែលនឹកស្មានមិនដល់ទាំងនោះបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជានៅក្នុងរបបខ្មែរក្រហម ។

ជាទូទៅ នៅពេលដែលមានគ្រោះអត់ឃ្លានកើតឡើង ប្រជាជនតែងតែខិតខំស្វែងរកមធ្យោបាយផ្សេងៗ ដើម្បីកាត់បន្ថយការឈឺចាប់ដែលបង្កឲ្យដោយការអត់ឃ្លាន ។ មនុស្សមួយចំនួនបានខំដើររកប្រភពអាហារផ្សេងៗដែលមិនធ្លាប់បរិភោគពីមុនមក ។ ជាងនេះទៅទៀត ចលនាបន្លាស់ទីទៅកាន់ទីកន្លែងដែលសម្បូរទៅដោយប្រភពចំណីអាហារចាប់ផ្តើមកើតឡើង ។ ដោយឡែក នៅក្នុងរបបខ្មែរក្រហម ប្រជាជនមិនអាចធ្វើសកម្មភាពស្វែងរកអាហារបែបនេះបានទេ ។ គោលនយោបាយរបស់ខ្មែរក្រហមបានហាមប្រាមរាល់ការបរិភោគលក្ខណៈឯកជន ហើយខ្មែរក្រហមបានប្រកាសថា អ្វីៗទាំងអស់ដែលមាននៅក្នុងប្រទេសកម្ពុជា គឺជាទ្រព្យសម្បត្តិរបស់អង្គការបដិវត្តន៍តែមួយគត់ ។ ដូច្នេះហើយរបស់របរទាំងនោះមិនអាចយកបានដោយគ្មានការអនុញ្ញាតពីខ្មែរក្រហមបានទេ ។ ប្រជាជនទាំងអស់ត្រូវបានហាមប្រាមមិនឲ្យដើរស្វែងរកអាហារដោយសេរីទេ ។ អាស្រ័យហេតុដូចនេះហើយជនរងគ្រោះនៅក្នុងរបបខ្មែរត្រូវប្រឈមនឹងការធ្វើការសម្រេចចិត្តថា តើត្រូវតែលួចរកអាហារបន្ថែមដោយលួចលាក់ ឬក៏ត្រូវពឹងផ្អែកទាំងស្រុងទៅលើតែរបបអាហារដែលផ្តល់ឲ្យដោយខ្មែរក្រហមនៅរោងបាយសហករណ៍? ប្រជាជនដែលសម្រេចចិត្តលួចអាហារបន្ថែមប្រឈមនឹងការវាយធ្វើបាប ឬសម្លាប់ ប្រសិនបើខ្មែរក្រហមចាប់បាន ។ ឯកសារដែលនៅសេសសល់ពីរបបខ្មែរក្រហមជាច្រើនបានរៀបរាប់ពីការចាប់ខ្លួនប្រជាជនដែលបានលួចអាហាររបស់បដិវត្តន៍ ឬត្អូញត្អែរពីរបបអាហារដែលមិនគ្រប់គ្រាន់ ។ ក្រោយមកទៀតជនរងគ្រោះទាំងអស់នោះត្រូវបានសម្លាប់ ។

ហេតុដូចច្នេះហើយ យើងសង្កេតឃើញថា ជនរងគ្រោះដោយការអត់ឃ្លានក្នុងរបបខ្មែរក្រហមមិនអាចស្វែងរកមធ្យោបាយណាមួយដើម្បីឧបត្ថម្ភខ្លួនឯងឲ្យរួចផុតពីការលំបាកដែលបង្កឡើងដោយការអត់ឃ្លានបាននោះទេ ។ រាល់សកម្មភាពទាំងឡាយដែលប្រជាជនបានធ្វើ ដូចជាការស្វែងរកអាហារនៅក្នុងព្រៃ ឬការផ្លាស់ទីទៅកាន់តំបន់ដែលមានអាហារ ត្រូវបានចាត់ទុកថាជាទង្វើខុសច្បាប់ ហើយខ្មែរក្រហមបានដាក់ទោសដល់ប្រជាជនទាំងនោះដោយការសម្លាប់ ។ ពោលគឺគ្មាននរណាម្នាក់អាចរត់រួចទេ ។

**តើមេដឹកនាំខ្មែរក្រហមបានដឹងរឿងអ្វីខ្លះទាក់ទងទៅនឹង**

### ការអត់ឃ្លាន?

សំណួរដែលចោទសួរថា «តើមេដឹកនាំកំពូលៗខ្មែរក្រហមបានដឹងអ្វីខ្លះទាក់ទងនឹងការអត់ឃ្លានដែលបានសម្លាប់ប្រជាជនកម្ពុជាអស់ជាច្រើននាក់?» គឺជាសំណួរមួយដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើនចង់ដឹង ។ ជាក់ស្តែង នួន ជា ដែលជាអតីតមេដឹកនាំខ្មែរក្រហមមួយរូបបាននិយាយជាសាធារណៈថា ខ្មែរក្រហមពិតជាបានប្រព្រឹត្តកំហុសឆ្គងមួយចំនួនមែន ។ ប៉ុន្តែ នួន ជា បានអះអាងបន្តថា រដ្ឋាភិបាលខ្មែរក្រហមមិនទទួលខុសត្រូវចំពោះការបង្កឲ្យមានការអត់ឃ្លាននោះទេ ។ ជាងនេះទៅទៀត នួន ជា បានបន្ថែមថា មេដឹកនាំខ្មែរក្រហមមជ្ឈិមបក្សនៅទីក្រុងភ្នំពេញមិនបានដឹងពីលក្ខខណ្ឌរស់នៅពិតប្រាកដរបស់ប្រជាជននៅតាមជនបទនោះទេ ពីព្រោះកម្មាភិបាលថ្នាក់ក្រោមដែលគ្រប់គ្រងនៅតាមតំបន់ទាំងនោះបានធ្វើរបាយការណ៍មិនពិតពីបរិមាណស្រូវដែលផលិតបាន និងបរិមាណអាហារដែលផ្តល់ទៅឲ្យប្រជាជន ។

បើទោះបីជាមិនមានភ័ស្តុតាង ឬព័ត៌មានជាក់លាក់ណាមួយបង្ហាញថា មេដឹកនាំខ្មែរក្រហមបានដឹងពីការអត់ឃ្លានដែលកើតមាននៅទូទាំងប្រទេសកម្ពុជា និងចំនួនប្រជាជនកម្ពុជាដែលត្រូវស្លាប់ដោយសារការអត់អាហារនិងជំងឺក៏ដោយ ក៏មានឯកសារជាច្រើនបានបង្ហាញថា មេដឹកនាំខ្មែរក្រហមបានដឹងអំពីស្ថានភាពទូទៅនៅតាមមូលដ្ឋានដូចខាងក្រោម៖

ទីមួយ ៖ អំណាចទាំងស្រុងគឺស្ថិតនៅលើមេដឹកនាំមជ្ឈិមបក្ស ។ បន្ទាប់ពីកាន់កាប់អំណាច មេដឹកនាំខ្មែរក្រហមបានបង្កើតប្រព័ន្ធរាយការណ៍ថ្នាក់ជាតិមួយដែលតម្រូវឲ្យអ្នកដឹកនាំតាមតំបន់ទាំងអស់ផ្ញើទូរលេខអំពីការងារផ្សេងៗនៅទូទាំងប្រទេស ដូចជា ទិន្នផលស្រូវ ស្ថានភាពសន្តិសុខនៅតាមតំបន់ ទៅមន្ទីរមជ្ឈិមលេខ «៨៧០» នៅទីក្រុងភ្នំពេញ ។ តាមរយៈការរាយការណ៍ទាំងអស់នេះ អាចបង្ហាញឲ្យឃើញថា មេដឹកនាំខ្មែរក្រហមពិតជាបានដឹងពីអ្វីដែលបានកើតឡើងនៅតាមមូលដ្ឋាន ។

ទីពីរ ៖ មេដឹកនាំខ្មែរក្រហមបានត្រួតពិនិត្យនូវរាល់ព័ត៌មានក្រៅប្រទេសផ្សេងៗដែលចុះផ្សាយពីរបបខ្មែរក្រហម និងប្រធានបទដែលពាក់ព័ន្ធផ្សេងៗ ។ ជាក់ស្តែង អត្ថបទដែលបានចុះផ្សាយនៅក្នុងសារព័ត៌មានទាំងនោះបានរៀបរាប់ថា ជនភៀសខ្លួនជាច្រើនដែលរត់គេចទៅប្រទេសថៃជួបប្រទះបញ្ហាកង្វះម្ហូបអាហារដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ ជាការឆ្លើយតបទៅនឹងអត្ថបទសារព័ត៌មានទាំងនោះ មេដឹកនាំខ្មែរក្រហមបាននិយាយជំទាស់ថា របាយការណ៍ទាំងនោះបានបំភ្លៃការពិតពីអ្វីដែលបានកើតឡើងពិតប្រាកដនៅក្នុងប្រទេសកម្ពុជា ។ ជាក់ស្តែង បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ អៀង ធីរិទ្ធ ដែលជាអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចរបស់ខ្មែរក្រហមបានអះអាងនៅក្នុងបទសម្ភាសន៍ជាខ្សែវីដេអូមួយថា «ខ្មែរក្រហមបានផ្តល់អាហារ សម្លៀកបំពាក់ និងសេវាសុខភាពគ្រប់គ្រាន់ទៅឲ្យប្រជាជនកម្ពុជាគ្រប់ៗគ្នា» ។ ស្រដៀងគ្នានឹងនេះដែរ អៀង សារី ដែលជាអតីតឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសរបស់ខ្មែរក្រហម បានធ្វើការអះអាងនៅក្នុងខ្សែវីដេអូមួយផ្សេងទៀតថា «មេដឹកនាំខ្មែរក្រហមមិនបានដឹងពីស្ថានភាពរស់នៅរបស់ប្រជាជនសាមញ្ញនៅតាមទីជនបទនោះទេ ។ នេះជាមូលហេតុមួយដែលបណ្តាលឲ្យមានអំពើឃាតកម្មកើតឡើង ។ ក៏ប៉ុន្តែ ឃាតករទាំងនោះ គឺជាភ្នាក់ងារវៀតណាម ។» ជាងនេះទៅទៀត នៅឆ្នាំ១៩៧៨ ជាឆ្នាំដែលប្រជាជនកម្ពុជារាប់ពាន់នាក់ កំពុងតែស្លាប់ជាបន្តបន្ទាប់ដោយសារការអត់ឃ្លាន ប៉ុល ពត បែរជានិយាយទៅកាន់អ្នកយកព័ត៌មានរបស់ប្រទេសចិនម្នាក់ថា ប្រទេសកម្ពុជាសម្បូរទៅដោយផលិតផលស្បៀងអាហារ ។ មិនតែប៉ុណ្ណោះ ប៉ុល ពត បានអះអាងថា «ប្រសិនបើយើងធ្វើការប្រៀបធៀបសេដ្ឋកិច្ច និងផលិតផលស្បៀងអាហាររវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម នោះយើងនឹងឃើញថា ប្រទេសកម្ពុជាមានស្បៀងអាហារគ្រប់គ្រាន់ ចំណែកឯប្រទេសវៀតណាមវិញ កំពុងតែញាំញីដោយបញ្ហាកង្វះខាតស្បៀងអាហារ ។ ដូច្នេះ យើងសង្កេតឃើញថា ប្រទេសកម្ពុជាមានប្រៀបជាងប្រទេសវៀតណាមខាងស្បៀងអាហារ» ។ វាគឺជារឿងមួយពិបាកនឹងជឿ នៅពេលដែលមេដឹកនាំខ្មែរក្រហមនិយាយថា ខ្លួនមិនបានដឹងអំពីការអត់ឃ្លានដែលបានកើតឡើង ។ ផ្ទុយទៅវិញ មេដឹកនាំខ្មែរក្រហមបែរជាប្រកាសជាអន្តរជាតិថា ការអត់ឃ្លានមិនបានកើតឡើងនៅក្នុងប្រទេសកម្ពុជាទេ ។

ទីបី ៖ នៅក្នុងរបបខ្មែរក្រហម មេដឹកនាំខ្មែរក្រហមបានធ្វើទស្សនកិច្ចទៅកាន់តំបន់មូលដ្ឋានដើម្បីត្រួតពិនិត្យការងារ ។ មិនតែ

ប៉ុណ្ណោះ មេដឹកនាំខ្មែរក្រហមបានធ្វើការបោសសម្អាតកម្មាភិបាលខ្មែរក្រហមរូបណាដែលបានទទួលស្គាល់ថា ការអត់ឃ្លានពិតជាបានកើតមាននៅតំបន់ដែលខ្លួនគ្រប់គ្រង ។ បន្ថែមពីនេះទៅទៀត មេដឹកនាំខ្មែរក្រហមបានប្រគល់ទង់កិត្តិយសទៅឲ្យតំបន់ណាដែលអាចសម្រេចតាមផែនការរបស់បដិវត្តន៍ ។ ជាឧទាហរណ៍ ខ្មែរក្រហមបានប្រគល់ទង់កិត្តិយសទៅឲ្យតំបន់មួយចំនួននៃភូមិភាគនិរតីដែលការអត់ឃ្លាននៅតំបន់ទាំងនោះមានលក្ខណៈមិនសូវធ្ងន់ធ្ងរដូចតំបន់ដទៃ ។ ពោលគឺផលិតផលស្រូវនៅភូមិភាគនិរតីច្រើនជាងតំបន់ផ្សេងៗទៀតនៃភូមិភាគពាយ័ព្យ និងភូមិភាគឧត្តរ ។ កត្តាផ្សេងទៀតដែលកម្មាភិបាលខ្មែរក្រហមនៅភូមិភាគនិរតីមិនត្រូវបានអង្គការចាប់ខ្លួនពីព្រោះភូមិភាគនិរតីសម្រេចបានទិន្នផលស្រូវតាមផែនការកំណត់ និងមិនបានរាយការណ៍អំពីបញ្ហាណាមួយដែលទាក់ទងនឹងផលិតកម្មស្រូវ ។ មិនតែប៉ុណ្ណោះ តាម៉ុក គឺជាមេដឹកនាំភូមិភាគនិរតីដែលទទួលបានការជឿជាក់ពីសំណាក់ខ្មែរក្រហម នៅពេលដែលមេដឹកនាំដទៃទៀតនៃភូមិភាគពាយ័ព្យ និងភូមិភាគបូព៌ាមិនត្រូវបាន ប៉ុល ពត និងមេដឹកនាំខ្មែរក្រហមផ្សេងទៀតទុកចិត្តទាំងស្រុងនៅឡើយ ។ ម្ល៉ោះហើយ ខ្មែរក្រហមបានដាក់កំហិតឲ្យតំបន់ទាំងនោះផលិតស្រូវឲ្យបានច្រើន ជាពិសេសតំបន់នៅភូមិភាគពាយ័ព្យ ។ នៅពេលដែលតំបន់ទាំងនោះមិនអាចសម្រេចទិន្នផលស្រូវតាមផែនការកំណត់ ឬបានរាយការណ៍ថាមានមនុស្សស្លាប់ដោយសារការអត់ឃ្លាន និងជំងឺ ខ្មែរក្រហមបានធ្វើការបោសសម្អាត និងសម្លាប់ថ្នាក់ដឹកនាំតាមមូលដ្ឋាន ។ ផ្ទុយទៅវិញ ខ្មែរក្រហមមិនបានចាត់វិធានការណាមួយ ដើម្បីដោះស្រាយបញ្ហាដែលបានកើតឡើងពាក់ព័ន្ធនឹងការអត់ឃ្លាននោះទេ ។ ជាក់ស្តែង នៅឆ្នាំ១៩៧៦ អៀង ធីរិទ្ធ បានធ្វើទស្សនកិច្ចដោយផ្ទាល់ទៅកាន់ភូមិភាគពាយ័ព្យ ហើយបានរាយការណ៍ទៅថ្នាក់ដឹកនាំបក្សថា ប្រជាជននៅតាមមូលដ្ឋានកំពុងរស់នៅក្នុងលក្ខខណ្ឌដ៏អាក្រក់ ។ ប្រជាជននៅតំបន់ទាំងនោះទទួលរងគ្រោះ ដោយការអត់ឃ្លាន និងជំងឺរាក ។ បន្ទាប់ពីរបាយការណ៍ស្តីអំពីស្ថានភាពនៅភូមិភាគពាយ័ព្យត្រូវបានបញ្ជូនទៅថ្នាក់ដឹកនាំបក្ស ខ្មែរក្រហមបានបញ្ជូនកម្មាភិបាលខ្មែរក្រហមពីភូមិភាគនិរតីទៅកាន់ភូមិភាគពាយ័ព្យ និងធ្វើការបោសសម្អាតថ្នាក់ដឹកនាំភូមិភាគពាយ័ព្យទាំងស្រុង ។ ដូច្នេះ យើងសង្កេតឃើញថា ជំនួសឲ្យការស្វែងរកដំណោះស្រាយទៅលើបញ្ហាអត់ឃ្លានដែលកំពុងតែកើតមាន ថ្នាក់ដឹកនាំបក្សបែរជាស្តីបន្ទោស និងសម្លាប់កម្មាភិបាលថ្នាក់ក្រោមទៅវិញ ។

ដោយផ្អែកលើឧទាហរណ៍ដែលបានលើកឡើងខាងលើ យើងអាចសន្និដ្ឋានបានថា មេដឹកនាំខ្មែរក្រហមបានដឹងយ៉ាងច្បាស់ថាមានប្រជាជនជាច្រើននៅតាមមូលដ្ឋានកំពុងតែជួបប្រទះការអត់ឃ្លាននៅក្នុងអំឡុងពេលនៃការកាន់អំណាចរបស់ខ្មែរក្រហម ។ ជាងនេះទៅទៀត ថ្នាក់ដឹកនាំខ្មែរក្រហមបានជ្រើសរើសការប្រើប្រាស់អំពើហិង្សា និងការស្តីបន្ទោសទៅលើកម្មាភិបាលថ្នាក់ក្រោមអំពីបញ្ហាដែលបានកើតឡើង ដោយមិនបានពិចារណាក្នុងការផ្លាស់ប្តូរនូវគោលនយោបាយរបស់ខ្លួនដែលបណ្តាលឲ្យមានការអត់ឃ្លានកើតឡើង ។ ការប្រើប្រាស់អំពើហិង្សា និងការសង្ស័យចំពោះកម្មាភិបាលថ្នាក់ក្រោមបានធ្វើឲ្យប្រជាជនទូទៅជួបប្រទះការអត់ឃ្លាន និងបានបង្កជាផលវិបាកផ្សេងៗដល់កម្មាភិបាលថ្នាក់ក្រោមនៅតាមមូលដ្ឋាន ។ ពោលគឺចំពោះកម្មាភិបាលថ្នាក់មូលដ្ឋានរូបណាដែលទទួលស្គាល់ថា តំបន់របស់ខ្លួនគ្រប់គ្រងមិនអាចសម្រេចបានទិន្នផលស្រូវតាមផែនការកំណត់របស់បក្ស កម្មាភិបាលរូបនោះត្រូវប្រឈមនឹងការបោសសំអាតយ៉ាងព្រៃផ្សៃបំផុត ។ ផ្ទុយទៅវិញ ប្រសិនបើកម្មាភិបាលថ្នាក់មូលដ្ឋានរូបណាដែលអាចផ្តល់ទិន្នផលស្រូវតាមតម្រូវការរបស់មជ្ឈិមបក្ស កម្មាភិបាលរូបនោះអាចគេចផុតពីការបោសសម្អាតរបស់បក្ស ។ ដូច្នេះ ប្រជាជនទូទៅណាដែលប៉ុនប៉ងរកអាហារបន្ថែម ត្រូវប្រឈមមុខនឹងការប្រើអំពើហិង្សា និងការសម្លាប់ ។

ពាក្យស្លោករបស់ខ្មែរក្រហមបានលើកឡើងថា អង្គការខ្មែរក្រហមជា “អង្គការភ្នែកម្នាស់” និងអាចដឹងគ្រប់រឿងរ៉ាវទាំងអស់ដែលបានកើតឡើង ។ ពាក្យស្លោកដ៏គួរឲ្យខ្លាចមួយឃ្លានេះពិតជាស្តែងឡើងចំពោះបុគ្គលណាដែលត្រូវបានចាត់ទុកថាជាសត្រូវរបស់អង្គការ ។ យោងតាមពាក្យស្លោកមួយឃ្លានេះ អង្គការបានត្រឹមតែអង្គុយមើលប្រជាជនដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនទទួលរងទុក្ខវេទនា និងស្លាប់ដោយសារការអត់ឃ្លាន ប៉ុន្តែមិនបានធ្វើអ្វីដើម្បីជួយដោះស្រាយបញ្ហានៃទុក្ខវេទនារបស់ប្រជាជននោះទេ ។ **រ៉េនឌល ជីហ្វាល់កូ**

# អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ជនជាប់ចោទ នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការជំនុំជម្រះ

ដោយសារជនជាប់ចោទ អៀង សារី ស្លាប់នៅថ្ងៃទី១៤ ខែមីនា និងការដោះលែងប្រពន្ធរបស់គាត់នៅឆ្នាំ២០១២ ដែលមានជំងឺភ្លេចភ្លាំង មានតែមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ពីរនាក់ប៉ុណ្ណោះ កំពុងត្រូវបានជំនុំជម្រះក្នុងសំណុំរឿង០០២នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជនជាប់ចោទ ខៀវ សំផន បានទាមទារបញ្ជូនខ្លួនគាត់ទៅមន្ទីរពេទ្យដើម្បីព្យាបាលជំងឺកាលពីចុងឆ្នាំ២០១២ ប៉ុន្តែផ្ទុយទៅវិញ ចុងចោទអាយុជាង៨០ឆ្នាំរូបនេះមានសុខភាពមាំមួន ហើយជាមនុស្សម្នាក់គត់ដែលអាចចូលរួមដំណើរការនីតិវិធីបានពេញលេញ ។ ជនជាប់ចោទ នួន ជា ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យចំនួនពីរដងក្នុងឆ្នាំនេះ ហើយជាទៀងទាត់ស្នើសុំសម្រាកនៅពេលព្រឹក ដោយសុខចិត្តចូលរួមសវនាការពីបន្ទប់សោតទស្សន៍ដែលបំពាក់ទូរទស្សន៍ និងប្រព័ន្ធស្តាប់សំឡេងដោយសារតែជំងឺខាងរាងកាយរ៉ាំរ៉ៃ រួមមាន ឈឺក្បាល វិលមុខ ឈឺខ្នង អស់កម្លាំង និងខ្វះការផ្តោតអារម្មណ៍ ។ ថ្មីៗនេះ អ្នកជំនាញផ្នែកវេជ្ជសាស្ត្រម្នាក់បានផ្តល់សក្ខីកម្មថា គាត់នឹងមិនភ្ញាក់ផ្អើលទេ ប្រសិនបើ នួន ជា ស្លាប់ក្នុងរង្វង់រយៈពេលប្រាំមួយខែទៀត ដោយសង្កត់ធ្ងន់ថា នេះមិនមែនជាការទស្សទាយនោះឡើយ ប៉ុន្តែជាការទទួលស្គាល់មួយសម្រាប់វ័យ៨៦ឆ្នាំ ដែល «ជីវិតមិនទៀងទាត់ឡើយ» ។


នួន ជា នៅក្នុងបន្ទប់សវនាការនៃតុលាការខ្មែរក្រហម (រូបថត : អ.វ.ត.ក)

បន្ទាប់ពីការបបញ្ជូន នួន ជា ទៅព្យាបាលនៅមន្ទីរពេទ្យនៅខែមករា ឆ្នាំ២០១៣ ដោយសារតែជំងឺរលាកទងសួតធ្ងន់ធ្ងរ និងជំងឺធ្វើឲ្យចុះខ្សោយសាច់ដុំ ហើយខែកុម្ភៈ ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ព្យាបាលជំងឺឡើងឈាម ជំងឺផ្លុយដេក និងជំងឺអស់កម្លាំង ។ វេជ្ជបណ្ឌិតបានរាយការណ៍ថា ស្ថានភាពរបស់គាត់ចុះទន់ខ្សោយ ប៉ុន្តែនៅស្ថិតស្ថេរនៅឡើយ ។ ក្រុមមេធាវីការពារក្តីបាននិយាយលើកហេតុផលថា ជំងឺរាងកាយជាច្រើន និងការចុះទន់ខ្សោយផ្នែកសតិអារម្មណ៍របស់ នួន ជា ទាមទារឲ្យមានការព្យាបាល និងការវាយតម្លៃផ្នែករាងកាយ និងសតិអារម្មណ៍បន្ថែមមុនពេលដែលគាត់អាចត្រូវបានរកឃើញថា មានសម្បទាគ្រប់គ្រាន់ក្នុងការបន្តការចូលរួមដំណើរការនីតិវិធីសវនាការ ។ ប៉ុន្តែក្រុមមេធាវីការពារក្តី ស្វែងរកការអនុញ្ញាតសម្រាប់ នួន ជា ក្នុងការតាមដានសវនាការតាមរយៈទូរទស្សន៍ ឬប្រព័ន្ធស្តាប់សំឡេងពីកន្លែងឃុំឃាំង ពីព្រោះគាត់ត្រូវបានផ្លាស់ប្តូរទៅបន្ទប់សវនាការ និងបន្ទប់សោតទស្សន៍ជាន់ក្រោមដែលធ្វើឲ្យគាត់នឿយហត់រហូតដល់មិនអាចចូលរួមដំណើរការនីតិវិធីដោយមានប្រសិទ្ធភាព ។

នៅចុងខែមិនា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានស្តាប់សក្ខីកម្មអ្នកជំនាញវេជ្ជសាស្ត្រពីររូបជំទាស់ទៅនឹងការស្នើសុំរបស់ក្រុមមេធាវីការពារក្តី ហើយដោយអនុវត្តតាមតុលាការឧក្រិដ្ឋកម្មអន្តរជាតិចំពោះលក្ខណៈវិនិច្ឆ័យតាមសំណុំរឿង ស្រ្តូហ្គារ (Strugar) របស់អតីតប្រទេសយូហ្គូស្លាវី បានរកឃើញថា នួន ជា មានសម្បទាគ្រប់គ្រាន់

សម្រាប់ជំនុំជម្រះ ។ ការវាយតម្លៃថាតើគាត់អាចចូលរួមពេញលេញក្នុងដំណើរការនីតិវិធីដែលអនុញ្ញាតឲ្យជនជាប់ចោទអនុវត្តនូវសិទ្ធិជំនុំជម្រះដោយយុត្តិធម៌របស់ខ្លួនដល់កម្រិតមួយដែលគាត់អាចចូលរួមសវនាការយ៉ាងមានប្រសិទ្ធភាព និងមានការយល់ដឹងអំពីសារសំខាន់នៃដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានពិចារណាទាំងរបាយការណ៍វេជ្ជសាស្ត្រ និងការសង្កេតការណ៍របស់ខ្លួនទាក់ទងទៅនឹងលក្ខខណ្ឌវេជ្ជសាស្ត្ររបស់ នួន ជា និងផលប៉ះពាល់នៃរបាយការណ៍នោះមកលើសមត្ថភាពរបស់គាត់ក្នុងការយល់ដឹងនិងតាមដានដំណើរការនីតិវិធីដោយមានជំនួយពីក្រុមមេធាវីការពារក្តី ។

អង្គជំនុំជម្រះសាលាដំបូង បានទទួលយកការបញ្ជាក់របស់អ្នកជំនាញដែលថា បញ្ហាសុខភាពរបស់ នួន ជា មិនបានធ្វើឲ្យប៉ះពាល់ដល់ការចូលរួមក្នុងដំណើរការនីតិវិធីនោះឡើយ ។ ជំងឺបេះដូងរបស់គាត់កំពុងត្រូវបានត្រួតពិនិត្យតាមរយៈការប្រើប្រាស់ឱសថ ហើយការឈឺចាប់ផ្នែកខ្នងរបស់គាត់បានធូរស្បើយតាមរយៈការប្រើប្រាស់ឱសថបំបាត់ការឈឺចុកចាប់ ។ អង្គជំនុំជម្រះបានទទួលស្គាល់ថា ជំងឺផ្នែកទ្រូង និងការរវើរវាយ ដែលបានតម្រូវឲ្យមានការព្យាបាលនៅមន្ទីរពេទ្យត្រូវបានដោះស្រាយរួចហើយ ។ ទោះបីជាការចាប់ផ្តើមមានជំងឺភ្នែកឡើងបាយ បានធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពក្នុងការអានអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ក្រុមមេធាវីការពារក្តីរបស់គាត់អាចអានឯកសារច្បាប់ជាច្រើនសម្រាប់រូបគាត់បាននៅពេលដែលមានការតម្រូវ ។

មិនមានអ្វីដែលជនជាប់ចោទត្រូវមានការចងចាំរយៈពេលវែង និងខ្លី ដើម្បីចងចាំព្រឹត្តិការណ៍ ចាប់តាំងពីពេលនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម និងត្រូវធ្វើអត្ថាធិប្បាយលើភស្តុតាងដែលបានបង្ហាញនោះឡើយ ។ អង្គជំនុំជម្រះសាលាដំបូង បានទទួលយកការបញ្ជាក់របស់អ្នកជំនាញ ដែលទោះបីជា នួន ជា បានជួបប្រទះការធ្លាក់ចុះអន់ខ្សោយខាងការចងចាំរយៈពេលខ្លីរបស់គាត់ ។ រឿងនេះមិនគ្រប់គ្រាន់ក្នុងការធ្វើឲ្យប៉ះពាល់ដល់សមត្ថភាពក្នុងការចូលរួមជាមួយក្រុមមេធាវីការពារក្តីរបស់ខ្លួនឡើយ ។ ជាងនេះទៅទៀត ការចងចាំរយៈពេលវែងរបស់គាត់នៅតែមានដដែល ។ អង្គជំនុំជម្រះបានទទួលយកគំហើញរបស់អ្នកជំនាញដែលថា នួន ជា មិនមានបញ្ហាផ្នែកប្រមូលផ្តុំស្មារតី ហើយមានសមត្ថភាពផ្តុំស្មារតី រហូតដល់ពីរម៉ោងដោយគ្មានការនឿយហត់ ។ ដូច្នេះហើយ អង្គជំនុំជម្រះបានរកឃើញថា នួន ជា មានសមត្ថភាពក្នុងការសារភាពទទួលកំហុស យល់ដឹងអំពីលក្ខណៈនៃការចោទប្រកាន់ សកម្មភាពនៃដំណើរការនីតិវិធីសេចក្តីលម្អិតភស្តុតាង បច្ច័យនៃដំណើរការនីតិវិធី និងមានសមត្ថភាពចង្អុលបង្ហាញក្រុមមេធាវីការពារក្តី និងផ្តល់សក្ខីកម្ម ។

ដោយផ្អែកលើទស្សនៈរបស់អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ អង្គជំនុំជម្រះសាលាដំបូងបានយល់ស្របថា កិច្ចខិតខំប្រឹងប្រែងសមហេតុផលក្នុងការសម្របសម្រួលឲ្យមានការចូលរួមដំណើរការនីតិវិធីរបស់ នួន ជា តាមរយៈការសម្រុះសម្រួលនូវលក្ខខណ្ឌទន់ខ្សោយរបស់គាត់គឺជាការសមស្រប ។ ទោះបីជាយ៉ាងនេះក៏ដោយ កិច្ចខិតខំប្រឹងប្រែងនោះមិនស្របជាមួយនឹងក្រុមមេធាវីការពារក្តី ដែលជំងឺរបស់ នួន ជា បានធ្វើឲ្យការចូលរួមដំណើរការនីតិវិធីពីបន្ទប់សោតទស្សន៍ ដែលបំពាក់សេវាសម្បទាយ៉ាងពិសេសនោះមានភាពស្មុគស្មាញហើយបានសម្រេចថា នួន ជា ត្រូវតែចូលរួមដំណើរការនីតិវិធីទាំងក្នុងបន្ទប់សោតទស្សន៍ និងបន្ទប់សវនាការ ៖

បន្ទប់សោតទស្សន៍ដែលបំពាក់សេវាសម្បទាយ៉ាងពិសេស មានបំពាក់ឧបករណ៍ស្តាប់សំឡេង និងមើលរូបភាពដែលបញ្ជូនរូបភាពផ្សាយផ្ទាល់នៃដំណើរការនីតិវិធីទូរស័ព្ទ ដែលអាចឲ្យជនជាប់ចោទធ្វើការទំនាក់ទំនងដោយសេរី និងសម្ងាត់ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់ខ្លួនហើយគ្រែដែលអាចបត់បាន ត្រូវបានបំពាក់ដើម្បីធ្វើឲ្យធូរស្រាលដល់លក្ខខណ្ឌរាងកាយរបស់ជនជាប់ចោទ ។ ជាងនេះទៅទៀត ដោយសារបន្ទប់សោតទស្សន៍មានទីតាំងនៅក្នុងអគារតុលាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សមាជិកនៃក្រុមមេធាវីការពារក្តីអាចចូលជួបជនជាប់ចោទបានពេញមួយថ្ងៃ ។

ដោយសារភាពមិនទៀងទាត់នៃសុខភាពរបស់គាត់ លទ្ធភាពពិតប្រាកដ ដែល នួន ជា មិនអាចនៅមើលសេចក្តីសម្រេចនឹងនៅតែជាការព្រួយបារម្ភយ៉ាងខ្លាំងសម្រាប់តុលាការក្នុងអំឡុងពេលដែលដំណើរការនីតិវិធីនៅសេសសល់ ។ **អាន ហាញឌល**

# សំណុំរឿងប្រាសាទព្រះវិហារ : កម្ពុជា និង ថៃ នៅតុលាការយុត្តិធម៌អន្តរជាតិ

ក្រុមអ្នកច្បាប់របស់ប្រទេសថៃ និងកម្ពុជា ទើបតែបានបញ្ចប់ការធ្វើអំណះអំណាងផ្ទាល់មាត់រៀងៗខ្លួន នៅខណៈដែលតុលាការយុត្តិធម៌អន្តរជាតិពិចារណាចំពោះសំណើរបស់កម្ពុជាសុំឲ្យធ្វើការបកស្រាយឡើងវិញនូវសាលក្រមឆ្នាំ១៩៦២ ស្តីពីជម្លោះជុំវិញប្រាសាទព្រះវិហារ ។ ជម្លោះដែលបានកើតឡើងសាជាថ្មីចាប់ពីឆ្នាំ២០០៧ ភាគច្រើន គឺបណ្តាលមកពីកម្លាំងនយោបាយជាតិនិយម ជាពិសេស ចលនាអាវលឿងនៅក្នុងប្រទេសថៃ ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក្តី ជម្លោះនេះបានកើតឡើងក៏ដោយសារតែការពុំយល់ស្របគ្នាលើភាពត្រឹមត្រូវផ្នែកគតិយុត្តិដែលបច្ចុប្បន្ននេះភាគីទាំងពីរកំពុងលើកឡើងចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ មូលដ្ឋានដែលខ្លួនយល់ឃើញថា អត្ថន័យគួរតែមានខ្លឹមសារបែបណា ។ ការពិនិត្យមើលមួយឲ្យកាន់តែច្បាស់លើជម្លោះគតិយុត្តិនេះ បានបង្ហាញឲ្យឃើញនូវច្រកមួយដើម្បីដោះស្រាយជម្លោះដែលបង្កមហន្តរាយធ្ងន់ធ្ងរ ។

ភាពចម្រូងចម្រាសនាពេលបច្ចុប្បន្ននេះ ផ្តោតទៅលើព្រំដែននៅតំបន់ជុំវិញប្រាសាទព្រះវិហារ ។ សាលក្រមឆ្នាំ១៩៦២ បានប្រគល់ប្រាសាទព្រះវិហារមកឲ្យកម្ពុជា និងតម្រូវឲ្យប្រទេសថៃដកកងកម្លាំងសន្តិសុខដែលបានដាក់នៅក្នុងប្រាសាទ ឬ "ក្នុងតំបន់ក្បែរប្រាសាទដែលស្ថិតក្នុងទឹកដីកម្ពុជា" ។ តុលាការបានផ្តល់ហេតុផលថា ថៃបានទទួលស្គាល់ផែនទីឆ្នាំ១៩០៧ អំពីខ្សែបន្ទាត់




ផែនទីប្រាសាទព្រះវិហារ (ប្រភព : ទីស្តីការគណៈរដ្ឋមន្ត្រី)

ព្រំដែន ដែលរៀបចំឡើងដោយ អ្នកជំនាញគូសដែនទីរបស់បារាំង ដែលបានដាក់ប្រាសាទព្រះវិហារចូលក្នុងទឹកដីប្រទេសកម្ពុជា ។ ទោះបីជាយ៉ាងណាក្តី តុលាការពុំបានកំណត់អំពីតំបន់ក្បែរប្រាសាទ ឬពិភាក្សាអំពីស្ថានភាពគតិយុត្តិរបស់ផែនទីឆ្នាំ១៩០៧នៅក្នុង ផ្នែកនៃសេចក្តីសន្និដ្ឋានដែលនិយាយអំពីសេចក្តីសម្រេចនោះទេ ។

កាលពីសប្តាហ៍មុន ក្រុមអ្នកច្បាប់ថៃបានអះអាងថា សេចក្តីសម្រេចឆ្នាំ១៩៦២របស់តុលាការជាប់ពាក់ព័ន្ធតែនឹង តួប្រាសាទ និងតំបន់ជុំវិញដែលនៅកៀកៗតែប៉ុណ្ណោះ ។ អ្នកច្បាប់ទាំងនោះ បានលើកឡើងថា ថៃបានគោរពតាមសាលក្រម ដែលតម្រូវឲ្យខ្លួនដកកងកម្លាំងសន្តិសុខចេញពីតួប្រាសាទ និងថា កម្ពុជាបានទទួលយកការអនុវត្តរបស់ថៃហើយ ។ ក្រុមអ្នកច្បាប់ថៃ បានលើកឡើងថា ហេតុដូច្នេះ ពុំគួរមានការបកស្រាយឡើងវិញនូវសាលក្រមរបស់តុលាការយុត្តិធម៌អន្តរជាតិទេ ។ ក្រុមអ្នកច្បាប់កម្ពុជាបានឆ្លើយតបថា ជម្លោះពិតជាបានកើតឡើងមែន ហើយថា សាលក្រមបានបង្ហាញពីលក្ខណៈដែលត្រូវប្រតិបត្តិតាម លើខ្សែបន្ទាត់ផែនទី ព្រោះសេចក្តីសម្រេចនៅក្នុងសាលក្រម ឆ្នាំ១៩៦២ គឺពុំអាចកាត់ផ្តាច់ចេញពីសេចក្តីសំអាងហេតុបានឡើយ ។ ដូច្នេះ ក្រុមអ្នកច្បាប់កម្ពុជាបានអះអាងថា ទាំងប្រាសាទព្រះវិហារនិងដីទំហំ៤.៦គីឡូម៉ែត្រការ៉េដែលនៅជាប់ផ្នែកខាងលិច គឺជាកម្មសិទ្ធិរបស់កម្ពុជាៈ

នៅពេលពិចារណាអំពីការលើកអំណះអំណាងនេះ តុលាការយុត្តិធម៌អន្តរជាតិត្រូវប្រឈមនឹងសំណួរគតិយុត្តិជាមូលដ្ឋានចំនួនពីរៈ ១) តើជម្លោះរវាងប្រទេសថៃនិងកម្ពុជាពន្យល់ នូវលក្ខណៈស្របច្បាប់ឲ្យមានការបកស្រាយឡើងវិញនូវសាលក្រម ឆ្នាំ១៩៦២ ដែរឬយ៉ាងណា? ២) ហើយប្រសិនបើតុលាការ សម្រេចបកស្រាយឡើងវិញនូវសាលក្រមនេះមែន តើផ្នែកទាំងអស់ ឬផ្នែកណាមួយនៃផែនទីឆ្នាំ១៩០៧គួរត្រូវប្រតិបត្តិតាម?

កម្ពុជាគួរតែឈ្នះចំពោះសំណួរទីមួយ ។ តុលាការបាន សម្រេចកាលពីឆ្នាំ២០១១ថា ជម្លោះទំនងជាបានកើតឡើងមែន រវាងភាគីទាំងពីរ ហើយការលើកឡើងនៅក្នុងសវនាការផ្ទាល់មាត់ ថ្មីៗនេះពុំមានអ្វីដែលគួរឲ្យចៅក្រមត្រូវសម្រេចផ្ទុយពីនេះឡើយ ។ នៅក្នុងយុត្តិសាស្ត្រដែលពាក់ព័ន្ធ ពុំមានការកំណត់អំពីអាជ្ញាយុកាល ស្តីពីការបកស្រាយឡើងវិញនូវសាលក្រមតុលាការយុត្តិធម៌អន្តរជាតិទេ ហើយជម្លោះក៏ពុំចាំត្រូវតែកើតមានឡើងជាផ្លូវការដែរ ។ ជម្លោះនោះចាំបាច់ត្រូវតែជាប់ពាក់ព័ន្ធនឹងផ្នែកនៃសេចក្តីសន្និដ្ឋាន របស់សាលក្រម ឬផ្នែកនៃសេចក្តីសំអាងដែលត្រូវបានចាត់ទុកថា "ពុំអាចផ្តាច់ចេញពីសាលក្រមបាន" ។ យ៉ាងហោចណាស់ នៅក្នុង ឯកសារដែលភាគីទាំងពីរបានដាក់ជូនតុលាការយុត្តិធម៌អន្តរជាតិ ចាប់តាំងពី២០១១ បានចង្អុលបង្ហាញថា ភាគីទាំងពីរមានការបកស្រាយផ្ទុយគ្នាចំពោះឃ្លានៅក្នុងសេចក្តីសន្និដ្ឋានដែលនិយាយ យោងទៅ "ទឹកដីនៃប្រទេសកម្ពុជា" និង "តំបន់ក្បែរ" ប្រាសាទ ព្រះវិហារ ។ ជាងនេះទៅទៀត ក្រុមមេធាវីកម្ពុជាបានបង្ហាញនូវ ភស្តុតាងយ៉ាងច្រើនដែលបញ្ជាក់ថា ជម្លោះអំពីការបកស្រាយ គឺពុំមែនជារឿងថ្មីនោះទេ ។ ពេញមួយទសវត្សរ៍ឆ្នាំ១៩៦០ សម្តេចព្រះ នរោត្តម សីហនុ និងអ្នកផ្សេងៗទៀត បានសម្តែង នូវការមិនសុខចិត្តចំពោះការដាក់ទាហានរបស់ថៃ និងការដាក់របង ខ្សែលួសបន្លានៅក្នុងតំបន់ជម្លោះដែលមានទំហំ៤.៦គីឡូម៉ែត្រ ក្រឡា ។

សំណួរដែលលំបាកជាងនេះថាតើ ឬដល់កម្រិតណាដែល សេចក្តីសំអាងរបស់តុលាការគួរតែត្រូវបានបកស្រាយភ្ជាប់ទៅ នឹងសេចក្តីសន្និដ្ឋាននៃសាលក្រមឆ្នាំ១៩៦២ ដែលដាក់ឲ្យប្រតិបត្តិ តាម ។ ដូចដែលក្រុមអ្នកច្បាប់ថៃបានសង្កត់ធ្ងន់ ថាតុលាការបាន បដិសេធយ៉ាងច្បាស់នូវសំណើរបស់កម្ពុជាដែលសុំឲ្យសម្រេចលើ ស្ថានភាពគតិយុត្តិនៃផែនទីឆ្នាំ១៩០៧ នៅក្នុងផ្នែកសេចក្តីសន្និដ្ឋាន នៃសាលក្រម ។ ប្រទេសថៃបានអះអាង ពុំមែនដោយមិនសម ហេតុផលនោះទេថា ការមិនសម្រេចលើស្ថានភាពគតិយុត្តិនៃ ផែនទីនេះ បង្ហាញថា តុលាការបានមើលឃើញអំពីស្ថានភាពនៃ ព្រំដែន និងរឿងប្រាសាទថាជាសំណួរគតិយុត្តិដាច់ដោយឡែក ពីគ្នា ហើយថា កម្ពុជាគឺស្វែងរកការសម្រេចមួយដែលតុលាការ ធ្លាប់បានបដិសេធរួចហើយកាលពីឆ្នាំ១៩៦២ ។ ប៉ុន្តែការលើក ឡើងនេះ គឺមានបញ្ហា ។

ដូចដែលក្រុមមេធាវីកម្ពុជាបានលើកឡើងនៅទីក្រុងឡាអេ ដូច្នេះដែរថា គេមិនអាចនិយាយសំដៅទៅរក "ទឹកដី" កម្ពុជានៅ ក្នុងសេចក្តីសន្និដ្ឋានឲ្យបានប្រសើរនោះឡើយ ដោយពុំបានដឹងថា



ប្រាសាទព្រះវិហារ

ទឹកដីនោះនៅកន្លែងណា។ ដើម្បីសម្រេចអំពីអធិបតេយ្យភាពជុំវិញ "តំបន់ជម្លោះ" ដែលតុលាការបានកំណត់ថាជា "តំបន់ប្រាសាទព្រះវិហារ" តុលាការបានប្រកាសថាសំណួរដែល "ពិតប្រាកដ" និង "សំខាន់" នៅក្នុងសំណុំរឿងនេះគឺ "ថាតើភាគីទាំងពីរយល់ព្រមទទួលយកផែនទីឆ្នាំ១៩០៧ "និងខ្សែបន្ទាត់ដែលបញ្ជាក់នៅលើផែនទីនោះថាបានកើតចេញពីលទ្ធផលនៃការកំណត់ខ្សែបន្ទាត់ព្រំដែននៅក្នុងតំបន់ប្រាសាទព្រះវិហារដែលផ្តល់នូវលក្ខខណ្ឌសម្រាប់ភាគីទាំងពីរក្នុងការប្រតិបត្តិតាមដែរឬយ៉ាងណា"។ ក្រោយពីការវិភាគយ៉ាងយូរ តុលាការបានសម្រេច "យកតាមខ្សែបន្ទាត់ដូចដែលបានគូសឲ្យនៅក្នុងផែនទីឆ្នាំ១៩០៧ "នៅក្នុងតំបន់ជម្លោះ"។ ការសម្រេចបែបនេះ បានដាក់ប្រាសាទព្រះវិហារឲ្យស្ថិតនៅក្នុងទឹកដីកម្ពុជានិងបានធ្វើឲ្យសេចក្តីសំអាងរបស់តុលាការពុំអាចកាត់ផ្តាច់ចេញពីសេចក្តីសន្និដ្ឋានរបស់ខ្លួនបានឡើយនេះបើយោងតាមក្រុមមេធាវីកម្ពុជា។

ការអះអាងរបស់កម្ពុជាដែលថា សាលក្រមនេះបានសម្រេចចំពោះខ្សែបន្ទាត់ព្រំដែនទាំងមូល ដែលត្រូវបានគូសនៅលើផែនទីឆ្នាំ១៩០៧ ក៏មានបញ្ហាដែរ។ បើទោះបីជាពាក្យថា "ទឹកដីកម្ពុជា" តម្រូវឲ្យមានការនិយាយយោងខ្លះទៅដល់សេចក្តីសំអាងរបស់តុលាការទាក់ទងនឹងព្រំដែនក៏ដោយ ក៏តុលាការពុំមានបំណងដោះស្រាយបញ្ហាខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃទាំងមូលនោះទេ ក្រៅពីតំបន់ជម្លោះមួយច្បាស់លាស់តែប៉ុណ្ណោះ។ ប្រការនេះ រួមជាមួយនឹងការបដិសេធពុំព្រមចេញសេចក្តីប្រកាសរបស់តុលាការ ស្តីពីស្ថានភាពរបស់ផែនទីឆ្នាំ១៩០៧ នៅក្នុងសេចក្តីសន្និដ្ឋានរបស់សាលក្រម បានធ្វើឲ្យមានអំណះអំណាងថា តុលាការទទួលស្គាល់ផែនទីទាំងមូលនៅក្នុងសេចក្តីសន្និដ្ឋានរបស់សាលក្រមមិនសូវរឹងមាំនោះទេ។

ចំណុចសំខាន់ពិតប្រាកដនៃជម្លោះ គឺថាតើដីទំហំ៤.៦គីឡូម៉ែត្រក្រឡា ដែលស្ថិតនៅភាគខាងលិចនៃប្រាសាទព្រះវិហារអាចត្រូវបានចាត់ទុកថាជាផ្នែកនៃ "តំបន់ក្បែរប្រាសាទដែលស្ថិតក្នុងទឹកដីកម្ពុជា" ដែរឬទេ។ ក្រុមអ្នកច្បាប់ថៃបានអះអាងថា លោក ឌិន អាឆេសុន ដែលជាមេធាវីកម្ពុជានៅក្នុងសំណុំរឿងដើមបានចាត់ទុកតំបន់ជម្លោះថាមានទំហំ "តូចណាស់"។ ទោះយ៉ាងណាក៏ដោយ ភាគីថៃបានជំទាស់ទៅនឹងការនិយាយយោងទៅដល់ពាក្យថា "តំបន់" ឬ "បរិវេណ" របស់ប្រាសាទថាវាមានទំហំធំទូលាយពេក។ គួរឲ្យសោកស្តាយ សាលក្រមឆ្នាំ១៩៦២ បានផ្តល់នូវការចង្អុលបង្ហាញតិចតួចប៉ុណ្ណោះ។ ការខ្វះខាតភាពច្បាស់លាស់នេះបានរួមចំណែកទៅដល់ភាពពុំស្ថិតស្ថេរ និងធ្វើឲ្យការបកស្រាយសាលក្រមឡើងវិញជារឿងដែលចាំបាច់ និងសមស្រប។

តុលាការអាចបញ្ជាក់ត្រឹមតែថា ប្រទេសថៃត្រូវដកកងទ័ពដែលឈរ "នៅប្រាសាទ"។ ការបន្ថែម ពាក្យថា "តំបន់ក្បែរ" ប្រាសាទនៅក្នុងសាលក្រមបញ្ជាក់ថាឲ្យសេចក្តីសម្រេចនេះមានចេតនាភ្ជាប់តំបន់ខ្លះ ដែលនៅហួសពីបរិវេណនៃតួប្រាសាទ។ ទោះបីជាតំបន់ក្បែរនោះ អាចត្រូវបានពង្រីកទៅខាងលិចប្រាសាទចំនួនពីរបីរយម៉ែត្រដូចនៅក្នុងផែនទីរបស់ភាគីថៃក៏ដោយ ក៏នៅតែមានសំណួរដដែលថាតើតំបន់នោះស្ថិតនៅក្នុងទឹកដីរបស់ថៃ ឬស្ថិតក្នុងទឹកដីរបស់កម្ពុជា? ការអានសាលក្រមនេះ ដោយភាគីថៃបង្ហាញថា ចម្លើយគឺអាស្រ័យទៅលើការព្រមព្រៀងរបស់ភាគី។ ប៉ុន្តែ ដោយសារពុំមានកិច្ចព្រមព្រៀងរវាងភាគីទាំងពីរ

បទបញ្ញត្តិនេះ គឺពុំមានប្រសិទ្ធភាពអនុវត្តទេនៅភាគខាងលិចនៃតំបន់ក្បែរប្រាសាទ ដែលជាកន្លែងតុលាការបានដឹងជាស្រេចហើយថាមានទាហានថៃមួយចំនួនបោះទីតាំងនៅទីនោះ ។

ទោះបីជាតុលាការបានបដិសេធពុំព្រមប្រកាសអំពីព្រំដែនដែលស្ថិតនៅក្នុងតំបន់ជម្លោះនៅក្នុងសេចក្ដីសន្និដ្ឋានរបស់សាលក្រមក៏ដោយ ក៏ចំណុចនេះអាចឲ្យគេយល់បានតាមរយៈការសម្រេចរបស់តុលាការដែលថា ភាគីបានទទួលស្គាល់ដែនទីឆ្នាំ១៩០៧ ។ តាមរយៈការឲ្យហេតុផលបែបនេះ តំបន់នៅក្នុង "តំបន់ក្បែរប្រាសាទនៅក្នុងខ្សែដែនទីឆ្នាំ១៩០៧ ខាងកម្ពុជាត្រូវស្ថិតនៅក្នុង "ទឹកដី"កម្ពុជា ។ មធ្យោបាយដែលសមរម្យបំផុតក្នុងការកំណត់តំបន់ក្បែរដែលពាក់ព័ន្ធនេះ គឺត្រូវកំណត់វិសាលភាពនៃសាលក្រមនេះមកនៅត្រឹមតែទឹកដីជាប់នោះដែលតូចបំផុត ដែលមានជម្លោះនៅជាប់នឹងប្រាសាទភាគខាងលិច និយាយឲ្យចំគឺផ្នែកតូចមួយដែលមានទំហំ៤.៦គីឡូម៉ែត្រក្រឡា ។ តាមរយៈការកំណត់វិសាលភាពបែបនេះ តុលាការគួរតែធ្វើសេចក្ដីសម្រេចគាំទ្រកម្ពុជា ។

ភាពសាំញ៉ាំនៃសំណួរគតិយុត្តិទាំងអស់នេះ ឆ្លុះបញ្ចាំងឲ្យឃើញអំពីភាពពុំច្បាស់លាស់នៃសាលក្រម ដែលគួរឲ្យសោកស្ដាយបានបន្សល់ទុកនូវចន្លោះប្រហោងបន្តឲ្យមានការវែងគំនិតគ្នានិងជម្លោះចំពោះការបកស្រាយ ។ ទោះបីភាគីណាមួយទទួលបានជោគជ័យនៅក្នុងតុលាការក៏ដោយ រដ្ឋាភិបាលទាំងពីរនឹងគោរពយ៉ាងខ្ជាប់ខ្ជួននូវសាលក្រមនេះ ។ សម្រាប់ខាងកម្ពុជា សេចក្ដីសម្រេចជាអន្តរជាតិនេះ បានផ្ដល់នូវវេទិកាយុត្តិធម៌បំផុតនៅក្នុងការដោះស្រាយវិវាទជាមួយនឹងប្រទេសជិតខាងដែលធំ និងមានឥទ្ធិពលជាងខ្លួន ។ សម្រាប់រដ្ឋាភិបាលរបស់លោកស្រី យីងឡាក់ ស៊ីណាវ៉ាត់ត្រា ការតតាំងផ្នែកច្បាប់យ៉ាងខ្លាំងក្លា អាចនឹងផ្ដល់ការការពារទល់នឹងការទាមទារជាតិនិយមក្នុងស្រុកឲ្យមានការចាត់វិធានការ បើទោះបីជាសេចក្ដីសម្រេចរបស់តុលាការពុំអាចទទួលយកបានក៏ដោយ ។ ភាគីទាំងពីរ បានបញ្ចេញសមត្ថភាព និងធ្វើការតតាំងយ៉ាងខ្នះខ្នែងនៅក្នុងតុលាការ ។ សេចក្ដីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិស្ដីពីបញ្ហានេះ នឹងផ្ដល់ដល់ភាគីទាំងពីរនូវខ្សែបែងចែកដ៏មានសារប្រយោជន៍មួយ ពោលគឺ ឱកាសដើម្បីងាកចេញពីនយោបាយចម្រូងចម្រាសនៃអតីតកាលថ្មីៗនេះ ដែលបានជួយប្រមូលផ្ដុំក្រុមជាតិនិយមឲ្យជ្រកក្រោមស្លាកទង់ជាតិប្រទេស ប៉ុន្តែប្រការនេះមានជាប់ទាក់ទងតិចតួចណាស់ទៅនឹងផលប្រយោជន៍យូរអង្វែងរបស់ប្រជាពលរដ្ឋរបស់ប្រទេសទាំងពីរ ។

**ចន ឆរឆីអារី**

# ដំណឹងស្វែងរកបងប្រុស



នាងខ្ញុំឈ្មោះ ប៊ុនឡា ម៉ៃ សព្វថ្ងៃរស់នៅសហរដ្ឋអាមេរិក ។ សូមប្រកាសស្វែងរកបងប្រុសឈ្មោះ ប៊ុនឡា ទោត ដែលបានបែកគ្នានៅចុងឆ្នាំ១៩៧៥ កាលពីអាយុ១៦ឆ្នាំ ក្នុងភូមិអៀន ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ក្បែរព្រំប្រទល់ខេត្តបន្ទាយមានជ័យ ។

ឪពុកឈ្មោះ ប៊ុនឡា ប៊ុតស៊ី (ស្លាប់) និងម្ដាយឈ្មោះ ប៊ុនឡា គឿ (ស្លាប់) ។ គាត់ទាំងពីរនាក់ មានកូនទីមួយឈ្មោះ ប៊ុនឡា ទោត (បាត់ខ្លួន), កូនទីពីឈ្មោះ ប៊ុនឡា អាត (នៅរស់), កូនទីបីឈ្មោះ ប៊ុនឡា លេត (នៅរស់), កូនទីបួនឈ្មោះ ប៊ុនឡា ឡៃ (នៅរស់), កូនទីប្រាំ ឈ្មោះ ប៊ុនឡា ម៉ៃ (នៅរស់) ។

បើបងប្អូនណាបានស្គាល់ឈ្មោះ ប៊ុនឡា ទោត សូមទំនាក់ទំនងមកនាងខ្ញុំ ប៊ុនឡា ម៉ៃ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា អាសយដ្ឋាន ៖ ផ្ទះលេខ៦៦, ផ្លូវព្រះសីហនុ, ភ្នំពេញ, ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ **សូមអរគុណ!**

# មហិច្ឆតាប្រព្រឹត្តអំពើហិង្សាក្នុងប្រទេសបង់ក្លាដេស

ជីវិតមនុស្សជាច្រើនត្រូវបានបាត់បង់ និងត្រូវបានសម្លាប់ អំឡុងពេលការតស៊ូដោយអំពើហិង្សារបស់ប្រទេសបង់ក្លាដេស ក្នុងការស្វែងរកឯករាជ្យពីប្រទេសប៉ាគីស្ថានក្នុងឆ្នាំ១៩៧១ ។ ជាងបួនទសវត្សរ៍ ក្រោយមក ជនជាតិបង់ក្លាដេស បានគំរាមកំហែងនឹងប្រព្រឹត្តអំពើហិង្សានៅតាមផ្លូវ ដោយទាមទារនូវអាយុជីវិតអ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏សាហាវ ក្នុងអំឡុងពេលនៃការតស៊ូទាមទារឯករាជ្យ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ *(The International Crimes Tribunal)* ក្នុងទីក្រុងដាកា ដែលត្រូវបានបង្កើតឡើងនៅខែមីនា ឆ្នាំ២០១០ ដើម្បីជំនុំជម្រះអ្នកដែលទទួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងនេះ ត្រូវរងការថ្កោលទោសយ៉ាងខ្លាំងពីអ្នកសង្កេតការណ៍អន្តរជាតិ ។ តុលាការនោះបានចេញសាលក្រមចំនួនពីរដំបូង នៅប៉ុន្មានសប្តាហ៍ចុងក្រោយនេះ ។ ដូចដែលបានទស្សន៍ទាយ សាលក្រមទាំងនេះគឺជាការផ្តន្ទាទោស ។ អាប់ខុលកាលាមអាហ្សាត ត្រូវកាត់ទោសប្រហារជីវិតដោយកំបាំងមុខ ហើយ អាប់ខុល ការដេរមូលា ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។ ដូច្នេះហើយ ការប្រព្រឹត្តអំពើហិង្សានៅតាមដងផ្លូវហាក់បីដូចជាយុត្តិធម៌ មានន័យថា ឈាមសងឈាម ។ រដ្ឋាភិបាលសម្ព័ន្ធអាវ៉ាមី ដែលកាន់អំណាច និងបានសន្យាធ្វើការជំនុំជម្រះក្តីដែលបានហួសកាលកំណត់ដល់ជនដៃដល់ (ដែលបានប្រែក្លាយទៅជាសត្រូវនយោបាយនៅក្នុងគណបក្សជាតិនិយមបង់ក្លាដេស និងចាម៉ាអ៊ីស្លាមមី) បានដាក់កាតព្វកិច្ចពន្លឿនការប្រហារជីវិតតាមផ្លូវច្បាប់ ។

បញ្ហានៃដំណើរការរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ មិនគួរកើតឡើងដោយគួរឲ្យភ្ញាក់ផ្អើលនោះឡើយ ។ សូម្បីតែមុនពេលដែលដំណើរការបានចាប់ផ្តើមជាមួយនឹងការព្រួយបារម្ភអំពីលក្ខណៈគ្រប់ជ្រុងជ្រោយនៃច្បាប់ឆ្នាំ១៩៧៣ ដែលជនជាប់ចោទកំពុងធ្វើការជំនុំជម្រះ ដែលជាការកំណត់របស់រដ្ឋធម្មនុញ្ញលើសិទ្ធិរបស់ជនជាប់ចោទ និងលទ្ធភាពនៃប្រព័ន្ធច្បាប់ក្នុងការគ្រប់គ្រងដំណើរការបន្តរឿងនយោបាយ ដោយមានលក្ខណៈទាមទារ និងមានលក្ខណៈស្មុគស្មាញ ។ ភាពតានតឹងតែងតែកើតឡើងដំណាលនឹងការជំនុំជម្រះក្តី ប៉ុន្តែការបន្តរឿងនយោបាយក្នុងប្រទេសបង់ក្លាដេស មានលក្ខណៈមិនសាមញ្ញនោះឡើយ ដោយលើកឡើងពីមហិច្ឆតា និងការបិទបាំងហេតុផល បើពុំដូច្នោះទេ រឿងរ៉ាវទាំងអស់នឹងត្រូវបានលាតត្រដាងយ៉ាងជាក់ស្តែង ។ អ្នកដែលរិះគន់សវនាការ ដូចអ្នកដែលមានទស្សនៈផ្សេងគ្នាលើអ្វីបានកើតឡើងក្នុងឆ្នាំ១៩៧១ ត្រូវបានថ្កោលទោសដោយរងការបរិហារយ៉ាងខ្លាំង ដែលកម្រឃើញក្នុងសវនាការស្រដៀងគ្នានេះនៅក្នុងសង្គមប្រជាធិបតេយ្យ ។ សូម្បីតែមេធាវីជនជាតិអង់គ្លេស១រូប ដែលផ្តល់ការប្រឹក្សាយោបល់ដល់ជនជាប់ចោទ ត្រូវបានហាមឃាត់មិនឲ្យចូលក្នុងប្រទេសនោះឡើយ បន្ទាប់ពីការរិះគន់ ។

ពាក្យបណ្តឹងជាច្រើនអំពីដំណើរការនីតិវិធីក្នុងប្រទេសបង់ក្លាដេស បានធ្វើឲ្យចុះខ្សោយដល់ដំណើរការនីតិវិធីស្រដៀងគ្នានេះក្នុងប្រទេសកម្ពុជា ទីម័រខាងកើត អ៊ីរ៉ាក់ និងកន្លែងដទៃ ។ ផ្ទុយទៅនឹងការស្វែងរកយុត្តិធម៌ តុលាការឧក្រិដ្ឋកម្មអន្តរជាតិទំនងជានឹងត្រូវបានចងចាំក្នុងប្រវត្តិសាស្ត្រចំពោះភាពមិនប្រក្រតីមួយចំនួនក្នុងចំណោមភាពមិនប្រក្រតីដ៏អាក្រក់បំផុតក្នុងដំណើរការនីតិវិធីលើឧក្រិដ្ឋកម្មអន្តរជាតិក្នុងសម័យទំនើប ។ ក្រុមអ្នកឃ្លាំមើលសិទ្ធិមនុស្សកំពុងតែទាមទារឲ្យមានការជំនុំជម្រះក្តីឡើងវិញ ដោយសារតែការផ្លាស់ប្តូរចៅក្រមក្នុងការជំនុំជម្រះ ខែលវា ហ៊ូសេន សាយ៉ាឌី ដែលមិនបានឲ្យចៅក្រមម្នាក់ក្នុងក្រុមប្រឹក្សាជំនុំជម្រះបានស្តាប់ភស្តុតាងទាំងអស់ ។ ពាក្យបណ្តឹងរបស់ក្រុមការពារក្តីមានច្រើន និងហួសពីអ្វីដែលយើងពុំជាធម្មតា ។ អ៊ីម៉ែលដែលត្រូវបានជ្រៀតចាញទិន្នន័យ *(Hacked Mail)* និងប្រតិចារឹកក្នុងស្កាយ *(Skype transcripts)* បានលាតត្រដាងពីការដាក់សម្ពាធផ្លូវនយោបាយលើតុលាការ និងចៅក្រម ដែលបន្តធ្វើការជំនុំជម្រះបានពាក់កណ្តាលលើពិរុទ្ធភាពនោះ ។ អ្នកសង្កេតការណ៍សវនាការរយៈពេលយូរម្នាក់បានចងក្រង

ឯកសារស្តីពីការប្រព្រឹត្តមិនស្មើគ្នារបស់ភាគីការសម្ងុត គំរាមកំហែង និងភាពអាម៉ាស់របស់ក្រុមមេធាវីការពារក្តី និងការរៀបចំពេលវេលាមិនគ្រប់គ្រាន់សម្រាប់ជនជាប់ចោទដែលជាផ្នែកតូចក្នុងបញ្ហាធំ ។

ប្រទេសបង់ក្លាដេស បានផ្តល់ឲ្យយើងនូវឧទាហរណ៍ដ៏សំខាន់ទាក់ទងទៅនឹងចៅក្រមជំនុំជម្រះដែលត្រូវបានចាប់កំហុសស្តីពីការពិភាក្សាយ៉ាងជាក់ស្តែងលើសេចក្តីលំអិតរបស់សំណុំរឿង និងការរៀបចំចេញសេចក្តីសម្រេចជាមួយនឹងភាគីទីបី ។ ប្រទេសបង់ក្លាដេសបានផ្តល់ឧទាហរណ៍នៃសំណុំរឿងដែលសាក្សីរបស់ព្រះរាជអាជ្ញា និងមេធាវីការពារក្តី សុគូ រាជុន បាលី ត្រូវបានប៉ូលិសចាប់ពង្រត់មុនសាក្សីផ្តល់សក្ខីកម្ម ហើយសាក្សីនេះនៅកំពុងបាត់ខ្លួននៅឡើយ ។ ប្រទេសបង់ក្លាដេសបានផ្តល់នូវឧទាហរណ៍ទាក់ទងទៅនឹងចៅក្រមមួយចំនួន ដែលជាអ្នកតស៊ូ ឬជាសកម្មជនដើម្បីសេរីភាព ក្នុងចលនាទទួលខុសត្រូវ និងបានចោទប្រកាន់ជនចាប់ចោទក្នុងតុលាការប្រជាជនដែលអះអាងថាមានឯករាជ្យ និងមិនលម្អៀងក្នុងការកាត់ក្តីលើជនជាប់ចោទដូចគ្នានៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ។ អ្នកគាំទ្រសវនាការបានចោទប្រកាន់ថា រឿងទាំងអស់នេះ គឺជាការកុហកដែលជាការឃោសនាកើតចេញពីអ្នកដែលគាំទ្រឧក្រិដ្ឋកម្មសង្គ្រាម ។

មហិច្ឆតាប្រព្រឹត្តអំពើហិង្សាក្នុងប្រទេសបង់ក្លាដេស គឺជាបញ្ហាអន្តរជាតិ ហើយពេលវេលាសម្រាប់ការឆ្លើយតបតាមផ្លូវការទូតដែលគ្មានប្រសិទ្ធភាពបានបញ្ចប់ហើយ ។ កាលពីឆ្នាំមុន ក្រុម *the Working Group on Arbitrary Detention* បានរកឃើញថា ប្រទេសបង់ក្លាដេស បានឃុំឃាំងជនជាប់ចោទទាំងនោះស្រេចតែអំពើចិត្តរបស់ខ្លួននៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងអ្នកឃ្លាំមើល ពិសេសរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកឃ្លាំមើលការប្រហារជីវិតក្រៅប្រព័ន្ធតុលាការ ការប្រហារជីវិតភ្លាមៗ ដោយមិនឆ្លងកាត់ដំណើរការនីតិវិធី ឬការប្រហារជីវិតស្រេចតែអំពើចិត្ត ។ អ្នកឃ្លាំមើលពិសេសរបស់អង្គការសហប្រជាជាតិ ដែលទទួលបន្ទុកឃ្លាំមើលឯករាជ្យភាពរបស់ចៅក្រម និងក្រុមមេធាវី បានបញ្ចេញទស្សនៈរួមប្រឆាំងទៅនឹងសេចក្តីសម្រេចទាំង២ដំបូង ។ ប៉ុន្តែការឆ្លើយតបទាំងនេះ មិនមានប្រសិទ្ធភាពឡើយ ហើយឧត្តមស្នងការរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងអគ្គលេខាធិការរបស់អង្គការសហប្រជាជាតិមានភាពស្ពឹកស្រពន់លើបញ្ហានេះដោយគួរឲ្យកត់សម្គាល់ ។ យើងបានទុកពេលវេលាចោល នៅពេលដែលការចំអកនេះស្ថិតក្នុងវង្វង់អធិបតេយ្យភាពរបស់រដ្ឋ ហើយសហគមន៍អន្តរជាតិចាំបាច់ត្រូវតែធ្វើប្រតិកម្មតប មុនពេលដែលឧក្រិដ្ឋកម្មដែលជាក់ទណ្ឌកម្មដោយតុលាការបានធ្វើឡើង ហើយមុនពេលដែលការតវ៉ាប្រឆាំងនឹងដំណើរការ បានក្លាយជាអំពើហិង្សាកាន់តែ ខ្លាំងជាងមុន ។

សហគមន៍អន្តរជាតិ មិនទាន់បាននិយាយនៅឡើយអំពីអ្វីដែលចាំបាច់ត្រូវនិយាយ ដូចជា ដំណើរ ការនេះត្រូវបានផ្តល់ឱកាសមួយ ប៉ុន្តែឱកាសនោះខ្វះនូវបទដ្ឋានអន្តរជាតិជាមូលដ្ឋាន ហើយយើងជិតទាស់ទៅនឹងការបន្តធ្វើតាមរបៀបនេះ ។ យើងមិនអាចពោលអះអាងចំពោះការព្រួយបារម្ភអំពីយុត្តិធម៌ សិទ្ធិមនុស្ស ការជំនុំជម្រះដោយយុត្តិធម៌ និងដំណើរការនីតិវិធីនោះឡើយ ដោយសារយើងនៅតែស្ពឹកស្រពន់លើបញ្ហាទាំងនោះ ។ ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ចាំបាច់ត្រូវតែចូលរួម ហើយអាចចាប់ផ្តើមបានតាមរយៈការតែងតាំងគណៈកម្មាធិការសួរចម្លើយអន្តរជាតិក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងជាងនេះទៅទៀត ក្នុងបញ្ហាទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មឆ្នាំ១៩៧១ ។ យុត្តិធម៌ត្រូវតែស្វែងរក ប៉ុន្តែនេះមិនមែនជាយុត្តិធម៌នោះឡើយ ។ **ស្សូហ្សាណា លីនគុន**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthsocheat@dccam.org*

*Home page: www.dccam.org*

# តើទ្រព្យសម្បត្តិរបស់អតីតមេដឹកនាំខ្មែរក្រហមគឺជាសំណងដល់ការព្យាបាលរបួសផ្លូវចិត្តរបស់ជនរងគ្រោះ ឬមួយយ៉ាងណា?

បន្ទាប់ពីការស្លាប់របស់ អៀង សារី មានសំណួរជាច្រើនដែលបានលើកឡើងទាក់ទងទៅនឹងលទ្ធភាពផ្តល់សំណងជាសាច់ប្រាក់របស់អតីតមេដឹកនាំខ្មែរក្រហម ។ តើទ្រព្យសម្បត្តិបន្តិចបន្តួចអាចនឹងជាសំណងរបស់ឧក្រិដ្ឋជនប្រឆាំងទៅនឹងតម្លៃរបស់មនុស្ស ការប៉ះដល់ផ្លូវចិត្តធ្ងន់ធ្ងរ ដែលឧក្រិដ្ឋជនធ្លាប់បានប្រព្រឹត្តមែនដែរឬទេ? លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រាប់ថា «អៀង សារី មានទ្រព្យសម្បត្តិមួយចំនួនធំដែលអាចលុបបំបាត់ការឈឺចាប់របស់ជនរងគ្រោះនៅក្នុងរបបប្រល័យពូជសាសន៍បាន ។ មានន័យថា គាត់មានទ្រព្យសម្បត្តិគ្រប់គ្រាន់ដែលអាចកសាងជាមជ្ឈមណ្ឌលជាតិសុខភាពផ្លូវចិត្តសម្រាប់ជនរងគ្រោះទាំងអស់បាន» ។

យ៉ាងហោចណាស់ វាគឺជាគំនិតដែលគួរឲ្យចាប់អារម្មណ៍ហើយនឹងមានលក្ខណៈយុត្តិធម៌ ដែលថាទ្រព្យសម្បត្តិរបស់ឧក្រិដ្ឋជនអាចប្រើប្រាស់សម្រាប់ជាកន្លែងព្យាបាលដល់ជនរងគ្រោះ ។

ថ្មីៗនេះ យោងតាមសាកលវិទ្យាល័យច្បាប់ហ្វតហាម បានពិនិត្យលើប្រព័ន្ធព្យាបាលសុខភាពផ្លូវចិត្តរបស់រាជរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា មានចំនួន ៣០.០០០ដុល្លារសហរដ្ឋអាមេរិកដែលត្រូវបានវិនិយោគទៅលើផ្នែកនេះ បើប្រៀបធៀបសរុបទៅនឹងថវិកាសម្រាប់ការថែរក្សាសុខភាពទូទៅមានចំនួន១៥០លានដុល្លារសហរដ្ឋអាមេរិក ។ នេះគឺត្រឹមតែ២ភាគរយនៃថវិកាសរុបលើផ្នែកសុខភាព ។ ទន្ទឹមនឹងនេះ នៅក្នុងប្រទេសកម្ពុជា ជំងឺផ្លូវចិត្តដែលទាមទារឲ្យមានការព្យាបាលគឺស្ថិតនៅក្នុងកម្រិតខ្ពស់ ហើយដែលគេចាត់ទុកប្រទេសដែលមានភាពរញ៉េរញ៉ៃ មានរឿងឃោរឃៅកើតឡើងជាញឹកញាប់ និងមានអំពើព្រៃផ្សៃផ្សេងទៀតដែល



អៀង សារី (ស្តាំ) កំពុងពិភាក្សាជាមួយគណៈប្រតិភូចិន ។ នៅខាងឆ្វេងគឺ ស៊ុន ហ្វូ អគ្គរដ្ឋទូតចិនប្រចាំនៅរបបកម្ពុជាប្រជាធិបតេយ្យ ។ រូបកណ្តាលគឺ ប៉ុល ពត

បន្សល់ទុកនូវជំងឺផ្លូវចិត្តច្រើនជាងគេនៅលើពិភពលោក ។ កម្មវិធីជាតិសុខភាពផ្លូវចិត្តមានភារកិច្ចត្រូវតែព្យាបាលរាល់បញ្ហាផ្លូវចិត្តទាំងអស់មិនមែនតែជំងឺដែលកើតឡើងដោយសារភាពតក់ស្លុតតែមួយនោះទេ ។ អង្គការក្រៅរដ្ឋាភិបាលខាងសុខភាពផ្លូវចិត្តប្រកួតប្រជែងផ្តល់ជាជំនួយមួយមានកំណត់ក្នុងនាមជាអ្នកផ្តល់ជំនួយអន្តរជាតិ ។

នៅខណៈពេលនោះ យើងដឹងថា អៀង សារី មានទ្រព្យសម្បត្តិសរុបនៅក្នុងគណនីមួយចំនួន២០លានដុល្លារអាមេរិក ។ គាត់ពិតជាមានទ្រព្យសម្បត្តិអស្ចារ្យ បើគ្រាន់តែនៅក្នុងគណនីមួយរបស់គាត់មានថវិកាច្រើនជាង៦០០ដង បើប្រៀបធៀបទៅនឹងថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រសុខភាពផ្លូវចិត្ត ។ វាមិនមានភាពលំបាកនោះទេនៅក្នុងការតាមដានចំពោះទ្រព្យសម្បត្តិរបស់គាត់ ។ សង្កត់ធ្ងន់ទៅលើបញ្ហានេះ សូម្បីតែឡានម៉ាកឡង់គ្រីស័ររបស់គាត់ក៏មានតម្លៃស្មើនឹងថវិកាប្រចាំឆ្នាំដែលគាំទ្រទៅលើសុខភាពផ្លូវចិត្តសម្រាប់ព្រះរាជាណាចក្រកម្ពុជា ។

ផលប៉ះពាល់ដ៏ជូរចត់ចំពោះរឿងតក់ស្លុតដែលទាក់ទងទៅនឹងសុខភាពផ្លូវចិត្ត គឺរោគសញ្ញាមួយដែលនៅតែបន្តជិតជាប់ចំពោះជនរងគ្រោះដែលនៅមានជីវិតបន្ទាប់ពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ហើយនឹងមានឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើក្មេងៗជំនាន់ក្រោយ ។ ចំពោះបញ្ហានេះ ការចាប់អារម្មណ៍បានកើនឡើងក្នុងការធ្វើឲ្យប្រសើរឡើងនូវជំនួយឧបត្ថម្ភ ការអប់រំ សេវាសុខាភិបាល សម្រាប់ជំងឺតក់ស្លុតពាក់ព័ន្ធនឹងបញ្ហាផ្លូវចិត្តនៅកម្ពុជា ប៉ុន្តែរហូតមកដល់ពេលបច្ចុប្បន្ននេះមានថវិកាតិចតួចប៉ុណ្ណោះសម្រាប់ឧបត្ថម្ភលើផ្នែកនេះ ។ ភាគីជនរងគ្រោះនីមួយៗនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានធ្វើការសាកសួរពីសេវាកម្មព្យាបាលសុខភាពផ្លូវចិត្តដែលជាសំណងដល់ការទទួលរងការឈឺចាប់របស់គាត់ (នេះជាការស្នើសុំមួយដែលមិនធ្លាប់មានពីមុនមកសម្រាប់តុលាការអន្តរជាតិមួយនេះ) ។

ត្រង់ចំណុចនេះ រាជរដ្ឋាភិបាលកម្ពុជា និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានពិចារណា ពិភាក្សាគ្នាលើបញ្ហាការព្យាបាលសុខភាពផ្លូវចិត្តទុកជាសំណងសម្រាប់ជំនួសឲ្យឧក្រិដ្ឋកម្មសង្គ្រាម ។

ប៉ុន្តែនៅតែមានសំណួរបន្តទៀតថា ៖ «តើអ្នកណាដែលគួរតែចំណាយទៅលើបញ្ហានោះ?»

នៅពេលនោះយើងប្រាប់ចម្លើយថា ប្រហែលជានៅក្នុងដំណាក់កាលដែលកំពុងតែស្រាវជ្រាវរកទ្រព្យសម្បត្តិរបស់ជនជាប់ចោទដែលធ្លាប់ជាអភិជន ។

**ដូរៀន រិកធីត និង ជីរ៉ល គ្រេ**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm ។ ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធីសំឡេងអំពើប្រល័យពូជសាសន៍ ៖ យុត្តិធម៌ និងការអត់ឃ្មាន ដែលចាប់ផ្តើមផ្សាយពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៣ រៀងរាល់ថ្ងៃអាទិត្យ ។

ប្រិយមិត្តដែលរស់នៅរាជធានីភ្នំពេញ និងនៅខេត្តអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំតាមរយៈ ៖

◆ វិទ្យុជាតិកម្ពុជា AM 918KHz រាជធានីភ្នំពេញ វេលាម៉ោង៩ព្រឹក និងម៉ោង៧និង៣០នាទីល្ងាច ។

◆ វិទ្យុខេត្តកំពត FM 93.25 MHz វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។

◆ វិទ្យុខេត្តព្រះវិហារ FM 99 MHz វេលាម៉ោង៧:៣០ព្រឹក និងម៉ោង៨រសៀល ។

◆ វិទ្យុខេត្តបាត់ដំបង FM 103.25 MHz វេលាម៉ោង៨ព្រឹក និងម៉ោង៨រសៀល ។

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ វិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិ ដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្ដី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្ដល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ស៊ិរិ សាវីណា តាមរយៈទូរស័ព្ទលេខ: ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល: truthsavina.s@dccam.org

**◆ទីកន្លែង : អាគារ "ក" ជាន់លើ ◆ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# បងប្រុសខ្ញុំ ហៃ សំអុល

មីង គ្រួច គឹមសាន ក្នុងវ័យ៦១ឆ្នាំ បានមកកាន់មជ្ឈមណ្ឌលឯកសារ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣ ដោយកាន់កាសែតរស្មីកម្ពុជា (ឆ្នាំទី២១ លេខ៦១០៥ ថ្ងៃអាទិត្យ-ចន្ទ ទី០៥-០៦ ខែឧសភា ឆ្នាំ២០១៣, ទំព័រ ខ«៨») មកជាមួយផង ក្នុងក្តីសង្ឃឹមមួយក្នុងចិត្ត បន្ទាប់ពីបានទៅដល់ទួលស្លែង និងកន្លែងផ្សេងៗទៀត ដើម្បីសួរនាំព័ត៌មានដែលទាក់ទិននឹងបងប្រុសបង្កើត ម្នាក់ ។

មីង គឹមសាន មានសម្បុរខ្មៅជ្រះ មាឌធំ នៅក្នុងទឹកមុខដែលមានលក្ខណៈភ័យ-អរៗ បានជួប និងសួរនាំបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាអំពីឈ្មោះ ហៃ សំអុល តាមរយៈអត្ថបទកាសែតរស្មីកម្ពុជាដែលចុះផ្សាយអំពី «សេចក្តីកត់ហេតុ និងចម្លើយ» របស់ ហៃ សំអុល ដែលធ្វើឡើងដោយមន្ទីរសន្តិសុខស្រុកកងមាស តំបន់៤១ ភូមិភាគឧត្តរនៃកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម នៅថ្ងៃទី១៦ ខែ១២ ឆ្នាំ១៩៧៦ ។ ខ្ញុំបានទៅទទួល និងជួបមីងផ្ទាល់ នៅកន្លែងទទួលភ្ញៀវរបស់មជ្ឈមណ្ឌលដើម្បីសួរនាំបន្ថែម និងផ្តល់ឱកាសឲ្យមីង គឹមសាន បានសួរនាំខ្ញុំវិញអំពីជោគវាសនារបស់ ហៃ សំអុល ដែលត្រូវជាបងប្រុសបង្កើតរបស់មីង ។

«ខ្ញុំសប្បាយចិត្តណាស់!» មីង គឹមសាន និយាយមកកាន់ខ្ញុំ ។ ខ្ញុំដឹងភ្លាមថា មីង គឹមសាន ប្រាកដជាចង់ដឹងថា ហៃ សំអុល នៅរស់រានមានជីវិត ឬ ស្លាប់ បន្ទាប់ពីបាត់ដំណឹងអស់រយៈពេល ៣៨ឆ្នាំមក ។ ខ្ញុំមានការស្ទាក់ស្ទើរក្នុងការឆ្លើយតបទៅនឹងក្តីរំពឹងរបស់មីង គឹមសាន ដោយហេតុថា មីង គឹមសាន នឹងមានអារម្មណ៍ក្តុកក្តួលខ្លាំងនៅពេលដែលដឹងថា បងប្រុសរបស់មីងត្រូវបានខ្មែរក្រហមចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខស្រុកកងមាស ដែលមានឈ្មោះ យុន ជាគណៈមន្ទីរសន្តិសុខ ។ បន្ទាប់ពីនិយាយស្ទាបស្ទង់ពីអារម្មណ៍របស់មីង គឹមសាន មួយសន្ទុះរួចមកខ្ញុំយល់ថា ខ្ញុំអាចចាប់ផ្តើមរៀបរាប់ពីដំណើរដើមទងដែលឈានដល់ការសរសេរអត្ថបទចុះក្នុងកាសែតរស្មីកម្ពុជា អំពី ហៃ សំអុល និងការអញ្ជើញមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជារបស់មីង គឹមសាន តាមរយៈអត្ថបទនេះ ។ មីង គឹមសាន ប្រែទឹកមុខបន្តិច ប៉ុន្តែមីងរឹតតែចង់ដឹងលម្អិតបន្ថែមទៀតទាក់ទងនឹងជោគវាសនារបស់បងប្រុស ហៃ សំអុល ។

ខ្ញុំបានលួងលោមចិត្តមីង ដោយពន្យល់មីងថា ទាំងមីង ទាំងខ្ញុំ និងអ្នកដទៃទៀត ពុំបានដឹងដំណឹងអំពីជោគវាសនារបស់ ហៃ សំអុល ទេ ។ ជាការពិត ហៃ សំអុល ត្រូវបានខ្មែរក្រហមចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខស្រុកកងមាស ដោយចោទប្រកាន់ថា បានទាក់ទងជាមួយព្រះអង្គម្ចាស់ នរោត្តម នរតិបោ៊ (នៅក្នុងឯកសារខ្មែរក្រហមសរសេរថា «ដាវ៉ាដេប៉ូ») ក្នុងការប្រឆាំងនឹងរបបខ្មែរក្រហម បន្ទាប់ពីរបបនេះឡើងកាន់អំណាចនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ។ លទ្ធផលស្វែងរក តាមរយៈឯកសារផ្សេងៗបង្ហាញថា ហៃ សំអុល មិនត្រូវបានបញ្ជូនមកទួលស្លែងទេ ដោយហេតុថា ចម្លើយសារភាពនៅទួលស្លែង, រូបថត និងបញ្ជីសម្លាប់ពុំត្រូវបានរកឃើញនៅឡើយ ។

«ខ្ញុំអរគុណណាស់ក្មួយ!» មីង គឹមសាន និយាយមកកាន់ខ្ញុំ និងសហការីរបស់ខ្ញុំ ។ មីង គឹមសាន មានបងប្អូនទាំងអស់១៣ នាក់ ក៏ប៉ុន្តែនៅក្នុងចម្លើយរបស់ ហៃ សំអុល បង្ហាញតែបងប្អូន៧នាក់ប៉ុណ្ណោះ ហើយមីងគឺជាប្អូនស្រីពៅ ។ មីងរៀបរាប់ថា បងប្អូនរបស់មីងបានស្លាប់អស់ហើយ ។ «ម៉ាបងប្អូនទាំងអស់នៅសល់តែខ្ញុំមួយទេ» មីងនិយាយទាំងអួលដើមកប្រាប់មកខ្ញុំ ។ មីងរៀបរាប់យ៉ាងច្រើនពីនេះពីនោះមិនតាមលំដាប់លំដោយទេ ពីឈ្មោះ ហៃ សំអុល ទាំងក្តីអាណិតអាសូរ និងទឹករពុកបំផុត ។ តាមការរៀបរាប់នោះ ខ្ញុំបានដឹងថា ហៃ សំអុល ត្រូវបានព្រះអង្គម្ចាស់ នរោត្តម នរតិបោ៊ ស្រឡាញ់រាប់អានយ៉ាងជិតស្និតតាំងពីសង្គមមកម្ល៉េះ ។ កូនប្រុសរបស់ ហៃ សំអុល ម្នាក់ឈ្មោះ រដ្ឋ ត្រូវបានព្រះអង្គម្ចាស់បញ្ជូនឲ្យទៅរៀននៅប្រទេសចិនតាំងតែពីនៅតូចៗ ។ រហូតមកទល់ពេលនេះ មិន ដឹងថាក្មេង រដ្ឋ នៅរស់ ឬយ៉ាងណានោះឡើយ ។ មីង សាន ដែលជាឈ្មោះត្រូវបានបង្ហាញនៅក្នុងកំណត់ចម្លើយ

របស់ ហៃ សំអុល បានបែកពីបងរបស់មីងចាប់តាំងពីពេលដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ដែលនៅពេលនោះ មីង សាន ត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅខេត្តបាត់ដំបង ហើយ សំអុល រួមជាមួយឪពុកម្ដាយ និងបងៗដទៃទៀតត្រូវបានជម្លៀសទៅកន្លែងផ្សេង ។

អ្វីដែលមីង សាន សង្ស័យមិនអស់ចិត្តនោះនៅត្រង់ថា មានមនុស្សប្រុសម្នាក់បានពាំនាំបណ្ដាំ របស់ ហៃ សំអុល ដែលហៃ សំអុល ប្រាប់ថា ប្រសិនបើស្រុកបែក សូមទៅរកឈ្មោះ សឿន ធ្វើការនៅរទេះភ្លើង ហើយប្រាប់ថា ខ្ញុំ (សំអុល) នៅរស់នៅឡើយទេ ។ មីង សាន បានដឹងដំណឹងនេះ ពីឈ្មោះ សឿន ដែលត្រូវជាបងថ្លៃប្រុសរបស់មីង នៅពេលក្រោយមកទៀត បន្ទាប់ពីរបបខ្មែរក្រហមដួលរំលំថ្មីៗក្នុងឆ្នាំ១៩៧៩ ។ នៅក្នុងកំណត់ចម្លើយរបស់ សំអុល ឈ្មោះ សឿន គឺជាប្ដីរបស់ លី ដែលត្រូវជាបងស្រីរបស់ មីង សាន ។ មនុស្សម្នាក់នោះធ្លាប់រស់នៅជាមួយ សំអុល នៅស្រុកកងមាស ហើយថែមទាំងប្រាប់ឈ្មោះ សឿន ទៀតថា ខ្លួនបានឃើញខ្មែរក្រហមយករទេះសេះមួយដឹកមនុស្សប្រាំនាក់ ដែលក្នុងចំណោមនោះមាន សំអុល ដែរយកចេញពីផ្ទះមួយខ្នងប្រក់ក្បឿង ដោយមិនដឹងថា ដឹកយកទៅទីណាទេ ។ នាពេលនោះ មីងពុំបានចាប់អារម្មណ៍ថា ត្រូវទៅរកបងប្រុសយ៉ាងណាឡើយ ដោយហេតុថា ក្រោយរំដោះឆ្នាំ១៩៧៩ មនុស្សម្នាក់ៗគិតតែពីធ្វើយ៉ាងណាឲ្យខ្លួនរស់រានមានជីវិតតទៅទៀតសិន ។ ម្យ៉ាងទៀតមីង មិនដឹងថា ស្រុកកងមាសស្ថិតនៅទីណានោះទេ ។ មីងនិយាយទាំងក្ដីសោកស្ដាយជាខ្លាំងថា «និយាយឲ្យខ្លី ម្នាក់ៗគិតតែពីធ្វើយ៉ាងម៉េចឲ្យរស់ ហើយមិនបានគិតអ្វីផ្សេងទៀតនោះទេ ក្រោយបែកឆ្នាំ១៩៧៩» ។ ហេតុផលខាងលើនេះហើយ ដែលមីង សាន ពុំបានទៅស្រាវជ្រាវរកបងប្រុសរបស់ខ្លួននៅស្រុកកងមាស ខេត្តកំពង់ចាម ។

ចុងក្រោយ ក្ដីសង្ឃឹមរបស់មីង សាន នៅសល់តែមួយចម្រៀកតូចស្ទើររកអ្វីមកប្រៀបធៀបបាន ។ បើទោះបីជាក្ដីសង្ឃឹមនៅសល់ប៉ុនរន្ធម្ជុលក៏ដោយ មីង សាន នៅតែស្នើសុំឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ជួយស្រាវជ្រាវស្វែងរកបងប្រុសរបស់មីងបន្តទៀត ។ មីង សាន ទទួលស្គាល់ថា ការដឹងដំណឹងពីការរស់រានរបស់បងប្រុសមីង គឺជារឿងសំខាន់ និងក្រេកអរក្នុងជីវិតរបស់មីង ។ ចំណែកការដឹងដំណឹងពីការស្លាប់របស់បងប្រុសមីង គឺនៅតែជារឿងសំខាន់ក៏ប៉ុន្តែវាធ្វើឲ្យមីងមានអារម្មណ៍ក្ដុកក្ដួលក្នុងចិត្ត ។ ខ្ញុំយល់ពីចិត្តមីង ។ ខ្ញុំយល់ទៀតថា មានតែពេលវេលាប៉ុណ្ណោះដែលអាចជួយមីងបាន ។ អ្វីដែលនៅសេសសល់សម្រាប់មីងនាគ្រាចុងក្រោយនៃជីវិត គឺអត្ថបទនៅលើទំព័រកាសែតរស្មីកម្ពុជា និងឯកសារ «សេចក្ដីកត់ហេតុ និងចម្លើយ» ៩ ទំព័រ ដែលធ្វើឲ្យមីងមានអារម្មណ៍ថា បានរស់នៅជាមួយបងប្រុស មីង គឺ ហៃ សំអុល ។


គ្រូច គីមសាន និងប្ដី ដែលរកឃើញបងប្រុស ហៃ សំអុល តាមរយៈសារព័ត៌មានរស្មីកម្ពុជា

មីង គ្រូច គីមសាន មានគ្រួសារឈ្មោះ ហេង សាម៉េត រស់នៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**ឆាយ ដាវីន**

# ធណ្ឌិតផ្លែល្ពៅ

**ជំពូក១**

**ភ្លោះទៅរកនរក**

**១) ឯកសណ្ឋានខ្មៅ**

ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ម៉ោង៩ព្រឹក ទីក្រុងភ្នំពេញផ្សាយសំឡេងគួរឲ្យរន្ធត់ «បងប្អូនប្រជាជនកម្ពុជា! ថ្ងៃនេះទីក្រុងភ្នំពេញត្រូវបានរំដោះហើយ បងប្អូនទាំងអស់ត្រូវរក្សារបៀបរៀបរយ ជ័យជម្នះនេះគឺជាជ័យជម្នះដោយប្រដាប់អាវុធលើអាក្សត់ លន់ នល់ មិនមែនជាការចរចា រណសិរ្សរំដោះប្រជាជនកម្ពុជាដាច់ខាតមិនចរចាជាមួយពួកអាក្សត់ លន់ នល់ ជាអាយ៉ងពួកចក្រពត្តិអាមេរិកជាដាច់ខាត» ។ ទាំងវោហារសព្ទទាំងសំឡេងរបស់ជននេះ ទោះបីជាសាមសិបប្រាំពីរឆ្នាំកន្លងទៅហើយក្តី តែវាស្ថិតនៅក្នុងអារម្មណ៍ក្នុងត្រចៀករបស់ខ្ញុំជានិច្ច ។

ពេលនោះខ្ញុំមានអាយុ២០ឆ្នាំហើយ ។ អំឡុងសង្គ្រាមប្រាំឆ្នាំ ខ្ញុំបានភៀសខ្លួនមកនៅកំពង់ឆ្នាំងជាមួយឪពុកម្តាយ ចំណែកបងប្អូនដទៃទៀត ខ្លះនៅភ្នំពេញ ខ្លះទៀតនៅខេត្តបាត់ដំបង ខ្ញុំបានរៀននៅភ្នំពេញ ក៏ប៉ុន្តែនាពេលចូលឆ្នាំថ្មី ក៏បានត្រឡប់មកលេងឪពុកម្តាយនៅឯកំពង់ឆ្នាំង គឺក្រោយឆ្នាំថ្មីបានបីថ្ងៃ ដែលរណសិរ្សរំដោះជាតិកម្ពុជាបានផ្តួលរំលំរបបសាធារណរដ្ឋខ្មែររបស់លោកសេនាប្រមុខ លន់ នល់ ។ យើងមានសេចក្តីត្រេកអរខ្លាំងណាស់ នៅពេលដឹងថារបបសាធារណរដ្ឋខ្មែរពោរពេញទៅដោយអំពើពុករលួយត្រូវបានផ្តួលរំលំយើងសង្ឃឹមថា រណសិរ្សរំដោះជាតិកម្ពុជានឹងដឹកនាំប្រទេសទៅរកការអភិវឌ្ឍប្រកបដោយយុត្តិធម៌ និងឧត្តមគតិ ។

គ្រាន់តែឮថា ភ្នំពេញត្រូវបានរំដោះគ្រប់គ្នាសុទ្ធតែត្រេកអរ ព្រោះថា សង្គ្រាមបានបន្សល់នូវវិនាសកម្មយ៉ាងខ្លាំងក្លាដល់មាតុភូមិ ។ ពេលនោះម្តាយខ្ញុំ ដែលមានអាយុ៥៨ឆ្នាំ បានរៀបចំកញ្ចប់អាហារមានបាយ ត្រីងៀតប្រគល់មកខ្ញុំ ចំណែកខ្លួនខ្ញុំផ្ទាល់ ក៏បានកាប់មែកឫស្សីយកមកចងក្រណាត់ស ដើរចេញទៅស្វាគមន៍ដំណើរមកទីក្រុងនៃទ័ពរណសិរ្សរំដោះជាតិកម្ពុជា ។ ពេលវេលាក៏បានមកដល់ម៉ោងដប់មួយកន្លះ រន្ធំមូលផ្លូវបំបែកមន្ទីរពេទ្យខេត្តកំពង់ឆ្នាំងក្បួនព្យុះហយាត្រារបស់ទ័ពរណសិរ្សរំដោះជាតិកម្ពុជាក៏បានធ្វើដំណើរមកដល់ ។

ដំណើរចូលក្រុងនៃរណសិរ្សរំដោះជាតិកម្ពុជា ។ យើងនាំគ្នាទះដៃព្រមទាំងគ្រវីទង់ពណ៌ស ព្រមទាំងស្រែកជ័យឃោស «ជ័យយោ! រណសិរ្សរំដោះជាតិកម្ពុជា ជ័យយោ! ការបង្រួបបង្រួមជាតិ» ។ កងទ័ពរណសិរ្សរំដោះជាតិកម្ពុជាធ្វើដំណើរយ៉ាងស្វាហាប់ ។ អ្នកទាំងនោះមានចំនួនប្រហែលបីរយនាក់ ស្លៀកពាក់ខ្មៅ ពាក់មួកកន្តឹបខ្មៅរបៀប ម៉ៅ សេទុង នៅចង្កេះមានស្ពាយអង្រឹង ចំណែកស្បែកជើងជាប្រភេទស្បែកជើងសង្រែកដែលខ្ញុំមិនដែលឃើញទាល់តែសោះ ។ ទាំងអស់គ្នាសុទ្ធតែមូរជើងខោខាងឆ្វេង ប្រហែលជាសញ្ញាសម្ងាត់អ្វីមួយ ។ ខ្ញុំចាប់អារម្មណ៍ថា ទឹកមុខរបស់យោធាទាំងនោះស្ងួតចែស ហាក់បញ្ជាក់ថា មិនរវល់នឹងសម្រែកអបអរសាទររបស់យើងទាល់តែសោះ ។ យើងដើរតាមពីក្រោយដើម្បីសម្តែងការរាក់ទាក់តែយោធាទាំងនោះមិនរវល់នឹងយើងឡើយ ។ដល់មុខសណ្ឋាគារខេត្តគឺជាទីលានបាល់ទាត់ ។ នៅទីនោះមានឡានរដ្ឋការ លន់ នល់ ប្រហែលជាដប់គ្រឿងកំពុងរង់ចាំស្វាគមន៍កងទ័ពរណសិរ្សរំដោះជាតិកម្ពុជា ។ ខ្ញុំសង្កេតឃើញថា នាយទាហាន លន់ នល់ ម្នាក់បានចេញមកគំនាប់មេបញ្ជាការកងទ័ពរណសិរ្សរំដោះជាតិកម្ពុជា ។ នៅខាងឆ្វេងដៃមានគំនរអាវុធដែលទាហាន លន់ នល់ បានយកមកប្រគល់ឲ្យជាសញ្ញានៃការចុះចាញ់ ។ ខ្ញុំមិនបានស្តាប់ឮពីការជជែកគ្នានៃមេបញ្ជាការទាំងពីរនោះទេ ហើយបន្តិចក្រោយមក ក៏ឃើញទាហានទាំងនោះនាំគ្នាឡើងរថយន្តប្រហែលជាងដប់ ហើយឡានហ្ស៊ីបក៏បានដឹកក្បួននោះបើកសំដៅទៅផ្លូវបាត់ដំបង ។

**២) សមមិត្ត**

ខ្ញុំព្យាយាមដើរតាមយុទ្ធជនទាំងនោះ ប៉ុន្តែអ្នកទាំងនោះក៏ព្យាយាមគេចពីខ្ញុំផងដែរ ។ ខ្ញុំបានហុចបាយកញ្ចប់ទៅឲ្យ ក៏ប៉ុន្តែ

បែរផ្ងាកមុខចេញ ហើយសម្តែងអាកប្បកិរិយាដូចជាធុញទ្រាន់ ។ យោធាទាំងអស់វាយគ្នាឯណេះបីបួននាក់ ឯណោះបីបួននាក់ ។ ដោយចង់ដឹងសភាពការណ៍ ខ្ញុំក៏បើកម៉ូតូហុងដារបស់ខ្ញុំកាត់មន្ទីរពិព័រណ៍ឆ្ពោះទៅចំណតរថយន្ត រួចហួសទៅបណ្ណាគារដែលស្ថិតនៅកណ្តាលទីក្រុង ។

ម៉ោងមួយកន្លះរសៀល ទីក្រុងកំពង់ឆ្នាំងមានសភាពស្ងាត់ជ្រងំ ។ តាមផ្លូវក្នុងទីក្រុងមនុស្សម្នាមិនហ៊ានធ្វើដំណើរដូចសព្វមួយដង ព្រោះពុំទុកចិត្តស្ថានការណ៍ជាយថាហេតុ ។ យើងឃើញយុទ្ធជនដែលមានឯកសណ្ឋានពណ៌ខ្មៅឈរយាមយ៉ាងប្រុងប្រយ័ត្ន ។ ខ្ញុំបើកម៉ូតូកាត់មន្ទីរឃោសនាការ បម្រុងហួសទៅមើលបន្ទាយកងរំដោះសេនាតូចលេខ៨៨ ស្រាប់តែឮសំឡេងដូចកូនក្មេងស្រែកហៅខ្ញុំ ។ មិត្តបង! ខ្ញុំងាករកមើលម្ចាស់សំឡេង សំឡេងដដែលបន្លឺឮជាងមុន ។ មិត្តបង! អីគឺមិត្តបងឯងហ្នឹងហើយ! ពេលខ្ញុំបែរចំ ខ្ញុំភ្ញាក់ស្ទើរលោះព្រលឹង ។ ម្ចាស់សំឡេង គឺជាកុមារាម្នាក់ ។ ខ្ញុំប៉ាន់ស្មានថា ក្មេងនោះមានអាយុប្រហែលដប់បួនឆ្នាំ ហើយពាក់មួកកន្ទឹបបង់កក្រមាពណ៌ក្រហម ស្ពាយកាំភ្លើង មាត់ជក់បារីស្លឹកសង្កែ កម្ពស់ស្ទើរនឹងកម្ពស់កាំភ្លើងដែរ ។ ខ្ញុំបញ្ឈរម៉ូតូ ហើយសួរទៅកាន់យុទ្ធជនថា បាទ! លោកហៅខ្ញុំមែនទេ? មែនហើយ! យុទ្ធជនឆ្លើយ ហើយបន្តថា តែកុំហៅខ្ញុំថា «លោក» ហៅខ្ញុំថា «សមមិត្ត!» សមមិត្តប្រែថា «ស្មើគ្នា» គ្មានលោក គ្មានឯកឧត្តម សមមិត្ត! ខ្ញុំខទានដោយភ្ញាក់ផ្អើល ។ មែនហើយ! សមមិត្តបានន័យថា យើងទាំងអស់គ្នាស្មើគ្នា ។

យុទ្ធជនតូចផ្ទៀងមើលម៉ូតូរបស់ខ្ញុំមួយសន្ទុះធំ សមមិត្តតូចចាប់ផ្តើមការសន្ទនាសាជាថ្មី ។ សមមិត្តបង តើម៉ូតូនេះជារបស់សមមិត្តមែនទេ? បាទមែនហើយ សមមិត្តប្អូន! តើគ្រួសារសមមិត្តបងជាអ្នកមានមែនទេ? បាទ! មិនជាមានណាស់ណាទេ ។ បើជាអ្នកមានគួរប្រយ័ត្នផង ព្រោះអ្នកមានជាសត្រូវនឹងបដិវត្តន៍ ។ ខ្ញុំពុំបានយល់ទាំងស្រុងនូវអ្វីដែលសមមិត្តតូចបាននិយាយនោះទេ ព្រោះអារម្មណ៍របស់ខ្ញុំ ផ្តោតទៅលើសន្តិសុខផ្ទាល់ខ្លួន និងគ្រួសាររបស់ខ្ញុំ ។ ខ្ញុំសូមលាសមមិត្តតូច ហើយបើកម៉ូតូត្រឡប់មកផ្ទះវិញ ។ តាមផ្លូវត្រឡប់មកផ្ទះ មានសមមិត្តជាច្រើនឈររេរាកាន់កាំភ្លើងក្នុងស្ថានភាពប្រុងជើងការណ៍ ។ សមមិត្តម្នាក់បានបញ្ឈប់ដំណើររបស់ខ្ញុំ ហើយសួរថា នែ៎មិត្ត! សូមប្រញាប់រួសរាន់ ព្រោះស្ថានការណ៍សន្តិសុខពុំមានអំណោយផលទេ? គ្រាន់តែឮដូច្នេះភ្លាម ខ្ញុំក៏ប្រញាប់សូមលាមិត្ត ហើយបើកម៉ូតូយ៉ាងលឿនត្រឡប់មកផ្ទះ ។

នៅផ្ទះម្តាយខ្ញុំបានស្ទុះមកទទួលខ្ញុំដោយអំណរ ព្រោះគាត់បារម្ភពីខ្ញុំយ៉ាងខ្លាំង ។ ខ្ញុំបានរៀបរាប់ប្រាប់ម្តាយអំពីអ្វីដែលខ្ញុំបានឮ និងឃើញ ព្រមទាំងពាក្យថ្មីៗដែលខ្ញុំទើបនឹងស្គាល់តាមរយៈសមមិត្តទាំងនោះ ។ កំពុងតែជជែកគ្នា ស្រាប់តែបងប្រុសរបស់ខ្ញុំបានចូលមក ។ ប៊ុនថាន់ ជាឈ្មោះរបស់គាត់ បងប្រុសរបស់ខ្ញុំជាអតីតសាស្ត្រាចារ្យភាសាបារាំង ។ បងប្រុសខ្ញុំត្រូវមេបញ្ជាការចាត់តាំងឲ្យដឹកនាំទាហានទៅទទួលសម្តេចឪ នៅម៉ោងពីរកន្លះនេះហើយ ។ ខ្ញុំពុំដឹងថានឹងមានអ្វីកើតឡើងទេ ។ បងប្រុសខ្ញុំផ្តាំឪពុកម្តាយថា សូមពុកម៉ែជួយមើលប្រពន្ធរបស់ខ្ញុំផង ។

ម្តាយរបស់ខ្ញុំសម្រក់ទឹកភ្នែកហើយក្រោកឈរឲ្យពរបងប្រុស ។ នៅក្រៅផ្ទះ សំឡេងស៊ីផ្លេលាន់ឡើង ។ បងប្រុសស្លៀកសម្លៀកបំពាក់ទាហានដើរចេញទៅ ។ ខ្ញុំតាមមើលដំណើររបស់គាត់ ហើយនៅមុខផ្ទះ រថយន្តហ្ស៊ីបបានបញ្ឈប់ចាំបងប្រុសឡើងរថយន្តដែលមានយុទ្ធជនពីរនាក់អង្គុយអមហើយបើកចេញទៅស្រែខាងជើង ។

## ៣) ជាប់ខាតមិនចរចា

បងប្រុសបានចេញទៅបាត់ហើយ ម្តាយខ្ញុំចម្អិនម្ហូបអាហារសម្រាប់យើងក្នុងផ្ទះមិនសូវមានភាពរីករាយទេ ម្នាក់ៗមានអារម្មណ៍ប្លែកៗរៀងខ្លួន យើងឮសូរកាំភ្លើង រីឯវិទ្យុទីក្រុងភ្នំពេញ ក៏ចាប់ផ្តើមចាក់ចម្រៀងបដិវត្តន៍ ។ «បទចម្រៀងថ្មី ប្រហែលជានិពន្ធក្នុងអំឡុងសង្គ្រាមស៊ីវិល ឬក៏និពន្ធភ្លាមៗ មានអត្ថន័យប្រយុទ្ធនឹងកំហឹងវណ្ណៈ សំឡេងនៃមនុស្សដដែលផ្ទួនលើពាក្យជ័យជម្នះប្រដាប់អាវុធដែលមិនមែនជាការចរចា ។ ដោយទីក្រុងកំពង់ឆ្នាំងមិនធំដូចទីក្រុងភ្នំពេញស្ថានការណ៍មិនសូវមានភាពច្របូកច្របល់ប៉ុន្មានទេ អ្នកស្រុកពុំដើររហេតរហូត ឯផ្សារលក់ទំនិញក៏ពុំមានសកម្មភាពដែរ ។

ក្នុងចិត្តខ្ញុំមានភាពមិនច្បាស់លាស់ដោយសារតែសមមិត្តមិនបានសម្តែងនូវភាពរួសរាយជាមួយយើងទាល់តែសោះ ។ ប្រហែលម៉ោងបួនល្ងាច ខ្ញុំកំពុងឈរនៅមុខផ្ទះ ខ្ញុំបានឃើញយុទ្ធជនបួនប្រាំនាក់ដើរសំដៅមកក្នុងនោះមានម្នាក់វ័យប្រហែល

សាមសិបឆ្នាំកាន់កាំភ្លើងអាកា បាននិយាយមកកាន់ខ្ញុំ “នែមិត្ត! ប្រញាប់ចេញពីផ្ទះ! យើងត្រូវទៅទទួលសម្ដេចសីហនុ នៅព្រលានយន្តហោះ ។ តើត្រូវទៅឥឡូវនេះឬ? ខ្ញុំសួរ ។ មែនហើយ! ឥឡូវនេះ ត្រូវទៅទាំងអស់គ្នា ។ បើទទួលសម្ដេចឪ ម៉េចក៏ចាំបាច់ទៅទាំងអស់គ្នា? រំពេចនោះ បុរសអាវខ្មៅម្នាក់មាឌធំ ស្ទុះចេញមក ហើយដកកាំភ្លើងខ្លីផ្ទង់ចំក្បាលរបស់ខ្ញុំ ហើយនិយាយថា “កុំចាំបាច់សួរ! បដិវត្តន៍ដាច់ខាតមិនចរចា” ។

ពេលដែលកាំភ្លើងខ្លីផ្ទង់ក្បាល ខ្ញុំនៅទ្រឹងពុំកំរើក យោធាខ្មែរក្រហមដទៃទៀតដើរចេញពីផ្ទះមួយ ទៅផ្ទះមួយទៀតដើម្បីប្រកាសឲ្យចាកចេញ ។ សមមិត្តអាវខ្មៅដកកាំភ្លើងខ្លីចេញពីក្បាលខ្ញុំដោយនិយាយថា “បដិវត្តន៍ផ្ដាច់ការអធន តើមិត្តឯងចេញឬស្លាប់! ពេលនោះខ្ញុំពុំយល់អ្វីទាល់តែសោះ ស្នូរកាំភ្លើងលាន់គ្រប់ទិសទីគឺជាការបាញ់គំរាមឲ្យចាកចេញពីផ្ទះ ។

ព្រលប់ឈានមកដល់ ស្នូរកាំភ្លើងនិងសម្រែកគំរាមឲ្យចាកចេញលាន់ឮគ្រប់ទិសទី ។ ម្ដាយរបស់ខ្ញុំ បងស្រី និង បងថ្លៃស្រីរួមទាំងកូនៗ បានមកជួបជុំនៅផ្ទះម្ដាយខ្ញុំ ចំណែកបងប្រុសខ្ញុំ និងបងថ្លៃពីរនាក់ទៀតបានចាកចេញជាមួយយោធាខ្មែរក្រហមទៅទទួលសម្ដេចឪតាំងពីថ្ងៃត្រង់ ។ សមមិត្តបានប្រាប់យើងថា កុំចាំបាច់យកអ្វីតាមខ្លួន ព្រោះស្អែកយើងនឹងត្រឡប់មកវិញហើយ ក៏ប៉ុន្តែម្ដាយខ្ញុំពុំជឿឡើយ ។ គាត់អង្គុយរៀបចំអីវ៉ាន់យ៉ាងស្ងៀមស្ងាត់ រួចខ្ញុំលើកដាក់អីវ៉ាន់ទាំងនោះលើកែបម៉ូតូ យើងចាកចេញពីផ្ទះទាំងអស់ ។ ពេលនោះឪពុកខ្ញុំមានវ័យចំណាស់ទៅហើយ គាត់មានអាយុ៦៨ឆ្នាំ ។ យប់កាន់តែងងឹតយើងចាកចេញដោយពុំដឹងថាត្រូវទៅណាទេ ។

ហ្វូងមនុស្សកកកុញពាសពេញផ្លូវក្មេងតូចៗយំទារឲ្យគេពចាស់ៗដើរពុំរួចត្រូវគេសែងស្រីៗ ស្រែកហៅ កូន ហៅ ប្ដី អ្នករបួសពិការត្រូវគេដើរជាន់ពីលើ សម្រែកសម្លុតគំរាមរបស់យោធាខ្មែរក្រហមជំរុញឲ្យដើរទៅមុខយប់ងងឹតឈឹង ។ ពេលដែលយើងងាកមើលទៅក្រោយ ផ្ទះរបស់យើងត្រូវភ្លើងឆាបឆេះ ពុទ្ធោ! យោធាទាំងនោះដុតផ្ទះរបស់យើងហើយបណ្ដេញយើងចេញ ។ យើងរំកិលទៅមុខយឺតៗ ដោយសារហ្វូងមនុស្សច្រើនពេក ។ នៅតាមផ្លូវខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងសម្រាកឡើយ ។ ខ្ញុំសម្គាល់ថា យើងមកដល់ព្រលានយន្តហោះដែលនៅជាប់បន្ទាយ ចាន់សារិ គឺប្រហែល៥គីឡូម៉ែត្រ ក៏ប៉ុន្តែយើងប្រើពេលជាងបួនម៉ោង ។ យើងអស់កម្លាំងជាខ្លាំង ហើយមេឃក៏មិនអាណិតយើងដែរ ភ្លៀងក៏បង្អុរមក យើងគ្មានអាវភ្លៀង ក្មួយៗតូចៗរបស់ខ្ញុំទទឹកទឹកភ្លៀងជោគ ហើយរងារណ្ដំធ្មេញ យើងក៏ចូលទៅជ្រកភ្លៀងនៅវត្តព្រែកត្នោត ក៏ប៉ុន្តែទីនោះ ក៏គ្មានកន្លែងជ្រកដោយសារមានមនុស្សច្រើនពេក ឯខ្មែរក្រហមក៏នៅតែបន្តស្រែកគំរាមឲ្យយើងដើរទៅមុខទៀត ។

## ៤) ក្ដីសង្ឃឹម

ពេលនេះយើងបានមកដល់ទន្ទឹមនឹងព្រលានយន្តហោះហើយ ហេតុអ្វីក៏ខ្មែរក្រហមនៅតែបន្តជំរុញដំណើរយើងទៅមុខទៀតដូច្នេះ ។ ទោះបីជាមានចម្ងល់ក៏ដោយ តែម្ដងនេះ ខ្ញុំមិនហ៊ានសួរនាំដូចមុនទៀតទេ ក៏ប៉ុន្តែសេចក្ដីសង្ឃឹមនៅមានក្នុងចិត្តព្រោះខ្ញុំជឿថា សង្គ្រាមស៊ីវិលប្រាំឆ្នាំកន្លងទៅនេះគឺ ដោយសារ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេច ប្រហែលជាព្រះអង្គមិនយាងមកតាមយន្តហោះទេ បន្តិចទៀតយើងនឹកបានទទួលព្រះអង្គ ហើយវិលត្រឡប់ទៅផ្ទះវិញ ក៏ប៉ុន្តែសំណួរមួយបានចោទឡើង តើយើងនឹងទៅនៅឯណាបើផ្ទះរបស់យើងឆេះអស់ទៅហើយ? ប្រហែលជាសម្ដេច ទ្រង់នឹងកសាងលំនៅដ្ឋានថ្មីឲ្យយើង ពេលនោះយើងនឹងកសាងកម្ពុជាស្អាតស្អំ រុងរឿង ប្រាសចាកអំពើពុករលួយ ។

គិតដល់ត្រឹមនេះសេចក្ដីសង្ឃឹមក៏លេចធ្លោក្នុងចិត្ត ខ្ញុំមានកម្លាំងនឹងដើរតទៅទៀតជាមួយម៉ូតូហុងដាដែលមានកម្លាំងបន្តិចបន្តួចជាមួយអីវ៉ាន់ ចាន ឆ្នាំង ខោអាវ កំពុងតែស្ថិតទៅក្នុងក្ដីសង្ឃឹម ស្រាប់តែក្មួយតូចៗរបស់ខ្ញុំស្រែកយំឡើង ឯឪពុកខ្ញុំបានដំពប់ដើងដួលដោយសារជរាភាពរបស់គាត់ ។ ដីរអិលធ្វើឲ្យបងស្រីខ្ញុំដែលពកូនដួលបោកខ្លួនទៅនឹងដី ។ យើងដើរទៅមុខលែងរួចហើយ ឯខ្ញុំក៏ងងុយដេកនិងអស់កម្លាំងខ្លាំងណាស់ដែរ ។ ខ្ញុំបញ្ឈរម៉ូតូក្បែរគល់ឈើ ហើយប្រាសខ្លួនទាំងទទឹកជោគដេកផ្អែកលើការ៉ុងខោអាវ ។ ក្មេងៗរងាខ្លាំងណាស់ តែយើងពុំអាចដុតភ្លើងកំដៅខ្លួនបានទេ ព្រោះអ្វីៗក៏សើមទាំងអស់ ។ យប់នោះ យើងដេកនៅក្បែររបងវត្តក្បែរចិញ្ចើមថ្នល់ ។ ក្មេងៗដែលពុំដែលជួបប្រទះស្ថានការណ៍បែបនេះក៏ស្រែកយំលាន់ឮអឺងកង ។

## ៥) កម្មសិទ្ធិសមូហភាព

ស្អែកឡើងយើងត្រូវខ្មែរក្រហមបង្ខំឲ្យបន្តដំណើរទៅទៀត យើងធ្វើដំណើរឆ្ពោះទៅទិសខាងលិចតាមផ្លូវលេខ៥៣ ឪពុកខ្ញុំបានជួបនឹងការលំបាកយ៉ាងខ្លាំងដោយគាត់អាយុ៦៨ឆ្នាំទៅហើយ ។ គាត់មានការអត់ធន់ខ្លាំងណាស់ដោយពុំមានត្អូញថ្ងូរសោះក្នុងការលំបាករបស់យើង សម្រាប់ក្មេងតូចៗដែលពុំធ្លាប់ជួបប្រទះ ហើយទ្រហោយំមួយចប់តាមផ្លូវ ខ្លះទារនំញ៉ាំ ឯខ្លះទៀតទារឲ្យគេព ឲ្យគេអៀវ ។ ខ្ញុំជាកូនទីប្រាំបីក្នុងគ្រួសារក្នុងចំណោមប្រាំបួននាក់ ក៏ប៉ុន្តែពេលនេះ ខ្ញុំបានក្លាយជាមនុស្សធំជាងគេ ព្រោះថាបងប្រុសរបស់ខ្ញុំនិងបងថ្លៃប្រុសខ្ញុំបានចាកចេញពីផ្ទះទៅទទួលសម្តេចឪអស់ហើយ ឯវាសនារបស់គាត់ក៏ពុំដឹងថាជាយ៉ាងណា ឯកូនៗស្ថិតនៅជាមួយម្តាយដែលមានកម្លាំងខ្សោយ ហើយពុំធ្លាប់មានជីវភាពលំបាកបែបនេះផង ។

យើងបន្តដំណើរយ៉ាងលំបាក តែបើក្រឡេកទៅមើលគ្រួសារដទៃទៀតលំបាកជាងយើងទៅទៀត ដោយត្រូវសែងឪពុកម្តាយចាស់ឬត្រូវរុញដោយរទេះ ខ្លះទៀតប្តីព្រាត់ប្រពន្ធកូន មានអ្នកខ្លះគ្មានខោអាវ គ្មានអង្ករ ចំណែកខ្មែរក្រហមពុំបានរវល់នឹងទុក្ខលំបាករបស់អ្នកទាំងនោះឡើយ ។ ធ្វើដំណើរបានប្រហែលមួយម៉ោង ខ្ញុំត្រូវបញ្ឈប់ដោយសមមិត្តតូចដែលខ្ញុំបានជួបកាលពីម្សិលមិញបានស្រែកហៅខ្ញុំ ។

មិត្តបង ខ្ញុំសុំស្នើម៉ូតូនេះ ទោះបីមិត្តបងយកម៉ូតូនេះទៅដល់មូលដ្ឋាន ក៏គង់តែអង្គការប្រមូលដាក់សមូហភាពដដែលទេ សូមប្រគល់ឲ្យសមូហភាពពេលនេះចុះ ។ ខ្ញុំទាល់គំនិតពុំដឹងជាដោះស្រាយយ៉ាងម៉េចជាមួយសមមិត្តតូច ក៏ឈរនៅស្ងៀម ។ ឃើញខ្ញុំអល់អែកយ៉ាងនេះ សមមិត្តតូចដើរចូលជិត ហើយអង្អែលស្មាខ្ញុំ ។ មិត្តបងមិនយល់ទេ បដិវត្តន៍វណ្ណៈអធន សមូហភាពជាម្ចាស់នៃវណ្ណៈកសិករ កម្មករ អធន អ្វីៗជារបស់យើងទាំងអស់គ្នា សមមិត្តបងទុកមូលដ្ឋាននេះឲ្យយើងប្រើប្រាស់ជាប្រយោជន៍សមូហភាពសិនចុះព្រោះថា អំណឹះតទៅពួកមូលធននិយម វណ្ណៈសក្តិភូមិនឹងត្រូវកម្ទាត់ចោលទាំងស្រុងហើយ ។

មិនរង់ចាំចម្លើយរបស់ខ្ញុំយូរ សមមិត្តចាប់ដៃម៉ូតូហើយចង្អុលទៅថង់អីវ៉ាន់ខាងក្រោយ ។ ខ្ញុំងាកទៅស្រាយថង់អីវ៉ាន់ដាក់ចុះ ហើយប្រគល់ម៉ូតូឲ្យសមមិត្តតូច ។ គេញញឹមយ៉ាងស្រស់ ហើយឡើងលើម៉ូតូបម្រុងបើកចេញ ។ តាមសន្មតមើលទៅពុំទាន់ចេះបើកម៉ូតូនៅឡើយទេ ។ ខ្ញុំដើរចុះទៅព្រៃក្បែរផ្លូវរកកាប់ឫស្សីយកមកធ្វើដងរែក ហើយរែកឥវ៉ាន់ទាំងនោះដឹកនាំក្បួនគ្រួសារធ្វើដំណើរជាមួយហ្វូងមនុស្សតទៅទៀត ។

## ៦) គល់ចេកដើមល្ហុង

ថ្ងៃត្រង់ក្តៅខ្លាំង ហ្វូងមនុស្សចេះតែធ្វើដំណើរឥតដាច់ ។ យើងមកដល់ផ្លូវបំបែកក្រាំងម៉ុ ។ នៅត្រង់នេះមានសាលាសំណាក់មួយដែលឲ្យយើងរកទឹកដាំបាយហូបបាន ។ ម្តាយរបស់ខ្ញុំជាស្ត្រីមានគំនិតបានរៀបចំអីវ៉ាន់មានចាន ឆ្នាំង អំបិល ទឹកត្រី អង្ករ និងខោអាវដាក់លើម៉ូតូរបស់ខ្ញុំ ក៏ប៉ុន្តែបងស្រីខ្ញុំ និងបងថ្លៃស្រីពីរនាក់ទៀត ពុំបានយកអ្វីមកជាមួយទេ ។ គាត់ប្រមូលតែលុយ និងមាសពេជ្រ នាឡិកាថ្លៃៗ មកជាមួយតែប៉ុណ្ណោះ ម្យ៉ាងទៀត គាត់មានកូនបីបួននាក់ក្នុងមួយគ្រួសារ ហើយកូនទាំងនោះសុទ្ធតែជាកូនទំយើ ពុំចេះជួយឬរែកអ្វីឡើយ ម្ល៉ោះហើយពេលនេះគ្មាននរណាលក់អ្វីទាំងអស់ ។ កូនអ្នកមានទាំងនោះស្រែកយំទារនំ ហើយពុំចេះអត់ទ្រាំនឹងការលំបាកអ្វីឡើយ ។ ម្តាយរបស់ខ្ញុំបង្ខំចិត្តយកអង្ករមកដាំបាយសម្រាប់មនុស្ស១៧នាក់ ។ ពេលបាយ គ្មានសាច់គោប៊ីហ្វសិក ឬសាលាដក្មេងថ្ងូរថា ពុំចេះស៊ី រឹងកូនខ្លះយំទារប័រប្រហុមាស់ ដោយសារត្រូវទឹកភ្លៀងពីរយប់ហើយព្រឹកឡើងត្រូវដីក្តៅ ហើយធ្វើដំណើរលំបាកជាងខ្ញុំនោះ កូនរបស់បងស្រីខ្ញុំក៏កើតជំងឺរាក ។ តាមធម្មតាផ្ទះគាត់មានវេជ្ជបណ្ឌិតប្រចាំគ្រួសារ តែពេលនេះ ខ្ញុំត្រូវកាន់កាំបិតទៅសកសំបកព្រះញ្ញេយកមកដាំទឹកឲ្យផឹក ។ ក្មេងអស់នោះរឹងរូសណាស់ ពុំព្រមផឹកទឹកទាំងនោះទេ ។

ថ្ងៃទីបី យើងក៏បានមកដល់ភូមិផ្សាររមាស ។ យើងបានចូលទៅសម្រាកក្នុងប៉មបែកបាក់មួយដែលបន្សល់ទុកដោយអាណានិគមបារាំង ។ កូនរបស់បងស្រីខ្ញុំរាកយ៉ាងខ្លាំងសូម្បីតែស្លឹកត្របែកដែលខ្ញុំបានបេះដើម្បីស្ងោរក៏វាពុំព្រមផឹក ទីបំផុតវាក៏ដាច់ខ្យល់ស្លាប់នៅទីនោះទៅ ។ ខ្ញុំត្រូវយកសាកសពរបស់ក្មួយរុំដោយសារុងទៅបញ្ចុះនៅក្បែរប៉មបារាំង ។ នេះជាមរណភាពទីមួយនៃសមាជិកគ្រួសារខ្ញុំ ក្នុងដំណើរឆ្ពោះទៅកន្លែងមួយដែលខ្ញុំមិនស្គាល់សោះ ។ ថ្ងៃទីបួន យើងបានមកដល់ស្តុកអាចម៍រមាសដែលជាស្រុកកំណើតរបស់ពុក ។ មុនសង្គ្រាមស៊ីវិល ស្តុកអាចម៍រមាសជាទីប្រជុំជនដ៏ធំមួយនិងជា

*បន្ទាយទាហានអាណានិគមបារាំង ហើយក៏ជាផ្លូវបំបែកភ្នំពេញ បាត់ដំបង ព្រមទាំងមានស្ថានីយ៍រថភ្លើងផង ។*

*រយៈពេល៥ឆ្នាំ ស្តុកអាចម៍រមាសបានក្លាយទៅជាសមរភូមិក្តៅរវាងរដ្ឋការ លន់ នល់ និងរណសិរ្សរំដោះជាតិ សីហនុនិយម ហើយខណៈដែលយើងមកដល់ទីនេះស្ងាត់ជ្រងំ សល់តែគំនរបាក់បែកនៃផ្ទះល្វែងនិងបន្ទាយទាហាន ។ យើងសម្រាកទីនេះពីរយប់ ហ្វូងមនុស្សបានថយច្រើន ព្រោះខ្លះបានធ្វើដំណើរតាមបណ្តោយផ្លូវរថភ្លើងទៅទិសភ្នំពេញ ឯខ្លះទៀតធ្វើដំណើរតាមផ្លូវលេខ៥៣ ទៅខេត្តពពក ។ នៅទីនោះ អនុស្សាវរីយ៍ដ៏ជូរចត់បានស្ថិតនៅក្នុងអារម្មណ៍ខ្ញុំរហូតដល់សព្វថ្ងៃ ។ ពេលនោះអង្ករនៅក្នុងថង់ដែលម្តាយខ្ញុំបានដាក់ពីផ្ទះបានរលស់ជិតអស់ទៅហើយ ឯលុយដែលបងស្រីខ្ញុំបានយកមកជាមួយមិនអាចរកទិញអ្វីបានឡើយ ។ សម័យនោះ នាឡិកាដៃម៉ាកថ្ងៃអាចដូរជាអង្ករបាន១០កំប៉ុង តែបើចិញ្ចៀនពេជ្រមួយវង់អាចដូរបានប្រាំកំប៉ុងប៉ុណ្ណោះ ដើម្បីអាហារមួយពេលសម្រាប់មនុស្ស១៦នាក់យើងត្រូវការអង្ករប្រាំបីកំប៉ុង ដូច្នេះទោះបីយើងមាននាឡិកាដប់ ក៏ពុំគ្រប់នឹងដូរយកអង្ករមកដាំបាយបានដែរ ។ ដើម្បីឲ្យគ្រប់គ្នាបានឆ្អែត ខ្ញុំត្រូវដើរចូលទៅក្នុងភូមិដែលជាអតីតរោងចក្រអារឈើរបស់ម្តាយមីងខ្ញុំ រកកាប់ដើមចេកឲ្យល្អិតដូចបាយជ្រូកលាយនឹងអង្ករ ។ បាយរបស់យើងពណ៌ខ្មៅយ៉ាប់ជាងបាយសម្រាប់ឆ្កែដែលយើងធ្លាប់ចិញ្ចឹមទៅទៀត ។ ចំពោះដើមល្ហុងយើងត្រូវពុះជាពីរហើយកោសយកសាច់ខាងក្នុងយកមកស្ងោរអស់ជាតិជ័រយកមកលាយអង្ករហើយដាំបាយ ។ វាគ្មានរសជាតិទេ តែយើងត្រូវតែបរិភោគ ព្រោះយើងគ្មានអ្វីក្រៅពីនេះទេ ។  បាយលាយបណ្តូលល្ហុងនេះប្រៀបដូចជាចំណាំងឈើឬកាកដូងដែលយើងប្រឆាំងយកខ្ទិះអស់ដូច្នេះ ។ វាគ្រាន់តែបំពេញក្រពះតែមិនមានរសជាតិ ឬកាឡូរីអ្វីទាំងអស់ ។*

*យើងត្រូវរកក្តាមឬខ្យងមកស្លលាយបន្លែព្រៃ ដូចជា ស្លឹករងៀង ត្រាវព្រៃ ឬប្រាច់ ក៏ប៉ុន្តែបន្លែទាំងអស់នោះក៏មិនមែនជាការងាយរកប៉ុន្មានដែរ ព្រោះមានមនុស្សច្រើនចេញទៅព្រមៗគ្នា ។ យើងក៏ចាប់ផ្តើមអស់អំបិលសម្រាប់បង់សម្ល ដូច្នេះយើងត្រូវយកចិញ្ចៀន ឬខ្សែកមាសទៅប្តូរយកអំបិលពីអ្នកមូលដ្ឋាន ។* ***(នៅមានត)***

**(នៅមានត)**

**ឆាយ  សុឆាត**

# ដំណឹងស្វែករកបង ឪពុកមា និងម្តាយមីង

*ខ្ញុំបាទឈ្មោះ ស្នួរ វីណារិន ជាមន្ត្រីរាជការនៅក្រសួងបរិស្ថាន ទីលំនៅបច្ចុប្បន្នផ្ទះលេខ ១៧៨ (មុំវត្តពោធិ៍ចិនតុង) ផ្លូវ២០០១ កែងមហាវិថីសហព័ន្ធរុស្ស៊ី ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។*

*ខ្ញុំបាទសូមប្រកាសរកបងប្រុសឈ្មោះ ស្នួរ វីឡា កើតឆ្នាំ១៩៦៥ (ឆ្នាំថោះ) មានឪពុកឈ្មោះ ស្នួរ គឹមចេក ស្លាប់ខែមករា ឆ្នាំ២០១២ និងម្តាយឈ្មោះ បេ គឹម ជីង នៅរស់ ។  ឪពុកម្តាយខ្ញុំបាទមានកូនចំនួន៣នាក់ គឺ ៖*

*១) ស្នួរ វីឡា ភេទប្រុស (បាត់ដំណឹង)*

*២) ស្នួរ វីណារ៉ា ភេទប្រុស*

*៣) ស្នួរ វីណារិន ភេទប្រុស*

*ចំណែកមា-មីងមានឈ្មោះ ៖ ទី១) បេ គឹមយ៉ុង (ស្រី) ទី២) បេ គឹមស៊ិន (ស្រី) ទី៣) បេ គឹមហួរ (ស្រី) ទី៤) បេ គឹមលេច ទី៥) បេ គឹមវ័ន្ត (ប្រុស) និង ទី៦) បេ គឹមមុំ (ស្រី) ដែលបានបែកគ្នាក្នុងខែមេសា ឆ្នាំ១៩៧៥ ពេលរបប ប៉ុល ពត ជម្លៀសចេញពីទីក្រុងភ្នំពេញ ។*

*ប្រសិនបើ បង និងមីង-មា ឬញាតិមិត្តណាបានឮដំណឹងនេះ សូមទាក់ទងមកប្អូន ឬក្មួយឈ្មោះ ស្នួរ វីណារិន តាមរយៈទូរស័ព្ទលេខ ០៩៧ ៨ ៨១១ ១០៧ ឬទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ភ្នំពេញ ។*

***សូមអរគុណ!***

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល សហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 161, May 2013 ◆ Funded by USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.